ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ការពិភាក្សាជុំវិញអំពើប្រល័យពូជសាសន៍

◆ ទំនាក់ទំនងចិន-កម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១០១ ខែឧសភា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ១០១ ខែឧសភា ឆ្នាំ២០០៨

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ ៖ ការពិភាក្សាជុំវិញអំពើប្រល័យពូជសាសន៍ ..........១

**ផ្នែកឯកសារ**

◆ ការតស៊ូរបស់នារីពេទ្យ៦មករា ..........៣

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកសន្ទំរំពុកនូវការឈឺចាប់ ..........៦

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម ..........៨

◆ យើងអាចអភ័យទោស ប៉ុន្តែយើងមិនអាចបំភ្លេចបានទេ ..........១៦

◆ របាយការណ៍ពីខេត្តកំពង់ធំ ៖ គម្រោងជួយជនរងគ្រោះ ..........១៨

**ផ្នែកច្បាប់**

◆ សេចក្ដីសម្រេចលើសំណើសុំពន្យារពេលសវនាការ ..........២២

◆ សេចក្ដីសម្រេចលើសំណើសុំឲ្យមានសវនាការដាច់ដោយឡែក ..........២៨

◆ ដីកាណែនាំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដាក់សារណា ..........៣០

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ..........៣៤

◆ ទំនាក់ទំនងចិន-កម្ពុជា ..........៤១

◆ ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ..........៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការចងចាំរបស់មីង ពីង ប៊ួយ ..........៥៦

◆ រង់ចាំតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ..........៥៨

◆ បំភ្លេចមិនបាន ..........៦០







**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នាដៃលេខនេះ ៖** គង់ សុភគឿន, ឌីល ក្រូឌីម, សារ៉ា ថូម៉ាស និង ជី ទេវិទ្ធ, អេតែល ហ៊ីហ្គនេត, ហូលីយ៉ូ អេ. ដេលជ្រែស, ឌី ខាំបូលី, ម៉ែន ពិចិត្រ, និង ហាវ សោភា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ជា ដល្លា, ដួង ចំរើន **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ទេព ម៉េងឃាន **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វ៉េង Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# ការពិភាក្សាជុំវិញអំពើប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍ជាបាតុភូតមួយដែលបានកើតឡើងជាញឹកញយនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ពិសេសនៅក្នុងសតវត្សរ៍ទី២០ ដែលមានការសម្លាប់រង្គាលជនជាតិជ្វីហ្វជាង ៦លាននាក់ដោយពួកណាហ្ស៊ី ការបង្អត់អាហារប្រជាកសិករដោយរបបកុម្មុយនីស្តរបស់ស្តាលីន ការសម្លាប់ប្រជាជនអាមេនៀនដោយរដ្ឋាភិបាលទួគី អំពើប្រល័យពូជសាសន៍កម្ពុជា ជម្លោះរវាងជាតិពន្ធុទុតស៊ី និងហ៊ូទូនៅប្រទេសរ៉្វាន់ដា និងថ្មីៗនេះការកាប់សម្លាប់គ្នានៅដាហ្វ៊ួរ ។ ដោយសារហេតុការណ៍បែបនេះ ក្រោយសង្គ្រាមលោកលើកទី២ត្រូវបានបញ្ចប់ បណ្ឌិតច្បាប់ រ៉ាហ្វែល ឡឹមគិន របស់ប៉ូឡូញ បានដាក់អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ ហើយរួមបញ្ចូលអំពើនេះជាបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ពាក្យថាប្រឆាំងនឹងមនុស្សជាតិមានន័យថា ទោះបីជាអំពើប្រល័យពូជសាសន៍មួយកើតឡើងនៅទីណា ចំពោះប្រជាជនក្រុមណា ពេលណាក៏ដោយ អំពើនេះគឺខុសឆ្គងចំពោះប្រជាជននៅក្នុងពិភពលោកទាំងមូល មិនមែនតែចំពោះជនរងគ្រោះឡើយ ។ អំពើប្រល័យពូជសាសន៍ជាបន្ទុករបស់មនុស្សជាតិទាំងមូលក្នុងការលុបបំបាត់ចោលនិងកាត់ទោសជនដៃដល់ ។ ហេតុនេះ បានជាអង្គការសហប្រជាជាតិខិតខំប្រឹងប្រែងជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាបង្កើតជាអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមចំពោះការស្លាប់បាត់បង់ជីវិតប្រជាជនខ្មែរជិតពីរលាននាក់ ទោះបីជាអ្វីដែលបានកើតឡើងកន្លងផុតទៅជិតបីទសវត្សរ៍ក៏ដោយ ។

ក្រោមការឃោសនារបស់បណ្ឌិត រ៉ាហ្វែល ឡឹមគិន ប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិបានចុះហត្ថលេខាគាំទ្រអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នៅឆ្នាំ១៩៤៨ ។ នៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ត្រូវបានឲ្យនិយមន័យថាជា «អំពើទាំងឡាយណាដែលបានប្រព្រឹត្តឡើងក្នុងគោលបំណងកម្ទេចក្រុមសាសនា ពូជសាសន៍ ជនជាតិ និងជាតិពន្ធុមួយផ្នែក ឬទាំងស្រុង» ។ បញ្ញាជនភាគច្រើនសន្និដ្ឋានថា អត្ថន័យរបស់ពាក្យ «មួយផ្នែក» គឺសំដៅទៅលើការកម្ទេចក្រុមមនុស្សមួយផ្នែកធំពីព្រោះការសម្លាប់មនុស្សមួយចំនួនតូច ឧទាហរណ៍ មនុស្សចំនួន១០ទៅ ២០នាក់នៅក្នុងក្រុមមួយមិនអាចចាត់ទុកថាជាអំពើប្រល័យពូជសាសន៍បានឡើយ ។ តាមការពិតពាក្យ «អំពើប្រល័យពូជសាសន៍» មានលក្ខណៈមិនគ្រប់គ្រាន់នៅឡើយទេ ពីព្រោះធ្វើឲ្យយើងយល់ថា មានតែពូជសាសន៍មួយមុខប៉ុណ្ណោះដែលជាជនរងគ្រោះ ។ ប៉ុន្តែនៅក្រោមច្បាប់អន្តរជាតិ ក្រុមសាសនា ជនជាតិ និងជាតិពន្ធុ ក៏ជាជនរងគ្រោះដែលត្រូវការពារដែរ ។

អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មានចំណុចខ្វះខាតជាច្រើនកន្លែង ។ ទីមួយ វាមិនបានការពារក្រុមនយោបាយ ។ ឧទាហរណ៍ ប្រសិនបើជនដៃដល់កាប់សម្លាប់មនុស្សមួយក្រុមក្រោមហេតុផលថា អ្នកទាំងនោះមាននិន្នាការនយោបាយប្រឆាំងនឹងខ្លួន ទង្វើនេះមិនអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍ក្រោមច្បាប់អន្តរជាតិបានឡើយ ។ ជាក់ស្តែង ចំពោះករណីបទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ព្រះរាជអាជ្ញាអន្តរជាតិពិបាកបកស្រាយពន្យល់ឲ្យបានគ្រប់ជ្រុងជ្រោយថា អ្វីដែលខ្មែរក្រហមបានប្រព្រឹត្តជាអំពើប្រល័យពូជសាសន៍ទៅលើជនរងគ្រោះជិតពីរលាននាក់ដែលបានស្លាប់បាត់បង់ជីវិត ។ មូលហេតុសំខាន់ គឺថាខ្មែរក្រហមហាក់បីដូចជាបានសម្លាប់មនុស្សក្រោមហេតុផលនយោបាយច្រើនជាងហេតុផលប្រកាន់ពូជសាសន៍ សាសនា ឬជាតិពន្ធុ ។ ខ្មែរក្រហមច្រើនតែសម្លាប់ដោយយល់ថា បុគ្គល «ក» លួចឧបករណ៍កសិកម្មក្បត់សមូហភាព បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអង្គការ ធ្វើវិទ្ធង្សនា ឬក្បត់ជាតិ ។ ប៉ុន្តែ ខ្មែរក្រហមកម្រនិយាយថា ការសម្លាប់ប្រជាជនដោយសារជនរងគ្រោះ «ក» នោះជាជនជាតិចិន ចាម វៀតណាម អ្នកកាន់សាសនាគ្រិស្ត ឬសាសនាព្រហ្មញ្ញណាស់ ។ ម្យ៉ាងវិញទៀតខ្មែរក្រហមមានទំនាក់ទំនងយ៉ាងស្អិតល្មួតជាមួយនឹងចិន ប្រទេសកាន់សាសនាអ៊ិស្លាមមួយចំនួន និងវៀតណាមកុម្មុយនីស្តក្នុងទសវត្សរ៍ទី៥០, ៦០ និង៧០ ។ ហេតុនេះ ការសម្លាប់ជនជាតិទាំងនេះអាចធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងអន្តរជាតិដ៏ជិតស្និទ្ធរបស់

កម្ពុជាប្រជាធិបតេយ្យ ។ ពាក្យថា «កម្ទេចពួកយួន» ត្រូវបានពុជារញឹកញាយ ប៉ុន្តែ មិនមែនដោយសារជនរងគ្រោះជាជាតិពន្ធុវៀតណាមសុទ្ធសាធទេ ។ ខ្មែរក្រហមប្រហែលជាយល់ថា ជាតិពន្ធុវៀតណាមមាននិន្នាការនយោបាយប្រឆាំងនឹងខ្លួន ហើយបម្រើផលប្រយោជន៍នយោបាយដល់រដ្ឋាភិបាលកុម្មុយនីស្តវៀតណាម តាមរយៈការធ្វើគិញឬការធ្វើវិទ្ធង្សនាក្នុងរូបភាពផ្សេងៗ ។ ជាក់ស្តែងនៅឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានវាយលុកមកលើកម្ពុជាប្រជាធិបតេយ្យក្នុងទ្រង់ទ្រាយធំពិតមែន ។

ចំណុចខ្វះខាតទី២គឺទាក់ទងទៅនឹងធាតុសត្យានុម័ត និងធាតុអត្តនោម័តរបស់អនុសញ្ញាអំពើប្រល័យពូជសាសន៍ ។ ធាតុអត្តនោម័តទាក់ទងទៅនឹងការគិតគូរក្នុងចិត្តរបស់ជនដៃដល់ថា តើមានចេតនាច្បាស់លាស់ ស្រពេចស្រពិល ឬគ្មានចេតនាសោះ ។ ដើម្បីបញ្ជាក់ថាជនដៃដល់មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ ព្រះរាជអាជ្ញាអាចប្រើប្រាស់វិធីពីរយ៉ាង ។ ទី១) ស្វែងរកភ័ស្តុតាងជាលាយលក្ខណ៍អក្សរ សម្តី ឬការតបជាសំឡេង ។ ទី២) គឺការប្រើវិធីសាស្ត្រធ្វើអនុមាន (ទាញហេតុផល) មានន័យថា បើជនម្នាក់ធ្វើទង្វើជាច្រើនក្នុងរយៈពេលខុសៗគ្នាឬជាមួយគ្នាដើម្បីបម្រើហេតុផលប្រយោជន៍ណាមួយ មានន័យថា ជននោះមានចេតនាប្រព្រឹត្តអំពើទាំងនោះដើម្បីបម្រើផលប្រយោជន៍ជាក់ស្តែងមួយ ទោះជាករណីនេះគ្មានភ័ស្តុតាងជារូបរាង ដូចជាសម្តី ឬអក្សរក៏ដោយ ។ អនុសញ្ញាអំពើប្រល័យពូជសាសន៍មិនបានចែងឲ្យបានច្បាស់លាស់ថាតើត្រូវសម្រេចយកវិធីសាស្ត្រណាមួយទេ ។ វិធីសាស្ត្រទាំងពីរមានភាពអវិជ្ជមានរៀងៗខ្លួន ។ វិធីសាស្ត្រទី១ ទោះបីជាមានលក្ខណៈប្រាកដប្រជាជាងវិធីសាស្ត្រទី២ ព្រះរាជអាជ្ញាពិបាកនឹងស្វែងរកភ័ស្តុតាងជារូបរាងដើម្បីយកមកប្រើប្រាស់នៅក្នុងតុលាការណាស់ ។ ជនដៃដល់ភាគច្រើនពុំបានសរសេរ ឬថតជាសំឡេងនូវអ្វីដែលខ្លួនចង់ធ្វើឡើយ ។ ចំណែកវិធីសាស្ត្រទី២ ទោះបីជាធ្វើឲ្យព្រះរាជអាជ្ញាមានការងាយស្រួលក្នុងការបញ្ជាក់ពីចេតនារបស់ជនដៃដល់ក៏ដោយ ប៉ុន្តែវាអាចមានគ្រោះថ្នាក់ក្នុងការទាញហេតុផលខុស ។ ទង្វើមួយចំនួនអាចកើតឡើងក្នុងលក្ខខណ្ឌមួយដែលមើលទៅមានលក្ខណៈសមស្របគ្នា ប៉ុន្តែទង្វើនោះមិនបានបម្រើផលប្រយោជន៍ឲ្យព្រះរាជអាជ្ញាចោទប្រកាន់ឡើយ ។

ចំណែកធាតុសត្យានុម័តវិញ ទាក់ទងទៅនឹងប្រព្រឹត្តកម្ម ឬមធ្យោបាយដែលត្រូវបានប្រើប្រាស់ដើម្បីសម្រេចឲ្យបាននូវការកាប់សម្លាប់ក្រុមជនរងគ្រោះ ។ ច្បាប់អន្តរជាតិបានចែងថា ទង្វើទាំងនោះមានរាប់បញ្ចូល ការកាប់សម្លាប់ ការធ្វើទុក្ខបុកម្នេញផ្លូវចិត្តនិងផ្លូវកាយ ការបង្កឲ្យមានសេចក្តីស្លាប់ ការពន្យារកំណើតនៅក្នុងក្រុមជនរងគ្រោះ និងការផ្ទេរកុមារពីក្រុមមួយទៅក្រុមមួយទៀត ។ លក្ខខណ្ឌទាំងនេះអាចថាគ្រប់គ្រាន់ ប៉ុន្តែពុំសូវមានលក្ខណៈច្បាស់លាស់ ហើយជួនកាលមានភាពទូលំទូលាយពេក ។ ដោយសារអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ត្រូវបានយកមកប្រើប្រាស់ដោយតុលាការអន្តរជាតិតែពីរឬបីដងតាំងពីឆ្នាំ១៩៤៨ ការបកស្រាយធាតុទាំងឡាយនៅក្នុងច្បាប់មិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ ។ ហេតុនេះ អ្វីដែលបានសម្រេចនៅក្នុងតុលាការអន្តរជាតិនីមួយៗនឹងក្លាយទៅជាឧទាហរណ៍សម្រាប់តុលាការអន្តរជាតិក្រោយៗទៀត ។ នេះជាលក្ខខណ្ឌសំខាន់នៅក្នុងច្បាប់អន្តរជាតិធ្វើតាមទម្លាប់ ។

ជាទូទៅបញ្ញាជនផ្នែកសង្គម នយោបាយ និងអំពើប្រល័យពូជសាសន៍យល់ថា អំពើប្រល័យពូជសាសន៍ជាបាតុភូតមួយដែលក្នុងនោះមនុស្សនៅក្នុងក្រុមមួយធ្វើការកាប់សម្លាប់មនុស្សមួយក្រុមទៀត និងមានគោលបំណងចង់លុបបំបាត់មនុស្សនៅក្នុងក្រុមនោះឲ្យផុតពូជ ។ ក្រុមជនរងគ្រោះក្នុងនិយមន័យនេះគឺរាប់បញ្ចូលទាំងក្រុមនយោបាយ និងក្រុមសង្គមសេដ្ឋកិច្ចផងដែរ ។ នៅក្រោមនិយមន័យនេះ អំពើដែលខ្មែរក្រហមបានប្រព្រឹត្តជាអំពើប្រល័យពូជសាសន៍ ។ ប៉ុន្តែប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានបំណងចង់កាត់ទោសខ្មែរក្រហមពីបទប្រល័យពូជសាសន៍ត្រង់ច្បាប់អន្តរជាតិ តុលាការនេះអាចប្រើប្រាស់វិធីសាស្ត្រពីរ ទី១) ត្រូវស្វែងយល់ថាតើការកាប់សម្លាប់ប្រជាជនចិន ចាម វៀតណាម ខ្មែរ ឬព្រះសង្ឃ ឬអ្នកកាន់សាសនាផ្សេងៗមានហេតុផលដោយឡែកពីហេតុផលនយោបាយឬទេ ។ ទី២) តុលាការអាចព្យាយាមបកស្រាយថា ការកាប់សម្លាប់ក្រោមហេតុផលនយោបាយធ្វើឲ្យមានការកាប់សម្លាប់ប្រជាជនក្នុងរូបភាពជាជាតិពន្ធុ ឬក្រុមសាសនាណាមួយដែលមានចែងនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍ ។ **រអេង កុកថាយ**

# ការតស៊ូរបស់នារីពេទ្យ៦មករា

បន្ទាប់ពីជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកម្ទេចចោលនូវរាល់រចនាសម្ព័ន្ធគ្រប់គ្រងទាំងអស់ រហូតដល់សម្ភារៈប្រើប្រាស់ដែលជារបស់ចក្រពត្តិ ។ ខ្មែរក្រហមបានចាប់ផ្តើមកសាងប្រទេសផ្អែកលើវិស័យកសិកម្ម ដោយយកកម្លាំងប្រជាជនមកប្រើជំនួសម៉ាស៊ីនវិញ ប៉ុន្តែ មិនបានយកចិត្តទុកដាក់លើសុខភាពរបស់ប្រជាជនទេ ។ ជាក់ស្តែង វ៉ាន ម៉ុន ដែលរស់នៅឃុំសាមគ្គី ស្រុកខដុគ្គ ខេត្តកំពង់ស្ពឺ ត្រូវបានបង្ខំឲ្យធ្វើការទាំងមានជំងឺរហូតដល់ដួលសន្លប់នៅពេលកំពុងស្ទូងស្រូវ ។

ម៉ុន កើតក្នុងត្រកូលអ្នកកសិករនិងជាកូនទី១ក្នុងចំណោមបងប្អូនស្រីម្នាក់និងប្រុស៤នាក់ ។ ម៉ុន មានស្រុកកំណើតនៅឃុំជើងរាស់ ស្រុកខដុគ្គ ខេត្តកំពង់ស្ពឺ ។ ក្រោយពីម្តាយរបស់ ម៉ុន ទទួលមរណភាពដោយសារជំងឺនៅឆ្នាំ១៩៧៣ គាត់ត្រូវនៅមើលថែរក្សាប្អូនៗទាំងអស់ ពីព្រោះតែឪពុករបស់គាត់ត្រូវទៅធ្វើការនៅកន្លែងឆ្ងាយ ។ ដោយសារ ម៉ុន ទទួលកាតព្វកិច្ចនេះជំនួសឪពុក ដូច្នេះគាត់មិនដែលបានចូលរៀននៅសាលាដូចជាក្មេងដទៃទេ ។ ដោយគិតថាកុំឲ្យគ្មានចំណេះដូចជាគាត់ ម៉ុន បានបញ្ជូនប្អូនៗរបស់គាត់ឲ្យរៀនអានអក្សរនិងបូកលេខក្រោមការបង្ហាត់បង្រៀនរបស់លោកគ្រូម្នាក់ឈ្មោះ នូ មួន ។

ក្រោយពីកងទ័ពបដិវត្តន៍បានទទួលជ័យជម្នះនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមបំបែកគ្រួសាររបស់ ម៉ុន ឲ្យនៅឆ្ងាយពីគ្នា ដោយបានបញ្ជូនគាត់ឲ្យទៅធ្វើការនៅកងចល័តក្នុងស្រុកអង្គស្នួល ។ ចំណែកឪពុកនិងប្អូនរបស់គាត់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅខេត្តកោះកុង ។ ម៉ុន ស្ថិតនៅវរៈលេខ៣២១ មានសមាជិកទាំងអស់ចំនួន៣០០នាក់ ដែលមានតួនាទីលើកទំនប់ ធ្វើស្រែប្រាំងនិងច្រូតស្រូវចាប់ពីម៉ោង៦ព្រឹកដល់១១ថ្ងៃត្រង់ និងពីម៉ោង១រសៀលដល់ម៉ោង៥ល្ងាច ។ លើសពីនេះ ម៉ុន ក៏ត្រូវធ្វើការរហូតដល់ម៉ោង១០យប់ទៀតទើបអាចសម្រាកបាន ។ ម៉ុន ខិតខំធ្វើការស្ទើរគ្មានសម្រាក ប៉ុន្តែអាហារដែលគាត់ទទួលបានគឺហូបបបរជាមួយសម្លត្រកួន ។

**ធ្លាក់ខ្លួនឈឺ**

ធ្វើការនៅកងចល័តបានមួយរយៈ ម៉ុន ក៏បានធ្លាក់ខ្លួនឈឺ ។ ប៉ុន្តែ ម៉ុន មិនហ៊ានសុំច្បាប់ឈប់សម្រាកទេ ទោះបីជាគាត់ឈឺរយៈពេល១០ថ្ងៃហើយក៏ដោយ ។ ម៉ុន នៅចាំបានថា គាត់បានសុំការអនុញ្ញាតពីប្រធានកងឈ្មោះ រីន ដើម្បីសម្រាកមួយថ្ងៃដែរ ប៉ុន្តែគាត់បែរជាទទួលការស្តីបន្ទោសមកវិញថា *«មិនខិតខំធ្វើការឈឺបន្តិចបន្តួចនាំគ្នាទម្រន់ ថ្ងៃមុខថ្ងៃក្រោយកុំធ្វើរបៀបនេះ បើមិនអ៊ីចឹងទេនឹងរាយការណ៍ទៅថ្នាក់លើហើយ»* ។ ពេលឮសម្តីនេះ ទើបគាត់លែងហ៊ានសុំឈប់ ហើយខំធ្វើការរហូតដល់ដួលសន្លប់នៅវត្តសំរោងកណ្តាលពេលគាត់កំពុងស្ទូងស្រូវ ។ ក្រោយពីសន្លប់មួយយប់មួយថ្ងៃ ម៉ុន ដឹងខ្លួនឡើងនៅក្នុងមន្ទីរពេទ្យមួយដែលមិនទាន់មានលក្ខណៈជាមន្ទីរពេទ្យនៅឡើយ ព្រោះកន្លែងនោះមានរូបរាងជាផ្ទះមួយវែងដំបូលប្រក់ស្បូវនិងមានបុគ្គលិកពេទ្យស្រីចំនួន៥នាក់ស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ។ ម៉ុន ត្រូវបានបុគ្គលិកពេទ្យព្យួរសេរ៉ូមនិងយកខ្សែអង្រឹងចងជើងនិងចងដៃគាត់ភ្ជាប់នឹងគ្រែកុំឲ្យរើបម្រះ ព្រោះពេលនោះគាត់គ្រុនញាក់ខ្លាំង ។ អង្គការបានចែកថ្នាំអាចម៍ទន្សាយបីគ្រាប់ឲ្យ ម៉ុន លេបពីរពេលក្នុងមួយថ្ងៃ ។ ប៉ុន្តែថ្នាំនេះមិនសូវមានប្រសិទ្ធភាពទេ ទើបអង្គការព្យួរសេរ៉ូមជូនឲ្យគាត់បន្ថែមទៀត ។ ម៉ុន សម្គាល់ឃើញថា អ្នកជំងឺដែលឈឺធ្ងន់អាចបានសម្រាកនៅលើគ្រែ ប៉ុន្តែ នៅពេលបានធូរស្រាលត្រូវសម្រាកនៅលើដីផ្ទាល់វិញ ។ លើសពីនេះ ប្រសិនបើឈឺរយៈពេលយូរក៏ពេទ្យលែងចាក់ថ្នាំឲ្យដែរ ។ នៅទីនេះ អ្នកជំងឺមានច្រើនណាស់មកពីគ្រប់ទីកន្លែង ប៉ុន្តែមិនមានបងប្អូនណាម្នាក់មកសួរសុខទុក្ខទេ ។ *«ប្រសិនបើខ្ញុំស្លាប់ក៏គ្មានអ្នកណាដឹងថាខ្ញុំនៅទីនេះដែរ»* ។ ម៉ុន បានរៀបរាប់ថា បើសិនជាអ្នកណាសុំទៅមើលបងប្អូន ខ្មែរក្រហមនឹងសួរថា *«តើអ្នកឯងធ្វើពេទ្យឬ បើយើងមិនមែនពេទ្យមិនចាំបាច់ទៅមើលទេ ប្រសិនបើទៅមើលមិនជា ត្រូវនៅធ្វើការជាមួយ*

*អង្គការល្អដាស់»* ។

ក្រោយពីសម្រាកព្យាបាលអស់រយៈពេលកន្លះខែ ម៉ុន ក៏បានជាសះស្បើយពីជំងឺនិងអាចត្រឡប់មកចូលកងវិញ ។ មុនពេលចាកចេញ ប្រធានមន្ទីរពេទ្យបានឲ្យលិខិតមួយច្បាប់ រួចប្រាប់ថា ប្រសិនបើមេកងសួរឲ្យហុចបង្ហាញលិខិតនេះទៅ ព្រោះមានចុះហត្ថលេខារបស់ប្រធានពេទ្យស្រាប់ ។ បន្ទាប់មក ប្រធានកងឈ្មោះ រីន បានចាត់តាំងគាត់ឲ្យទៅធ្វើការដូចធម្មតាវិញ ។ ម៉ុន មានការព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជាងមុន ព្រោះគាត់សង្កេតឃើញអ្នកដែលឈឺដូចជាគាត់ ក្រោយពីបញ្ជូនទៅពេទ្យមិនដែលដែលឃើញត្រឡប់មកវិញទេ និងឮតែពាក្យខ្សឹបខ្សៀវគ្នាថាអង្គការយកទៅវាយចោលហើយ ។ ដូច្នេះ ម៉ុន ខិតខំធ្វើការជាងមុន ដើម្បីកុំឲ្យអង្គការស្តីបន្ទោស ទោះបីជាការងារពិបាកយ៉ាងណាក៏ដោយ ។

## ការងារនៅមន្ទីរពេទ្យ៦មករា

ប្រហែលបីខែក្រោយមក អង្គការបានជ្រើសរើស ម៉ុន ឲ្យទៅធ្វើការនៅភ្នំពេញ ។ ពេលនោះ ម៉ុន គិតថា អង្គការច្បាស់ជាយកគាត់ទៅវាយចោលហើយ ព្រោះក្នុងចំណោមនោះមានតែគាត់ម្នាក់ប៉ុណ្ណោះដែលត្រូវបានជ្រើសរើស ។ ម៉ុន បានបដិសេធមិនព្រមទៅទេ ប៉ុន្តែប្រធានកងប្រាប់ថា គាត់ត្រូវតែទៅព្រោះឈ្មោះគាត់ត្រូវអង្គការចាត់តាំងយកទៅ ។ *«ខ្ញុំភ័យមិនដឹងថាគេបញ្ជូនខ្ញុំទៅណាទេ»* ។ ២ថ្ងៃក្រោយមក រថយន្តធំមួយក៏បានមកដឹក ម៉ុន និងមនុស្សប្រហែល ៤០នាក់មកពីកងផ្សេងៗ ភាគច្រើនជាស្ត្រីមានអាយុប្រហែល ១៧-១៨ឆ្នាំមកទម្លាក់នៅផ្សារថ្មី ដែលនៅទីនេះមានអ្នកយាមបីនាក់ ។ យប់នោះ ម៉ុន សម្រាកនៅក្នុងផ្ទះថ្មមួយល្វែង គ្មានភួយខ្នើយនិងបន្ទប់ទេ ប៉ុន្តែបានបែងចែកប្រុសមួយកន្លែងនិងស្រីមួយកន្លែង ។

ស្អែកឡើង អង្គការបញ្ជូនមនុស្សទាំងអស់ឲ្យទៅធ្វើការនៅតាមផ្នែកផ្សេងៗ ។ ម៉ុន បានលួចសួរអ្នកមកជាមួយដែរ ប៉ុន្តែចម្លើយដែល ម៉ុន បានទទួលគឺ *«ចេះតែដើរទៅតាមគេទៅ»* ។ បន្ទាប់មក ម៉ុន ត្រូវបាននារីម្នាក់ហៅឈ្មោះឲ្យទៅមួយកន្លែង ។ ក្រោយពីបានគ្រប់ចំនួន១០នាក់ នារីម្នាក់នោះ ក៏នាំ ម៉ុន ចេញទៅ ។ ពេលនោះ ម៉ុន មានអារម្មណ៍ភ័យខ្លាចក្រែងមិនបានជួបឪពុកនិងប្អូនៗ ។ ម៉ុន ចង់រត់គេចដែរ ប៉ុន្តែគាត់មិនដឹងជារត់គេចទៅកន្លែងណាព្រោះមិនស្គាល់ផ្លូវ ។ មួយម៉ោងក្រោយពីដើរតាមផ្លូវដែលមានសភាពស្ងាត់ជ្រងំនិងតាមផ្ទះគ្មានមនុស្សរស់នៅ ម៉ុន ក៏បានទៅដល់មន្ទីរពេទ្យ៦មករា ។ ម៉ុន មិនដែលរៀនពេទ្យពីមុនទេ ដំបូងគាត់ត្រូវបានចាត់តាំងឲ្យបោកខោអាវរបស់អ្នកជំងឺនៅពេលព្រឹកនិងនៅពេលថ្ងៃរៀនពីរបៀបចាក់ថ្នាំនិងរុំរបួស ។ ក្រោយពីរៀនចេះ ប្រធានមន្ទីរពេទ្យបានចាត់តាំងឲ្យ ម៉ុន ទទួលខុសត្រូវនៅអគារជាន់ទី២និងមើលថែទាំអ្នកជំងឺចំនួន១០០នាក់ ចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង១២យប់ជាមួយពេទ្យបីនាក់ ។ ម៉ុន ឃើញថា អ្នកជំងឺដែលបញ្ជូនមកទីនេះ ភាគច្រើនជាអ្នករបួសដោយសារការប្រយុទ្ធ ព្រោះជារៀងរាល់ល្ងាចគាត់តែងតែឃើញរថយន្តពីរគ្រឿងដឹកអ្នករបួសចូលមកជានិច្ច ។ ប៉ុន្តែ អ្នកត្រូវរបួសនេះជាប្រភេទរបួស


អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត

ស្រាលមិនសូវមានស្លាប់ទេ ព្រោះប្រសិនបើរបួសធ្ងន់នឹងត្រូវបញ្ជូនទៅមន្ទីរពេទ្យ១៧មេសាហើយ ។ ម៉ុន អាចធ្វើការងារនេះបានទោះបីជាគាត់មិនចេះអានអក្សរក៏ដោយ ព្រោះនៅពេលគាត់ចាក់ថ្នាំឲ្យអ្នកជំងឺ គាត់ដឹងថា ថ្នាំប៉េនីស៊ីលីនសម្រាប់ចាក់អ្នករបួស និងថ្នាំបេខូសម្រាប់ចាក់នៅពេលខ្លះឈាម ។ ពេលទំនេរក្រៅពីការងារនេះ ម៉ុន ត្រូវដូតឥដ្ឋការ៉ូថែមទៀត ។ ចំណែកការហូបចុកវិញ ពេលខ្លះហូបបាយ ពេលខ្លះហូបបបរជាមួយសម្ល្លរគ្រឿង ដោយមានអ្នករៀបចំឲ្យទុកមុនជាស្រេចនៅក្នុងផ្ទះធំមួយសម្រាប់អ្នកជំងឺនិងបុគ្គលិកពេទ្យ ។

នៅទីនេះ ម៉ុន ធ្លាប់បានទៅទទួលមេដឹកនាំ ប៉ុល ពត ម្តង ។ ប៉ុន្តែ ម៉ុន មិនបានឃើញមុខផ្ទាល់ទេ ព្រោះគាត់ជិះនៅក្នុងរថយន្តដែលអមដំណើរដោយរថយន្តចំនួនបួនគ្រឿងទៀត ។ នៅពេលនោះ ម៉ុន ត្រូវអង្គការចែកសម្លៀកបំពាក់ថ្មីមួយសម្រាប់ឲ្យស្លៀកដើម្បីទទួលស្វាគមន៍និងទះដៃអបអរសាទរនៅពេលរថយន្តមេដឹកនាំបើកមកដល់ ។

## ត្រឡប់មកលំនៅឋាន

ប្រហែលកន្លះខែក្រោយបន្ទាប់ពីទទួលដំណឹងថាកងទ័ពវៀតណាមចូលមករំដោះ ប្រធានមន្ទីរពេទ្យបានបញ្ជាឲ្យនាំអ្នកជំងឺចេញ ។ ព្រោះលេចឮដំណឹងថា អ្នកដែលធ្វើការបម្រើខ្មែរក្រហមនៅពេលត្រឡប់ទៅវិញយួននឹងចោះត្រចៀក ម៉ុន ក៏សម្រេចចិត្តរត់ទៅជាមួយអ្នកជំងឺដែរ ដោយជិះរថភ្លើងទៅស្រុកបវេល ខេត្តបាត់ដំបង ។ ម៉ុន បន្តរស់នៅទីនោះអស់រយៈពេលបីខែដោយដើរស្នើបាយអ្នកភូមិហូប ។ ក្រោយមកដោយសារគិតឃើញថាមិនអាចរស់នៅក្នុងជីវភាពបែបនេះបាន ម៉ុន ក៏សម្រេចចិត្តត្រឡប់មករស់នៅស្រុកកំណើតវិញ ។ ម៉ុន បានឃើញមនុស្សជាច្រើនស្លាប់នៅតាមផ្លូវ ចំណែកភូមិដែលគាត់ធ្លាប់រស់នៅគឺមានលក្ខណៈស្ងាត់ជ្រងំនិងផ្ទះត្រូវបានរុះរើអស់ ។ ម៉ុន បានរស់នៅជួបជុំជាមួយឪពុកនិងប្អូនៗនៅផ្ទះកំណើតយ៉ាងសុខដុម មួយខែក្រោយមក ម៉ុន ក៏បានរៀបការជាមួយនឹងប្តីរបស់គាត់ ហើយសព្វថ្ងៃគាត់ប្រកបមុខរបរធ្វើស្រែដើម្បីចិញ្ចឹមកូនស្រី១និងប្រុស៤ ។ **គាត លក្ខិណា**



**អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិតនៅខេត្តកំពង់ធំ**

# គុកសង់រំលួកនូវការឈឺចាប់

សព្វថ្ងៃ បាន សំបូរ មានអាយុ៥៨ឆ្នាំ និងមានស្រុកកំណើតនៅភូមិមាត់បឹង ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ សំបូរ ជាស្ត្រីជីអភ័ព្វម្នាក់ដែលត្រូវបានខ្មែរក្រហមចាប់ប្តីនិងប្អូនប្រុសបង្កើតយកទៅឃុំឃាំងនិងសម្លាប់ចោលនៅមន្ទីរសន្តិសុខសង់ (ទន្លេបាទី) ។ សំបូរ មានម្តាយឈ្មោះ ទូច ស្លាប់នៅក្នុងឆ្នាំ១៩៧២ និងឪពុកឈ្មោះ បាន ស្លាប់នៅក្នុងឆ្នាំ១៩៧៤ ។ សំបូរ មានកូនបីនាក់ ។

នៅឆ្នាំ១៩៧៤ ភូមិកំណើតដែល សំបូរ រស់នៅបានក្លាយជាតំបន់ប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហមនិងទាហាន លន់ នល់ ។ ស្ថានភាពនេះបានធ្វើឲ្យ សំបូរ និងប្តីពិភាក្សាគ្នាផ្លាស់ទីលំនៅទៅរកកន្លែងសុវត្ថិភាពមួយនៅឯជាយទីក្រុងភ្នំពេញម្តុំរោងចក្រកែវ ខាងលិចស្ទឹងមានជ័យដើម្បីប្រកបរបរចិញ្ចឹមជីវិតដូចជាអូសអួននិងបេះស្លឹកឈូកលក់យកលុយទិញអង្ករ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានបាញ់កាំភ្លើងជាច្រើនគ្រាប់ឡើងទៅលើគំរាមប្រជាជនចេញឲ្យបានឆាប់ ។ ស្នូរគ្រាប់កាំភ្លើងធុរំពងស្ទើរគ្រប់ទីកន្លែងទាំងអស់នៅក្នុងទីក្រុងភ្នំពេញ ប្រជាជនចាកចេញពីផ្ទះយ៉ាងតក់ក្រហល់ដោយទុករបស់របរឲ្យនៅរាយប៉ាយពាសពេញផ្ទះ ។ សំបូរ និងក្រុមគ្រួសារក៏ស្ថិតនៅក្នុងចំណោមប្រជាជនដែលត្រូវបានជម្លៀសនោះដែរ ដោយខ្មែរក្រហមបានប្រាប់ថា «អ្នកណាមានស្រុកកំណើតនៅឯណាត្រូវត្រឡប់ទៅទីនោះវិញ នៅពេលណារៀបចំទីក្រុងរួចទើបអង្គការអនុញ្ញាតឲ្យត្រឡប់មកផ្ទះសម្បែងរៀងៗខ្លួនវិញ» ។ សំបូរ បានត្រឹមតែស្ពាយកាបូបសម្រាប់ដាក់ខោអាវពីខាងក្រោយខ្នងដែលធ្វើអំពីកៅស៊ូនិងឱបកូនតូចៗទាំងពីរ ចំណែកប្តីរបស់គាត់រែកសែ្រកដាក់សម្ភារៈប្រើប្រាស់មួយចំនួនដូចជា បង្កុចខោអាវនិងអង្ករ ។ នៅតាមផ្លូវ សំបូរ បានឃើញហេតុការណ៍ជាច្រើនដូចជាកងឈ្លបខ្មែរក្រហមធ្វើការឆែកឆេរយករបស់របរពីប្រជាជននៅតាមផ្លូវ ចាប់ចងមនុស្សជាជួរ និងសាកសពហើមស្អុយរលួយ ។


បាន សំបូរ

រយៈពេលពីរយប់ពីរថ្ងៃ គ្រួសារ សំបូរ ក៏ដូចជាគ្រួសារដទៃទៀតក៏បានមកដល់ស្រុកកំណើត ។ អង្គការបានចែកអង្ករសម្រាប់ទុកហូបជាឯកជនដែលតម្រូវទៅតាមសមាជិកតិចឬច្រើននៃគ្រួសារនីមួយៗក្នុងម្នាក់ទទួលបានអង្ករមួយកំប៉ុងក្នុងមួយថ្ងៃ ។ ក្រោយមក ដោយសារអង្ករត្រូវកាត់បន្ថយត្រឹមតែកន្លះកំប៉ុងក្នុងមួយគ្រួសារ សំបូរ បានព្យាយាមដើរបេះទងដំឡូងនិងក្រអៅឈូកយកមកលាយបន្ថែមជាមួយបបរ ។ នៅឆ្នាំ១៩៧៦ អង្គការតម្រូវឲ្យ សំបូរ ទៅហូបបាយនៅក្នុងរោងបាយរួមរបស់សហករណ៍វិញ ។ ចាប់តាំងពីពេលនោះមក សំបូរ ត្រូវហូបបបរពីរវែកដែលអង្គការបានកំណត់ឲ្យ ។ កូនតូចៗរបស់ សំបូរ ត្រូវបានអង្គការយកទៅឲ្យក្រុមមនុស្សចាស់មើលថែរក្សា ប្តីត្រូវចាត់តាំងនៅក្នុងកងភ្ជួរ ចំណែកគាត់ក្នុងកងធ្វើជី ។ ពីមួយថ្ងៃទៅមួយថ្ងៃ សំបូរ ត្រូវដើរកាប់មែកឈើ និងកាប់ដើមទន្រ្ទានខែត្រយកមកចិញ្ច្រាំធ្វើជី ។

មិនយូរប៉ុន្មាន កូនទាំងពីររបស់ សំបូរ ដែលកំពុងតែស្ថិតក្នុង

ដំណាក់កាលមួយត្រូវការជាចាំបាច់នូវការហូបចុកគ្រប់គ្រាន់ ការស្នាក់នៅសមរម្យ ការថែរក្សាការពារនិងការយកចិត្តទុកដាក់ឲ្យបានជិតដល់ពីឪពុកម្តាយនោះ បែរជាក្លាយជាកុមារដ៏អភ័ព្វព្រោះត្រូវស្លាប់ដោយសារកង្វះអាហារនិងថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺ ។ សំបូរ បានរៀបរាប់ថា «គាត់មានការសោកស្តាយយ៉ាងខ្លាំងដែលខ្លួនជាម្តាយ ហើយពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបីបាច់ថែរក្សាផ្គត់ផ្គង់ចំណីអាហារនិងផ្តល់ភាពកក់ក្តៅដល់កូនបាននៅក្នុងជំនាន់នោះ» ។

នៅឆ្នាំ១៩៧៧ ក្រោយពីឆ្លងទន្លេបានរយៈពេលបីថ្ងៃ សំបូរ មានអារម្មណ៍រន្ធត់ និងតក់ស្លុតយ៉ាងខ្លាំងពេលដែលគាត់បានទទួលដំណឹងថា ប្តីរបស់គាត់ជាប្រជាជនថ្មីដែលកំពុងតែភ្ជួរស្រែនៅការដ្ឋានត្រូវបានអង្គការឲ្យផ្លាស់ឲ្យទៅកាប់ដើមឫស្សីនៅគុកសង់ (ទន្លេបាទី) វិញ ដែលគាត់ដឹងយ៉ាងច្បាស់ថាគឺជាកន្លែងសម្រាប់ឃុំឃាំងមនុស្សដ៏ធំមួយ ។ នៅពេលជាមួយគ្នានោះ សំបូរ បន្តថា ប្អូនប្រុសបង្កើតរបស់គាត់ម្នាក់ឈ្មោះ សោម ក៏ត្រូវអង្គការបញ្ជូនទៅទីនោះដែរ ដោយមិនបានដឹងពីមូលហេតុច្បាស់លាស់ ។

មុនពេលចេញដំណើរទៅ អង្គការបានឲ្យប្តីរបស់គាត់មកផ្ទះដើម្បីយកអីវ៉ាន់ ។ ពេលនោះប្តីគាត់លួចខ្សឹបប្រាប់ថា «អង្គការផ្លាស់ទៅគឺយកទៅសម្លាប់ហើយ» កុំឲ្យគាត់យំ ប្រសិនបើអង្គការឃើញនឹងយកទៅដែរហើយ ។ និយាយចប់ កងឈ្លបខ្មែរក្រហមបានបណ្តើរប្តីរបស់ សំបូរ កាត់តាមវត្តស្រួលដែលមានទីតាំងស្ថិតនៅភូមិត្រស់ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល (ជំនាន់ខ្មែរក្រហមប្រើសម្រាប់ដាក់កងមេម៉ាយ) ។ សំបូរ មិនហ៊ានបង្ហូរទឹកភ្នែកឲ្យនរណាម្នាក់ឃើញឡើយបានត្រឹមតែបញ្ចេញទឹកមុខស្រងូតស្រងាត់ខ្លោចផ្សារចិត្តនិងអួលណែនក្នុងទ្រូងប៉ុណ្ណោះ ។ ដោយមិនអស់អាល័យពីប្តី សំបូរ ក៏បានលួចរត់ទៅតាមមើលប្តីដែលកំពុងកាប់ឆ្ការគុម្ពឫស្សីនៅខាងកើតមន្ទីរសន្តិសុខសង់និងពួនសម្ងំនៅក្នុងគុម្ពឫស្សីដើម្បីបាននិយាយឆ្លើយឆ្លងជាមួយ ។ ដោយសារតែមានការអង្វរករពីប្តីខ្លាំងពេក សំបូរ ក៏សម្រេចចិត្តត្រឡប់មកផ្ទះវិញទាំងមិនស្ងប់ចិត្តនិងមានទឹកភ្នែកហូររហាម ។ សំបូរ មិនអាចដើរមកផ្ទះដូចធម្មតាបានទេ ក្រោយពីនិយាយជាមួយប្តីរួច ព្រោះតែគាត់មានអារម្មណ៍តក់ស្លុត ដៃនិងជើងមិនអាចបញ្ឈរបាននិងដើរដួលជាច្រើនដង ។ មកដល់ផ្ទះ សំបូរ មិនហ៊ានយំឲ្យឮទេ ដោយយកក្រមាមកគ្របមុខហើយលួចយំខ្សឹបៗតែម្នាក់ឯង ។ ចាប់តាំងពីពេលនោះមក សំបូរ ត្រូវបានកងឈ្លបខ្មែរក្រហមលួចតាមដានគាត់ជារៀងរាល់ថ្ងៃ ។

សំបូរ មានការប៉ះទង្គិចទាំងផ្លូវកាយនិងផ្លូវចិត្តយ៉ាងខ្លាំងបន្ទាប់ពីមានព្រឹត្តិការណ៍នេះ ។ ម្យ៉ាងវិញទៀត សំបូរ ទើបតែឆ្លងទន្លេរួចបណ្តាលឲ្យទាស់រីងរៃ រាងកាយប្រែទៅជាស្គមនិងចាប់ផ្តើមដកដង្ហើមថប់ៗសន្ធប់ពីរដងក្នុងមួយថ្ងៃ ។ ឃើញដូច្នេះ ប្រធានក្រុមរបស់ សំបូរ គិតថា គាត់ប្រាកដជាមានជំងឺសតិអារម្មណ៍ ក៏ចេញបញ្ជាឲ្យកោះហៅគាត់ទៅអប់រំកសាងជាច្រើនលើក ។ បន្ទាប់មក សំបូរ ត្រូវអង្គការផ្លាស់ឲ្យទៅជីកប្រឡាយនិងអូសកំប្លោកនៅសហករណ៍ភូមិត្រពាំងស្វា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានទីតាំងនៅជិតមន្ទីរសន្តិសុខសង់ ។ នៅទីនោះ សំបូរ បានឃើញឆ្មាំគុកធ្វើបាបអ្នកទោសជាញឹកញាប់ដែលធ្វើឲ្យគាត់កាន់តែនឹកឃើញនិងមិនអាចបំភ្លេចប្តីរបស់គាត់បាន ។

នៅពេលកងទ័ពវៀតណាមចូលធ្វើអន្តរាគមន៍ក្នុងឆ្នាំ១៩៧៩ សំបូរ និងកូនបានរត់ភៀសខ្លួនមករស់នៅភូមិទួលចំបក់ខាងកើតសៀមរាបកន្ទួត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល វិញ ។ បទពិសោធន៍និងភាពគ្រាំគ្រាដែលបន្សល់ទុកពីរបបនោះ បានធ្វើឲ្យសំបូរ ប្រឈមមុខនឹងបញ្ហាដូចជា ថប់ៗដង្ហើម អួលណែនដើមទ្រូងនៅពេលដែលនឹកឃើញដល់រឿងពីអតីតកាល ឧស្សាហ៍សុបិនឃើញរឿងអាក្រក់ៗ និងមិនអាចធ្វើការងារបានច្រើនដូចជាមនុស្សធម្មតា ។ សំបូរ បន្ថែមថា គាត់ពិតជាមិនចង់រំឭកដល់រឿងអតីតកាលទេ ព្រោះរៀងរាល់ពេលដែលគាត់ចាប់ផ្តើមនិយាយធ្វើឲ្យគាត់អួលណែនដើមទ្រូងនិងស្រក់ទឹកភ្នែក ។ លើសពីនេះ ការខ្លាចរអានិងភាពបាក់ស្បាតដោយសារតែឃើញកងឈ្លបដែលបណ្តើរប្តីរបស់គាត់យកទៅកាលពីជំនាន់នោះកំពុងតែរស់នៅក្នុងភូមិជាមួយគាត់ សព្វថ្ងៃធ្វើឲ្យគាត់មិនហ៊ាននិយាយអ្វីច្រើនទេ ។ ចុងក្រោយ សំបូរ នៅមានបំណងប្រាថ្នាតែមួយគត់ គឺចង់បានយុត្តិធម៌ជូនប្តីនិងប្អូនប្រុសដែលត្រូវបានខ្មែរក្រហមសម្លាប់ទាំងគ្មានកំហុស ។

**គង់ សុភគឿន**

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

***(តពីលេខមុន)***

*នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្លើយតបនឹងលិខិតរបស់លោក អាណាន់ កាលពីថ្ងៃទី២៥ ហើយស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការកាត់ទោសឧក្រិដ្ឋកម្មដែលមានតាំងពីឆ្នាំ១៩៧០ ។*

*នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បានយល់ស្របនឹងសំណើរបស់សមាជិកព្រឹទ្ធសភាអាមេរិក លោក ចន ខេរី ។ នៅក្នុងសំណើនោះ ក្រុមចៅក្រមត្រូវមានចៅក្រមកម្ពុជា៣រូប និងចៅក្រមបរទេស២រូប ។ ចំពោះការដោះស្រាយជម្លោះក្នុងការចោទប្រកាន់ត្រូវតែមានចៅក្រម៤រូបយល់ស្របគ្នាដើម្បីរក្សាដំណើរការកាត់ក្តីនេះ ។*

*នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០០ លោក អាណាន់ បានសរសេរលិខិតមួយផ្ញើជូននាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីចង់បានការអះអាងបញ្ជាក់បន្ថែមដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមជាមួយនឹងសមាជិកព្រឹទ្ធសភា ចន ខេរី ដែលសំណើបានធ្វើឡើងនៅក្នុងលិខិតរបស់អគ្គលេខាធិការនៅថ្ងៃទី១៩ ខែមេសា ពាក់ព័ន្ធនឹងយន្តការដោះស្រាយភាពមិនយល់ស្របគ្នារវាងសហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញា ហើយសវនាការអង្គជំនុំជម្រះនេះអាចកាត់សេចក្តីត្រឹមឧក្រិដ្ឋកម្មដែលកើតឡើងតែក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ប៉ុណ្ណោះ ។*

*នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បានផ្ញើលិខិតមួយទៅលោក កូហ្វី អាណាន់ ដើម្បីបង្ហាញពីការគាំទ្ររបស់ខ្លួនចំពោះយុត្តិសាស្ត្រសម្របសម្រួលដែលចរចាដោយ ខេរី នៅខែមេសា ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។*

*នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០០ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា បញ្ចប់សេចក្តីសង្ខេបនៃច្បាប់ព្រាងសម្រាប់អង្គជំនុំជម្រះ ។ អង្គជំនុំជម្រះនឹងប្រព្រឹត្តទៅនៅក្នុងតុលាការកម្ពុជាដែលមានការចូលរួមពីព្រះរាជអាជ្ញានិងចៅក្រមអន្តរជាតិ ។*

*នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០០ ហាន់ កូរ៉ែល បង្ហាញពីអនុស្សរណៈព្រាងនៃការយល់ដឹងដែលនឹងផ្តល់ការសហការរវាងអង្គការសហប្រជាជាតិនិងកម្ពុជាស្តីអំពីការបង្កើតនិងប្រតិបត្តិការរបស់អង្គជំនុំជម្រះ ។ អនុស្សរណៈត្រូវបានចុះហត្ថលេខាដោយអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបន្ទាប់ពីសភាកម្ពុជាអនុម័តច្បាប់ ។ លោក កូរ៉ែល និង លោក ឱម យិនទៀង ទីប្រឹក្សាជាន់ខ្ពស់របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងនៅក្នុងសាលចតុមុខអំពីលទ្ធភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះមុនពេលដែលក្រុមប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិចាកចេញពីកម្ពុជា ។*

*នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០០ សម្តេច ហ៊ុន សែន បង្ហាញថា អតីតរដ្ឋមន្ត្រីក្រសួងការបរទេសរបស់ខ្មែរក្រហម អៀង សារី មិនគួរយកទៅកាត់ទោសអំពីបទប្រល័យពូជសាសន៍ទេ ។ នៅឆ្នាំ១៩៧៩ អៀង សារី និង ប៉ុល ពត ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខ ប៉ុន្តែ អៀង សារី ទទួលបានការលើកលែងទោសពីសម្តេច សីហនុ បន្ទាប់ពីបានចុះចូលជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៦ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ថែមទៀតថា វាអាស្រ័យទៅលើតុលាការនិងសភាជាតិចំពោះការពិចារណាទៅលើច្បាប់ព្រាងសម្រាប់អង្គជំនុំជម្រះថាតើគួរធ្វើយ៉ាងណាចំពោះអង្គជំនុំជម្រះវិសាមញ្ញ ។*

*នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០០ ព្រះអង្គម្ចាស់ រណឫទ្ធិ ប្រាប់អ្នកសារព័ត៌មានថា សម្តេច សីហនុ បានបួងសួងឲ្យតុលាការពន្យារពេលពីព្រោះទ្រង់កំពុងតែព្រួយបារម្ភអំពីសន្តិភាពនិងស្ថិរភាពនៅក្នុងប្រទេស ។ ព្រះអង្គម្ចាស់បានបន្ថែមទៀតថា សេចក្តីព្រាងច្បាប់របស់តុលាការមិនទាន់មានការស្រុះស្រួលគ្នានៅឡើយទេនៅឆ្នាំនេះ ពីព្រោះរដ្ឋាភិបាលព្រួយបារម្ភអំពីទឹកជំនន់ថ្មីៗនេះដាង ។*

នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០០ នាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្សព្វផ្សាយតាមវិទ្យុជាតិថា គាត់ព្យាយាមជំរុញឲ្យច្បាប់របស់តុលាការមានដំណើរការទៅមុខៗ គាត់អះអាងថា «យើងត្រូវការឲ្យមានតុលាការនៅពេលឆាប់ៗនេះ បើមិនដូច្នេះភាពព្រៃផ្សៃរបស់ខ្មែរក្រហមនៅតែដក់ជាប់ក្នុងចិត្តយើង» ។

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០០ មានប្រទេសចំនួន១១ រួមមានប្រទេសជប៉ុន អូស្ត្រាលី កាណាដា និងញូហ្សីលេន ស្នើសុំឲ្យគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជាបង្កើតច្បាប់សម្រាប់តុលាការដើម្បីកាត់ទោសខ្មែរក្រហម ។

នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០០ យោងទៅតាមរបាយការណ៍របស់កាសែតបានឲ្យដឹងថា សមាជិកព្រឹទ្ធសភាលោក ចន ខេរី ធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាប្រហែលជាអាចជំរុញឲ្យការប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបង្កើតអង្គជំនុំជម្រះបានសម្រេច ។ លោក ខេរី សន្យាចំពោះមុខ លោក សុខ អាន នាយករដ្ឋមន្ត្រី ហ៊ុន សែន និងព្រះអង្គម្ចាស់ រណឫទ្ធិ ថា ដំណើរការរបស់អង្គជំនុំជម្រះនឹងដើរទៅមុខតាមការរៀបចំដែលអាចជំរុញឲ្យសភាជាតិធ្វើការសម្រេចច្បាប់នៅខែធ្នូ ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ គណៈកម្មាធិការគាត់តែងច្បាប់របស់សភាកម្ពុជានិងក្រុមការងាររបស់រដ្ឋាភិបាលធ្វើការសម្រេចសេចក្តីព្រាងច្បាប់របស់តុលាការ ។ ដូច្នេះ សភាជាតិអាចធ្វើការពិភាក្សាទៅលើច្បាប់នេះ ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០០ នៅក្នុងបទសម្ភាសន៍ជាមួយប្រទេសជប៉ុន នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ម្តងទៀតថា ការកាត់ទោស អៀង សារី ប្រហែលជាអាចបង្កើតបញ្ហាចំពោះប្រទេសកម្ពុជា ។ ប៉ុន្តែ លោកបញ្ជាក់ទៀតថា «ការកាត់ទោស ខៀវ សំផន និង នួន ជា ប្រហែលជាមិនមានបញ្ហាអ្វីទេ» ។

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០០ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ UNGA A/RES/55/95 កថាខណ្ឌទី១៨ ៖ ទទួលស្វាគមន៍ចំពោះសេចក្តីសម្រេចដ៏ជោគជ័យអំពីកិច្ចពិភាក្សារវាងរដ្ឋាភិបាលកម្ពុជានិងអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ធានាចំពោះរដ្ឋាភិបាល ដោយជួយសម្រួលសេចក្តីសម្រេចដែលចាំបាច់ចំពោះដំណើរការគាត់តែងច្បាប់ឲ្យបានឆាប់រហ័សដើម្បីយកមេដឹកនាំខ្មែរក្រហមមកទទួលខុសត្រូវ យោងទៅតាមប្រព័ន្ធយុត្តិធម៌ ភាពមិនលម្អៀង ដែលមានបទដ្ឋានអន្តរជាតិ សុភនិច្ឆ័យនិងដំណើរការនីតិវិធីស្របច្បាប់ ហើយជំរុញឲ្យរដ្ឋាភិបាលបន្តសហការជាមួយអង្គការសហប្រជាជាតិចំពោះបញ្ហានេះ ព្រមទាំងស្វាគមន៍ការខំប្រឹងប្រែងរបស់អគ្គលេខាធិការដ្ឋាននិងសហគមន៍អន្តរជាតិក្នុងការជួយរដ្ឋាភិបាលមកដល់ទីបញ្ចប់នេះ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០ អៀង សារី ប្រាប់សារព័ត៌មានថា គាត់បានធ្វើវិភាគទានកសាងជាតិនិងផ្សះផ្សាជាតិតាំងពីគាត់ចុះចូលជាមួយរដ្ឋាភិបាលនៅខែកញ្ញា ឆ្នាំ១៩៩៦ ។ គាត់បានបន្ថែមទៀតថា គាត់គ្រាន់តែទទួលបន្ទុកកិច្ចការក្រសួងការបរទេសនៅអំឡុងកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ មិនមែនអំពើប្រល័យពូជសាសន៍នោះទេ ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ សភាជាតិរបស់កម្ពុជាទទួលបានសេចក្តីសម្រេចព្រាងច្បាប់របស់តុលាការពីក្រុមការងាររបស់រដ្ឋាភិបាល ។ សមាជិកសភាចំនួន៩៨រូបក្នុងចំនួន១២២រូបគាំទ្រជំពូកទីមួយនៃច្បាប់របស់អង្គជំនុំជម្រះ ។ ច្បាប់នេះត្រូវបានរំពឹងទុកថានឹងត្រូវសម្រេចដោយពេញលេញនៅដើមខែមករា ។

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ សភាជាតិរបស់កម្ពុជាយល់ស្របនឹងច្បាប់ព្រាងរបស់អង្គជំនុំជម្រះក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០០១ សហរដ្ឋអាមេរិកស្វាគមន៍សភាជាតិរបស់កម្ពុជាក្នុងការបង្កើតមធ្យោបាយស៊ើបអង្កេតនិងកាត់ទោសមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មនៅអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ លោក ហាន់ កូរ៉ែល ផ្ញើសំបុត្រមួយទៅឲ្យរដ្ឋាភិបាលកម្ពុជាដើម្បីបង្ហាញពីភាពមិនយល់ស្របអំពីសេចក្តីព្រាងច្បាប់ ។ អង្គការសហប្រជាជាតិស្នើសុំឲ្យ

មានការផ្លាស់ប្តូរសេចក្តីព្រាងច្បាប់ប្រហែល១៨មាត្រា ។ លោក កូរ៉ែល ក៏បានអះអាងថា សេចក្តីព្រាងច្បាប់ខ្វះខាតច្បាប់ត្រៀម ដើម្បីធានាឲ្យមានការត្រួតពិនិត្យគ្រប់គ្រាន់ពីអង្គការសហប្រជាជាតិក្នុងការរ៉ាប់រងឲ្យព្រះរាជអាជ្ញាមានអំណាចចោទប្រកាន់ជនសង្ស័យដែលមានការលើកលែងទោស ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅភ្នំពេញផ្ញើឯកសារបកប្រែច្បាប់ជាលក្ខណៈមិនផ្លូវការដែលមានការយល់ស្របពីសភាជាតិនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ។ នៅក្នុងលិខិតថ្ងៃទី៩ ខែមករា ឆ្នាំ២០០១ លោក កូរ៉ែល បានបង្ហាញពីការព្រួយបារម្ភអំពីច្បាប់ត្រៀមនេះ ។

នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ ព្រឹទ្ធសភាកម្ពុជាសុទ្ធតែយល់ស្របនឹងសេចក្តីព្រាងច្បាប់របស់អង្គជំនុំជម្រះ ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីខែមេសា ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៩ បានផ្ញើសារមួយថា គាត់នឹងប្រឈមមុខចំពោះអង្គជំនុំជម្រះប្រសិនបើមានករណីចាំបាច់ ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០១ លោក កូរ៉ែល ស្នើសុំឲ្យមានការបកប្រែច្បាប់ដែលមានការយល់ស្របគ្នាជាលក្ខណៈផ្លូវការ ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញយល់ស្របនឹងសេចក្តីព្រាងច្បាប់ ។ យ៉ង់ សែម ដែលជាសមាជិករបស់ក្រុមប្រឹក្សាសម្រេចថាច្បាប់ «មានលក្ខណៈផ្លូវការនៅក្រោមច្បាប់រដ្ឋធម្មនុញ្ញ» ។ យ៉ាងណាមិញ ក្រុមប្រឹក្សាសម្គាល់ឃើញភាពមិនយល់ស្របគ្នាខាងបច្ចេកទេសនៅក្នុងវិធានទី៣នៃសេចក្តីព្រាងច្បាប់ដែលស្នើឲ្យមានការកាត់ទោសប្រហារជីវិតចំពោះទោសធ្ងន់បំផុត ។ ដោយសារតែរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នបានលុបបំបាត់ការកាត់ទោសប្រហារជីវិត ដូច្នេះក្រុមប្រឹក្សាប្រកាសថានឹងផ្ញើសេចក្តីព្រាងច្បាប់ទៅឲ្យសភាដើម្បីធ្វើវិសោធនកម្ម ។

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា សេចក្តីព្រាងច្បាប់ត្រូវតែបញ្ជូនទៅដំណាក់កាលព្រាងដំបូង ហើយធ្វើកិច្ចពិភាក្សាដោយសភាម្តងទៀតអំពីភាពមិនយល់ស្របគ្នាខាងបច្ចេកទេសដែលរកឃើញដោយក្រុមប្រឹក្សាធម្មនុញ្ញអំពីកំហុសឆ្គងខាងបច្ចេកទេសនៅក្នុងការតាក់តែងច្បាប់ដែលពាក់ព័ន្ធនឹងការកាត់ទោសប្រហារជីវិតនៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ តាមការពិត ច្បាប់ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យលើកទីពីរពីសភាជាតិដែលនេះធ្វើឲ្យអង្គការសហប្រជាជាតិមានភាពអស់សង្ឃឹម ។ អ្នកនាំពាក្យរបស់អង្គការសហប្រជាជាតិប្រាប់អ្នកសារព័ត៌មាននៅទីក្រុងញូវយ៉កថា «វាហាក់ដូចជាយើងកំពុងតែចាប់ផ្តើមពីក្រោមឡើងទៅម្តងទៀត» ។

នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា គាត់ចង់រក្សាទុកអដ្ឋិធាតុរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមដើម្បីជាភស្តុតាងសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនៅតុលាការដែលបានគ្រោងទុក ដែលវាសនានៃតុលាការនេះត្រូវបានសម្រេចដោយប្រជាជន ។ នាយករដ្ឋមន្ត្រីមានប្រសាសន៍ទៀតថា គណៈរដ្ឋមន្ត្រីត្រូវតែពិភាក្សាអំពីច្បាប់នេះជាលើកទីពីរមុនខែមិថុនា បន្ទាប់ពីបញ្ជូនទៅឲ្យសភាជាតិ ។

គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិយល់ស្របនឹងដំណោះស្រាយរបស់ប្រទេសជប៉ុនដែលជំរុញឲ្យរដ្ឋាភិបាលកម្ពុជាបង្កើតអង្គជំនុំជម្រះឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន បដិសេធការចោទប្រកាន់របស់អ្នកសារព័ត៌មានដែលថាប្រទេសចិនកំពុងតែដាក់សម្ពាធទៅលើរដ្ឋាភិបាលកម្ពុជាអំពីបញ្ហាអង្គជំនុំជម្រះ ។ លោកនាយករដ្ឋមន្ត្រីមានប្រសាសន៍ថា «អ្នកដែលដាក់សម្ពាធមកលើខ្ញុំគឺអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ ប្រធានមន្ត្រីច្បាប់របស់អង្គការសហប្រជាជាតិ លោក ហាន់ កូរ៉ែល និង សមាជិកព្រឹទ្ធសភារបស់អាមេរិក លោក ចន ខេរី ។

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០១ លោក កូហ្វី អាណាន់ បន្តឲ្យរដ្ឋាភិបាលកម្ពុជាធ្វើច្បាប់សម្រាប់អង្គជំនុំជម្រះឲ្យបានលឿន ។ លោក អាណាន់ បានប្រាប់អ្នកសារព័ត៌មានថាគាត់មិនបានឮដំណឹងអ្វីពីរដ្ឋាភិបាលកម្ពុជាអំពីអង្គជំនុំជម្រះអស់រយៈពេល៦ខែមកហើយ ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន សន្យាថានឹងឲ្យសច្ចាប័នច្បាប់រួមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ប្រសិនបើមានការយល់ស្របដោយសភា ប្រទេសកម្ពុជាអាចជាប្រទេសដំបូងគេនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលបានឲ្យសច្ចាប័នច្បាប់ ។ នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា «ប្រទេសកម្ពុជានឹងទទួលផលប្រយោជន៍ច្រើនជាងគេដោយសារបទពិសោធន៍ដែលគ្មានអ្វីប្រៀបផ្ទឹមនៃអំពើប្រល័យពូជសាសន៍ថ្មីៗ នេះ» ។

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០១ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ ស្នើឲ្យសាកលវិទ្យាល័យធម្មសាត្រប្រគល់កំណត់ហេតុ នួន ជា ដែលគាត់ទទួលបានអាហារូបករណ៍ដើម្បីរៀនច្បាប់នៅទសវត្សរ៍ឆ្នាំ១៩៤០នៅទីនោះ ហើយបន្ទាប់មកគាត់ធ្វើការឲ្យក្រសួងការបរទេសថៃបានមួយរយៈពេលវែងដោយនិយាយថាកំណត់ហេតុនេះប្រហែលជាមានផ្ទុកនូវភ័ស្តុតាងសំខាន់សម្រាប់តុលាការខ្មែរក្រហម ។

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន លោក កូរ៉ែល ស្នើឲ្យមានការបកប្រែច្បាប់ជាផ្លូវការនិងឲ្យមានភាពរលូននៃឧបករណ៍បកប្រែទាំងពីរនេះ ។

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់ដំណឹងឲ្យម្ចាស់ជំនួយអន្តរជាតិនៅពេលជួបប្រជុំពិគ្រោះយោបល់រយៈពេលពីរថ្ងៃដែលប្រារព្ធឡើងនៅតូក្យូ អំពីប្រទេសកម្ពុជាដែលមានគម្រោងអនុម័តច្បាប់តុលាការនៅពេលឆាប់ៗនេះ ។ នាយករដ្ឋមន្ត្រីនិយាយថា លោកនឹងគោរពតាមយុត្តិធម៌ហើយតុលាការខ្មែរក្រហមនឹងចាប់ផ្តើមនៅចុងឆ្នាំនេះ ។

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០១ នួន ជា អតីតខ្មែរក្រហមដែលជាអ្នកមនោគមន៍វិជ្ជានិងជាបងធំទីពីរនិយាយថា គាត់នឹងប្រឈមមុខចំពោះតុលាការព្រមទាំងច្បាប់ ។ យ៉ាងណាមិញ នួន ជា បដិសេធរហូតថា គាត់មិនបានដឹងអំពីការសម្លាប់ទេបន្ទាប់ពីការចាកចេញពីរដ្ឋាភិបាលនៅខែធ្នូ ឆ្នាំ១៩៩៨ ។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ រដ្ឋាភិបាលកម្ពុជាកែប្រែសេចក្តីព្រាងច្បាប់របស់តុលាការដោយប្តូរទោសប្រហារជីវិតឲ្យទៅជាជាប់ពន្ធនាគារអស់មួយជីវិតវិញចំពោះទោសធ្ងន់ធ្ងរបំផុត ។ នាយក រដ្ឋមន្ត្រី ហ៊ុន សែន ថែមទាំងបានបង្ហាញពីសុទិដ្ឋិនិយមថា អង្គជំនុំជម្រះនឹងដំណើរការនៅចុងឆ្នាំនេះ ។

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០១ សមាជិកគណៈកម្មការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិនៃអ្នកតំណាងសិទ្ធិមនុស្សពិសេសប្រចាំប្រទេសកម្ពុជា លោក ភីតធឺ ឡឺប្រឺត្យ និយាយថា អៀង សារី គួរតែត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មពីឆ្នាំ ១៩៧៥-១៩៧៩ ហើយប្រសិនបើមានតែការកាត់ទោស តា ម៉ុក និង ឌុច នោះវានឹងមិនមានប្រសិទ្ធភាពទេ ។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ ដើម្បីឆ្លើយតបនឹងសេចក្តីថ្លែងការណ៍ព័ត៌មានថ្មីៗដែលថាអង្គជំនុំជម្រះអាចនឹងត្រូវបានបង្កើតឡើងនៅឆ្នាំនេះ អង្គការសហប្រជាជាតិបានចេញសេចក្តីប្រកាសព័ត៌មានថា គ្មានការទទួលស្គាល់អង្គជំនុំជម្រះជាលក្ខណៈអន្តរជាតិទេ ដរាបណាអនុស្សរណៈយល់ស្របគ្នារវាងអង្គការសហប្រជាជាតិនិងកម្ពុជាមិនទាន់ត្រូវបានចុះហត្ថលេខានិងឲ្យសច្ចាប័ន ។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ សម្តេច សីហនុ ធានាចំពោះ ភីតធឺ ឡឺប្រឺត្យ ថា ព្រះអង្គនឹងចុះហត្ថលេខាទទួលស្គាល់ច្បាប់ដើម្បីបង្កើតតុលាការដែលមានជំនួយពីអង្គការសហប្រជាជាតិក្នុងគោលបំណងកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា ប្រសិនបើអង្គការសហប្រជាជាតិមិនពេញចិត្តនឹងច្បាប់ថ្មី គឺអាចដកខ្លួនចេញពីអង្គជំនុំជម្រះបាន ។ លោកបន្តទៀតថា «ប្រសិនបើអង្គការសហប្រជាជាតិមិនចូលរួមនោះ វាងាយស្រួលដល់ខ្ញុំ ។ ខ្ញុំមានបំណងនឹងចុះកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ» ។

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០១ ព្រះអង្គម្ចាស់ រណឫទ្ធិ បន្ថែមលើសម្តីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ថា ប្រទេសកម្ពុជាមិនត្រូវធ្វើតាមតម្រូវការរបស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងច្បាប់របស់អង្គជំនុំជម្រះ ។ ព្រះអង្គសង្កត់ធ្ងន់ថា «ប្រទេសកម្ពុជានឹងមិនធ្វើការរចរចាបន្តទៀតទេ ហើយទោះបីជាអង្គការសហប្រជាជាតិមិនយល់ព្រមនឹងច្បាប់នេះក៏ដោយ នោះគឺជារឿងរបស់គេ» ។

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក កូរ៉ែល លោក សុខ អាន សម្តែងភាពយល់ស្របពីទំនាក់ទំនងរវាង

ច្បាប់និងកិច្ចព្រមព្រៀង ។ ខណៈពេលដែលយល់ស្របនឹងគោលការណ៍ដែលគួរតែអនុវត្តន៍ លោកក៏បានបដិសេធនឹងការ «បង្ខំ» ។

នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០១ លោក កូរ៉ែល ឆ្លើយតបថា គាត់ត្រូវការភាពស៊ីគ្នារវាងឯកសារទាំងពីរ ។

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០១ សភាជាតិយល់ស្របនឹងច្បាប់ដើម្បីបង្កើតតុលាការកាត់ទោសខ្មែរក្រហម ។ បន្ទាប់ពីមានការយល់ព្រមគ្នា លោក សុខ អាន ប្រាប់អ្នកសារព័ត៌មានថា គាត់និងលោក កូរ៉ែល «នឹងបន្តចរចាជាមួយគ្នាទៀតបន្ទាប់ពីច្បាប់មានសុពលភាព» ។

នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០១ សម្តេច សីហនុ ប្រកាសថាទ្រង់នឹងមិនពាក់ព័ន្ធនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះ ជាពិសេសចំពោះបញ្ហាថានឹង «ការកាត់ទោស អៀង សារី នួន ជា និង ខៀវ សំផន» ។

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ព្រឹទ្ធសភាកម្ពុជាទទួលច្បាប់តុលាការខ្មែរក្រហមដែលអាចកែប្រែបាន ។

នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០១ ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនៅសាកលវិទ្យាល័យអាមេរិកផ្សាយព័ត៌មានដោយ ស្ទេហ៊្វិន ហេដឺ និង ប្រាយអេន ធីតឋឹម៉ន បង្ហាញពីការចោទប្រកាន់និងភ័ស្តុតាងសមស្របពាក់ព័ន្ធនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម៧នាក់ដែលនៅរស់ ។ មេដឹកនាំដែលត្រូវបានយកមកពិចារណានៅក្នុងរបាយការណ៍គឺ នួន ជា, អៀង សារី, ខៀវ សំផន, តា ម៉ុក, កែ ពក, ស៊ូ ម៉េត និង មាស មុត ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា ការចោទប្រកាន់មេដឹកនាំខ្មែរក្រហមសម្រេចទៅលើការសម្រេចចិត្តរបស់តុលាការមិនមែនអ្នកមានចំណេះដឹងទេ ។ លោកនាយករដ្ឋមន្ត្រីចាត់ទុកសេចក្តីសម្រេចថាជាការធ្វើអន្តរាគមន៍របស់បរទេសនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ។

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ព្រឹទ្ធសភាកម្ពុជាយល់ស្របនឹងច្បាប់ថ្មីរបស់តុលាការ ។ បន្ទាប់ពីការបោះឆ្នោត លោក សុខ អាន ប្រាប់អ្នកសារព័ត៌មានថា គាត់មានសុទិដ្ឋិនិយមថាប្រទេសកម្ពុជា និង អង្គការសហប្រជាជាតិនឹងឆ្ពោះទៅកាន់ដំណោះស្រាយហើយ «វត្តមានរបស់តុលាការត្រូវពឹងផ្អែកលើការធ្វើកិច្ចចរចាទាំងនេះ» ។

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថានៅក្នុងសាលាគរុកោសល្យថា «រដ្ឋាភិបាលមិនទាន់បានចេញដីកាចាប់ខ្លួន ខៀវ សំផន នួន ជា ឬ កែ ពក» ហើយស្នើសុំថាការចាប់ខ្លួនត្រូវតែមានតុល្យភាពរវាងសន្តិភាពនិងការផ្សះផ្សាជាតិ ។

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០១ លោក សុខ អាន បង្ហាញថា រដ្ឋាភិបាលកម្ពុជាកំពុងតែស្វែងរកការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការប្រល័យពូជសាសន៍ ។ លោកមានប្រសាសន៍នៅក្នុងផ្ទះរបស់គាត់នៅខេត្តតាកែវថា «យើងត្រូវការដៃគូរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម» ។

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញយល់ស្របនឹងសេចក្តីព្រាងច្បាប់ដែលនឹងត្រូវយកមកកាត់ទោសមេដឹកនាំខ្មែរក្រហម ។

នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ សម្តេច សីហនុ ឡាយព្រះហស្តលេខាលើច្បាប់ «ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍នៅឯការសម្ពោធមួយ ដែលមានការចូលរួមរបស់អតីតមេបញ្ជាការទ័ពខ្មែរក្រហម មេដឹកនាំថ្នាក់ខ្ពស់យ៉ាងតិច១០នាក់ត្រូវយកមកកាត់ទោសនៅតុលាការដែលបានគ្រោងទុក ហើយកម្មាភិបាលថ្នាក់ទាបនិងមធ្យមនឹងមិនត្រូវយកមកកាត់ទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។ «ដូច្នេះកុំភ័យខ្លាច និងរត់ចូលព្រៃអី ។ តុលាការនេះកាត់ទោសតែមេដឹកនាំថ្នាក់ខ្ពស់របស់ខ្មែរក្រហមប៉ុណ្ណោះ» ។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ឯកអគ្គរដ្ឋទូតអាមេរិក លោក ខេន វីដឹមេន មានប្រសាសន៍ថា រដ្ឋាភិបាលបានសន្យាថា អៀង សារី អាចត្រូវបានចាប់ខ្លួនមុនពេលមានការកាត់ទោសមេដឹកនាំខ្មែរក្រហម ប្រសិនបើ អៀង សារី មិនត្រូវបានយកមក

កាត់ទោសទេ អាមេរិកនឹងដកជំនួយពីតុលាការ ។

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០១ លោក សុខ អាន ស្នើច្បាប់ក្នុងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានយល់ស្របនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ជាភាសាខ្មែរដោយមានកំណត់សម្គាល់ថា ការបកប្រែមិនផ្លូវការជាភាសាអង់គ្លេសនិងបារាំងនឹងសម្រេចនៅពេលខាងមុខនៅអង្គការសហប្រជាជាតិ ។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា ខៀវ សំផន មិនអាចគេចផុតពីការប្រឈមមុខនឹងការកាត់ក្តី ទោះបីជាគាត់បដិសេធថាគាត់មិនជាប់ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ក៏ដោយ ។ ដកស្រង់ចេញពីច្បាប់អង្គជំនុំជម្រះរបស់កម្ពុជាដែលសេចក្តីចម្លងត្រូវបានបញ្ជូនទៅឲ្យអង្គការសហប្រជាជាតិនៅញូវយ៉ក បានឲ្យដឹងថា ខៀវ សំផន បដិសេធថាគាត់មិនបានបញ្ជាឲ្យមានការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ អង្គការសហប្រជាជាតិទទួលបានការបកប្រែជាផ្លូវការពីភាសាខ្មែរទៅអង់គ្លេសនិងបារាំងនៅក្នុងលិខិតដែល លោក សុខ អាន ផ្ញើឲ្យលោក ហាន់ កូរ៉ែល ។

នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ សមាជិកព្រឹទ្ធសភាអាមេរិកពីររូបស្នើថា អង្គការសហប្រជាជាតិនឹងមិនចូលរួមក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ប្រសិនបើរដ្ឋាភិបាលកម្ពុជាមិនផ្តល់ការការពារដើម្បីធានាឲ្យមានច្បាប់ដែលមានបទដ្ឋានអន្តរជាតិកម្រិតខ្ពស់ ។

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០១ ទ័ពកម្ពុជានិយាយថាបានដករថក្រោះនិងកាំភ្លើងធំពីអតីតទីបញ្ជាការខ្មែរក្រហមដោយការផ្លាស់ប្តូរនេះគឺដើម្បីចៀសវាងកុំឲ្យមានអសន្តិសុខចំពោះតុលាការប្រល័យពូជសាសន៍ដែលបានគ្រោងទុក ។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០១ កែ ពក ដែលជាអតីតមេបញ្ជាការទ័ពរងរបស់ខ្មែរក្រហមបដិសេធថា មិនបានជាប់ពាក់ព័ន្ធនឹងអំពើឃោរឃៅដែលបានសម្លាប់ប្រជាជនកម្ពុជាជាង១លាននាក់ដោយនិយាយថាគាត់គឺជាសមាជិកថ្នាក់តូចម្នាក់ហើយយល់ដឹងពីស្ថានការណ៍ប្រទេសតែបន្តិចបន្តួចប៉ុណ្ណោះ ។ គាត់ថែមទាំងបដិសេធនឹងពាក្យចចាមអារ៉ាមដែលថាគាត់កំពុងតែស្វែងរកទិដ្ឋាការដើម្បីធ្វើដំណើរទៅប្រទេសចិន ។

នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០១ លោក សុខ អាន ផ្ញើលិខិតអញ្ជើញទៅឲ្យលោក ហាន់ កូរ៉ែល ដើម្បីអញ្ជើញលោកមកប្រទេសកម្ពុជាក្នុងគោលបំណងបញ្ចប់ការសហប្រតិបត្តិការ ។

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០១ នាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រាប់ឯកអគ្គរដ្ឋទូតអាមេរិក លោក ខេន វីដីមេន ថា គាត់ «ពិតជាចង់ចូលរួមក្នុងអង្គជំនុំជម្រះ» ដោយប្រើប្រាស់ច្បាប់ដែលមានការយល់ស្របពីរដ្ឋាភិបាលនិងឡាយព្រហស្តលេខាដោយសម្តេចសីហនុ កាលពីខែសីហា ។ រដ្ឋាភិបាលកម្ពុជាផ្ញើលិខិតអញ្ជើញទៅឲ្យអង្គការសហប្រជាជាតិដើម្បីបន្តពិភាក្សាអំពីការកាត់ទោសដើម្បីជំរុញឲ្យឆ្ពោះទៅដល់ទីបញ្ចប់ ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន នៅថ្ងៃទី១០ ខែតុលា លោក ហាន់ កូរ៉ែល ថ្លែងថាអង្គការសហប្រជាជាតិនៅតែមានការព្រួយបារម្ភចំពោះបញ្ហាមួយចំនួន ។ ការព្រួយបារម្ភធំបំផុតគឺឯកសារច្បាប់ឬក៏ការយល់ស្របគ្នារវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិដែលនឹងត្រួតពិនិត្យការគ្រប់គ្រងអង្គជំនុំជម្រះក្នុងករណីដែលមានភាពមិនយល់ស្របគ្នា ។

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ចក្រភពអង់គ្លេសផ្តល់ជំនួយ៥សែនដុល្លារទៅឲ្យអង្គការសហប្រជាជាតិដើម្បីជាមូលនិធិជួយដល់ការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅប្រទេសកម្ពុជានេះគឺជាប្រទេសដំបូងដែលផ្តល់ជំនួយហិរញ្ញវត្ថុជាផ្លូវការទៅឲ្យតុលាការដែលបានគ្រោងទុក ។ ឯកអគ្គរាជទូតប្រទេសអង់គ្លេស លោក ស៊ីហ៊ិន ប្រ៊ីត្យ និយាយថា «ថ្មីៗនេះរដ្ឋាភិបាលអង់គ្លេសបានឲ្យប្រាក់៥សែនដុល្លារទៅឲ្យអង្គការសហប្រជាជាតិនៅញូវយ៉កដើម្បីជាជំនួយដល់ដំណើរកាត់ទោសខ្មែរក្រហមនៅកម្ពុជា» ។

នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០១ ប្រទេសជប៉ុនមានគម្រោងរៀបចំឲ្យ លោក គូនីជី ស៊ីបាហារ៉ា ដែលជាសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យហ្គាគីសីអ៊ីនធ្វើជាចៅក្រមនៅអង្គជំនុំជម្រះ ។

នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក ហាន់ កូរ៉ែល លោក សុខ អាន ថ្លែងថា «ខណៈពេលដែលកិច្ចព្រម

ព្រៀងសហប្រតិបត្តិការ ប្រហែលជាមានភាពខុសគ្នាបន្តិចបន្តួច នៅក្នុងច្បាប់និងមិនបានបរិយាយពីសេចក្តីលម្អិតជាក់លាក់មួយ តែយើងមិនអាចធ្វើការកែប្រែទេ ទុកឲ្យច្បាប់ដែលទើបតែត្រូវបានប្រកាសឲ្យប្រើនេះដំណើរការទៅមុខ» ។

លោក សុខ អាន ទទួលស្គាល់លិខិតនេះ ហើយធ្វើការកែប្រែសេចក្តីព្រាងច្បាប់នៃកិច្ចព្រមព្រៀងដោយថ្លែងថា ការឆ្លើយតបរបស់លោកនៅតែមិនទាន់ច្បាស់នៅឡើយទេ ។ គាត់បាននិយាយអំពីភាពមិនយល់ស្របគ្នាចំពោះកិច្ចព្រមព្រៀងផ្នែកច្បាប់ ។

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០១ កិច្ចចរចារវាងប្រទេសកម្ពុជានិងអង្គការសហប្រជាជាតិចំពោះការជ្រើសរើសភាសាផ្លូវការដើម្បីប្រើប្រាស់នៅក្នុងសវនាការអង្គជំនុំជម្រះ ។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាដោះស្រាយសារាចរ ការរៀបចំជនរងគ្រោះដែលនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨) និងរៀបចំស្រុកអន្លង់វែងឲ្យទៅជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០១ នៅក្នុងលិខិតផ្ញើឲ្យលោក សុខ អាន លោក កូរ៉ែល បង្ហាញថា ការឆ្លើយតបដ៏ច្បាស់លាស់នឹងបញ្ជូនទៅ ប្រសិនបើកម្ពុជាបំពេញការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១ របាយការណ៍សន្និសីទរបស់អង្គការសហប្រជាជាតិ **H.R.2506** កិច្ចប្រតិបត្តិការបរទេស ការនាំចេញហិរញ្ញវត្ថុនិងច្បាប់សមស្របកម្មវិធីដែលពាក់ព័ន្ធ ឆ្នាំ២០០២ (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១) «លក្ខខណ្ឌជំនួយរបស់តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជាចំពោះការសម្រេចចិត្តនិងការអះអាងដើម្បីធានាថា តុលាការមានលទ្ធភាពផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងលក្ខណៈយុត្តិធម៌និងជឿទុកចិត្តបាន» ។

សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ *UNGA A/RES/56/169*

ជំពូក៤ ៖ តុលាការខ្មែរក្រហម

កថាខណ្ឌទី២ ៖ ស្វាគមន៍ចំពោះការប្រកាសឲ្យប្រើប្រាស់ច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានកើតឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាមួយនឹងការពេញចិត្តនឹងបញ្ញត្តិទូទៅនិងច្បាប់ដ៏មានប្រសិទ្ធភាពព្រមទាំងតួនាទីដែលបានរៀបចំទុកឲ្យអង្គការសហប្រជាជាតិ ធ្វើឲ្យរដ្ឋាភិបាលកម្ពុជាធានាថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌និងទម្លាប់អន្តរជាតិព្រមទាំងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយកម្ពុជា ។ អ្នកទាំងនោះនឹងត្រូវយកទៅកាត់ទោសដោយយុត្តិធម៌តាមបទដ្ឋានអន្តរជាតិ ភាពមិនលម្អៀង និងដំណើរការនីតិវិធីស្របច្បាប់ ។ នេះជំរុញឲ្យរដ្ឋាភិបាលបន្តសហការជាមួយអង្គការសហប្រជាជាតិទៅលើបញ្ហានេះ ។ ស្វាគមន៍ចំពោះកិច្ចប្រឹងប្រែងរបស់លេខាធិការដ្ឋាននិងសហគមន៍អន្តរជាតិក្នុងការជួយឲ្យរដ្ឋាភិបាល ឆ្ពោះទៅកាន់ទីបញ្ចប់នេះដែលជំរុញឲ្យរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិសម្រេចកិច្ចព្រមព្រៀងដោយមិនមានការពន្យារពេល ។ ទាំងនេះបានធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការដោយជោគជ័យនិងធ្វើឲ្យសហគមន៍អន្តរជាតិផ្តល់ជំនួយជាហិរញ្ញវត្ថុនិងឧបត្ថម្ភជាបុគ្គលិកទៅឲ្យអង្គជំនុំជម្រះ ។

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០២ មន្ត្រីក្រសួងការបរទេស លោក ហោ ណាំហុង បង្ហាញពីទុទិដ្ឋិនិយមទៅលើអង្គជំនុំជម្រះដោយមានហេតុផលថា «យោងទៅតាមអធិបតេយ្យភាពរបស់អង្គការសហប្រជាជាតិ ការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងមិនសង្ឃឹមថាអាចដំណើរការបានក្នុងពេលឆាប់ៗនេះទេ ពីព្រោះថាមេដឹកនាំខ្មែរក្រហមប្រហែលជាស្លាប់មុនពេលដែលអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលព្រមព្រៀងគ្នាដើម្បីបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ លោក សុខ អាន ផ្ញើលិខិតបីទំព័រទៅឲ្យអង្គការសហប្រជាជាតិ «ដើម្បីលុបបំបាត់ចម្ងល់និងបង្ហាញច្បាស់លាស់» អំពីមុខងាររបស់រដ្ឋាភិបាលចំពោះការបង្កើតអង្គជំនុំជម្រះ ។

នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ អគ្គលេខាធិការប្រាប់ឲ្យទីប្រឹក្សាច្បាប់របស់គាត់ លោក ហាន់ កូរ៉ែល បញ្ជូនលិខិតមួយ

ច្បាប់ទៅកាន់រដ្ឋាភិបាលកម្ពុជា ដោយប្រាប់ថាអង្គការសហប្រជាជាតិនឹងមិនបន្តចរចាជាមួយរដ្ឋាភិបាលចំពោះការបង្កើតតុលាការពិសេសដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។ នៅក្នុងការសន្និសីទព័ត៌មានប្រចាំថ្ងៃ លោក កូរ៉ែល ថ្លែងការណ៍ថា «នៅក្នុងការណែនាំរបស់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិបានឲ្យដឹងថា អង្គការសហប្រជាជាតិនឹងមិនបន្តចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យទេ» ។

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០២ លោក សុខ អាន មានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាពិតជាសម្តែងការសោកស្តាយចំពោះការសម្រេចចិត្តរបស់អង្គការសហប្រជាជាតិដែលបានប្រកាសកាលពីថ្ងៃទី៨ ខែកុម្ភៈ ។ «រដ្ឋាភិបាលកម្ពុជាកំពុងតែបើកទ្វាររង់ចាំធ្វើការពិភាក្សាបន្តទៅទៀត ។ យើងមិនទាន់បានបញ្ឈប់ការពិភាក្សាដូចលោក កូរ៉ែល ទេ» ។

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ សេចក្តីប្រកាសព័ត៌មានជាអន្តរជាតិចំពោះការលើកលែងទោសថ្លែងថា «សេចក្តីប្រកាសដែលថាអង្គការសហប្រជាជាតិកំពុងតែដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីនាំយកអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរឲ្យសង្ស័យដែលរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនៅសម័យខ្មែរក្រហមយកមកកាត់ទោសគឺមិនមែនជាការភ្ញាក់ផ្អើលអ្វីទេ ។ លទ្ធផលការងារពិតនៅឆ្នាំនេះគឺប្រជាជនកម្ពុជានៅតែមិនទាន់ទទួលបានយុត្តិធម៌ ហើយនេះគឺជាសោកនាដកម្ម» ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន សុំឲ្យអង្គការសហប្រជាជាតិពិចារណាម្តងទៀតចំពោះការមិនពិភាក្សាទៅលើការនាំយកអតីតមេដឹកនាំខ្មែរក្រហមទៅកាត់ទោសដែលអាចធ្វើឲ្យពិភពលោកមិន «ធ្លាក់ក្នុងផ្លូវខុសម្តងទៀត» ក្រោមការដឹកនាំរបស់អ្នកគ្រប់គ្រងប្រទេស ។ លោកនាយករដ្ឋមន្ត្រីប្រាប់អ្នកសារព័ត៌មានថា ប្រទេសកម្ពុជាអាចរង់ចាំរយៈពេល «ពីរឬបីខែ» ដើម្បីឲ្យអង្គការសហប្រជាជាតិផ្លាស់ប្តូរការសម្រេចចិត្ត ប៉ុន្តែរដ្ឋាភិបាលនឹងមិនរង់ចាំជារៀងរហូតទេ ។

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ នៅក្នុងសេចក្តីថ្លែងការណ៍ឆ្លើយតបនឹងការប្រកាសដកខ្លួនរបស់អង្គការសហប្រជាជាតិចេញពីកិច្ចចរចាស្តីពីអង្គជំនុំជម្រះ លោក សុខ អាន មានប្រសាសន៍ថា «រាជរដ្ឋាភិបាលកម្ពុជានៅតែព្យាយាមស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម ក្នុងនាមជាប្រជាជនកម្ពុជានិងមនុស្សជាតិ ។ យើងជឿថា ច្បាប់ដែលប្រកាសឲ្យប្រើកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ បានឲ្យដឹងថា មូលដ្ឋាននៃដំណើរការនីតិវិធីមានទីតាំងនៅតុលាការកម្ពុជាដោយមានការចូលរួមពីអន្តរជាតិនិងមានបទដ្ឋានអន្តរជាតិ ហើយយើងពិតជាសង្ឃឹមថាអង្គការសហប្រជាជាតិនឹងជាចំណែកមួយនៃដំណើរការនេះ» ។ សហរដ្ឋអាមេរិកជំរុញឲ្យអង្គការសហប្រជាជាតិកុំបោះបង់កិច្ចខំប្រឹងប្រែងចូលរួមក្នុងអង្គជំនុំជម្រះ ។

លោក សុខ អាន សរសេរលិខិតមួយទៅឲ្យលោក ហាន់ កូរ៉ែល បង្ហាញពីភាពសោកស្តាយចំពោះការប្រកាសដកខ្លួនចេញពីកិច្ចចរចារបស់អង្គការសហប្រជាជាតិ ហើយសង្ឃឹមថាអង្គការសហប្រជាជាតិនឹងវិលមកធ្វើការបញ្ចប់ក្នុងកិច្ចព្រមព្រៀងសហប្រតិបត្តិការនិងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០២ មេធាវីសុំឲ្យដោះលែង តា ម៉ុក បន្ទាប់ពីអង្គការសហប្រជាជាតិដកខ្លួនចេញពីដំណើរការកាត់ទោស ។ តា ម៉ុក អាយុ៧៥ឆ្នាំ ត្រូវបានឃុំខ្លួននៅឆ្នាំ១៩៩៩ នៅក្រុងភ្នំពេញ រង់ចាំការកាត់ទោសចំពោះតួនាទីរបស់គាត់នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ។ នៅក្រោមច្បាប់កម្ពុជា តា ម៉ុក ទទួលការចោទប្រកាន់ជាផ្លូវការ ហើយដោះលែងវិញនៅថ្ងៃទី៦ ខែមីនា ។

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ មេបញ្ជាការកងពលខ្មែរក្រហម កែ ពក អាយុ៦៨ឆ្នាំ ស្លាប់ដោយជំងឺលើសឈាម និងទឹកនោមផ្អែម ។ គាត់បានធ្វើដំណើរទៅប្រទេសថៃនៅខែមករា ដើម្បីធ្វើការព្យាបាល ក្រោយមកគាត់ក៏ដាច់សរសៃឈាមហើយបញ្ជូនមកស្រុកអន្លង់វែងខាងជើងប្រទេសកម្ពុជាហើយស្លាប់នៅទីនោះ ។

***(នៅមានត)***

**គាត លក្ខិណា**

# យើងអាចអភ័យទោស ប៉ុន្តែយើងមិនអាចបំភ្លេចបានទេ

ការសិក្សាមួយនៅពេលថ្មីៗដែលបានបោះពុម្ពផ្សាយនៅន័រវ៉េ បង្ហាញឲ្យឃើញថា និស្សិត៦៥ភាគរយនៅទីនោះមិនដឹងថា ប៉ុល ពត ជាអ្នកណាទេ ។ នេះធ្វើឲ្យមានការពិភាក្សាដ៏គួរឲ្យចាប់អារម្មណ៍មួយនៅន័រវេស ទាក់ទងនឹងការបង្ហាញអំពីការព្រួយបារម្ភធំមួយ ។ អ្នកអត្ថាធិប្បាយជាច្រើនបកស្រាយបញ្ហានេះថាជាសញ្ញាណនៃភាពមិនដឹងអំពីប្រវត្តិសាស្ត្រ ។ ប៉ុន្តែតើភាពផ្ទុយពីការមិនដឹងអំពីប្រវត្តិសាស្ត្រអាចបកស្រាយជាការដឹងប្រវត្តិសាស្ត្រឬទេ?

កាសែតអន្តរជាតិមួយបានសម្ភាសន៍និស្សិតជនជាតិន័រវេសម្នាក់ចំពោះពាក្យមួយឃ្លាថា «ការមិនចងចាំឈ្មោះនៅក្នុងបរិបទមិនមានន័យថា យើងមិនដឹងពីប្រវត្តិសាស្ត្រនោះទេ ។ អ្វីដែលសំខាន់គឺត្រូវធ្វើឲ្យសង្គមបច្ចុប្បន្នយល់ដឹងអំពីមូលហេតុនិងឥទ្ធិពលរបស់វា» ។ ចំពោះការពិភាក្សានៅន័រវេសអំពីភាពមិនយល់ដឹងពីប្រវត្តិសាស្ត្រថា ប៉ុល ពត គឺជាអ្នកណា បានបង្កើតជាសំណួរថា ហេតុអ្វីបានជាវាសំខាន់ចំពោះនិស្សិតនៅកម្ពុជានិងន័រវេសត្រូវដឹងពី ប៉ុល ពត? តើការយល់ដឹងពីប្រវត្តិសាស្ត្រមានអត្ថន័យនិងតម្លៃអ្វី? ចម្លើយខ្លះអាចនឹងរកឃើញប្រសិនបើយើងងាកទៅផ្តោតលើតុលាការនៅកម្ពុជា ហើយនិស្សិតនៅន័រវេស៦៥ភាគរយដែលមិនដឹងពីរបបប្រល័យពូជសាសន៍នេះធ្វើការស្រាវជ្រាវស្វែងរកការពិតនិងយុត្តិធម៌ ។

ប៉ុល ពត ស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ នៅអន្លង់វែងដែលជាស្រុកសម្បូរដោយធូលីដីនៅតាមព្រំដែនថៃ ។ កន្លែងនេះគឺជាមូលដ្ឋានចុងក្រោយបង្អស់របស់ខ្មែរក្រហម ហើយត្រូវបានរំលាយនៅឆ្នាំ១៩៩៨ ដោយចលនាតស៊ូ ។ ប៉ុល ពត មិនមានឱកាសប្រឈមមុខនឹងយុត្តិធម៌ក្នុងរបបប្រល័យពូជសាសន៍របស់គាត់នៅឆ្នាំ១៩៧៥-១៩៧៩ ដែលធ្វើឲ្យប្រជាជនប្រមាណ ១.៧លាននាក់ ស្លាប់បាត់បង់ជីវិតទេ ។

រហូតមកដល់ពេលនេះ អតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចំនួន៥នាក់ ត្រូវបានចាប់ខ្លួន ហើយរង់ចាំការកាត់ក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មេដឹកនាំទាំងនេះបច្ចុប្បន្នមានវ័យចំណាស់ ហើយភាគច្រើនមានជំងឺទៀត ។

នៅពេលដែលខ្ញុំនិយាយទៅកាន់ប្រជាជនកម្ពុជាដែលមានវ័យក្មេង មនុស្សជាច្រើនបានប្រាប់ខ្ញុំថា មិនចាប់អារម្មណ៍ចង់ដឹងពីរឿងអ្វីដែលបានកើតឡើងនោះទេ ។ គ្រូបង្រៀនម្នាក់នៅបឋមសិក្សាក្រុងភ្នំពេញប្រាប់ខ្ញុំថា សិស្សរបស់គាត់មិនជឿពីអំពើប្រល័យពូជសាសន៍និងទុក្ខវេទនានៅអំឡុងកម្ពុជាប្រជាធិបតេយ្យដែលគាត់បានប្រាប់នោះទេ ។ សាលារៀនដែលគាត់បង្រៀនស្ថិតនៅតែប៉ុន្មានប្រកបុំណ្ណោះពី «សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង» ដែលជាអតីតគុកស-២១ មានបុរស ស្ត្រី និងកូនក្មេងប្រមាណ១៧.០០០នាក់ត្រូវបានសួរចម្លើយនិងធ្វើទារុណកម្មមុនពេលបញ្ជូនទៅសម្លាប់នៅជិតវាលស្រែនៅទិសខាងលិចដែលស្គាល់ថាជា «វាលពិឃាត» ។

នៅប្រទេសន័រវេស រដ្ឋាភិបាលបានបញ្ជូនសិស្សរាប់ម៉ឺននាក់ឲ្យធ្វើដំណើរទៅប្រទេសប៉ូឡូញ និងអាឡឺម៉ង់ដើម្បីទស្សនាអតីត «ជំរំប្រមូលផ្តុំ» ដែលបង្កើតឡើងដោយរបបណាហ្ស៊ីនៅអាឡឺម៉ង់ក្នុងអំឡុងសង្គ្រាមលោកលើកទី២ ហើយជនជាតិជ្វីហ្វប្រមាណ ៦លាននាក់ត្រូវបានសម្លាប់ ។ ប្រសិនបើយើងរួមបញ្ចូលជនជាតិភាគតិចផ្សេងទៀតក្នុងរបបណាហ្ស៊ីរបស់ អាដុហ្វ ហ៊ីត្លែ នោះមានប្រជាជនប្រមាណ៩-១១លាននាក់ត្រូវបានសម្លាប់ ។ គ្រប់ផ្នែកនៃការិយាធិបតេយ្យរបស់អាឡឺម៉ង់ពាក់ព័ន្ធនឹងការសម្លាប់រង្គាល ។

សំណួរដែលថាហេតុអ្វីបានជាវាសំខាន់ក្នុងការអប់រំសិស្សនៅប្រទេសកម្ពុជានិងន័រវេស ឲ្យបានដឹងពីជម្លោះអតីតកាល ។ ចម្លើយមួយផ្នែកគឺថាវាសំខាន់ណាស់ចំពោះការយល់ដឹងពីប្រវត្តិសាស្ត្រ ។ ប៉ុន្តែ តើគេចង់សំដៅទៅលើអ្វីនៅក្នុងសង្គមពីរផ្សេងគ្នាដូចជាកម្ពុជានិងន័រវេស?

បន្ទាប់ពីនិយាយជាមួយជនរងគ្រោះក្នុងរបបខ្មែរក្រហមធ្វើឲ្យខ្ញុំយល់ច្បាស់ថាអ្វីដែលសំខាន់ជាងគេ គឺថាការពិតនឹងត្រូវបានគេស្អប់ខ្ពើម ហើយកូនចៅជំនាន់ក្រោយនឹងជឿលើប្រវត្តិ

សាស្ត្រនេះ ។

«មិនអាចកើតឡើងម្តងទៀត» បានក្លាយទៅជាពាក្យស្លោកសម្រាប់ប្រើក្នុងគោលបំណងផ្សេងៗគ្នា ដើម្បីធានាថាប្រវត្តិនៃអតីតកាលដែលបានវិនាសនឹងមិនអាចកើតមានម្តងទៀតទេ ។ នេះមិនមានន័យថា យើងនឹងបំភ្លេច ប៉ុន្តែក្នុងន័យរំឭកដល់ជម្លោះអតីតកាល ហើយធ្វើឲ្យមានទំនាក់ទំនងដល់សង្គមបច្ចុប្បន្ន ដូច្នេះប្រវត្តិសាស្ត្រនេះនឹងមិនអាចកើតមានម្តងទៀត ។

នៅក្នុងឯកសារនយោបាយដែលបានគ្រោងទុកសម្រាប់បង្ហាត់បង្រៀនសិស្សនៅកម្រិតបឋមសិក្សាបានឲ្យដឹងពីប្រវត្តិសាស្ត្រដែលបានបកស្រាយថា ជាលទ្ធភាពដើម្បីឆ្លុះបញ្ចាំងជីវិតពិតនៅក្នុងប្រវត្តិសាស្ត្រអតីតកាល ។ រឿងនេះពាក់ព័ន្ធនឹងការបង្កើនទស្សនៈផ្ទាល់ខ្លួននៅក្នុងជីវិតដើម្បីឲ្យដឹងថា មនុស្សជាផ្នែកនៃប្រវត្តិសាស្ត្រនៅអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។ ហើយរឿងនេះក៏ពាក់ព័ន្ធនឹងអ្វីផ្សេងៗទៀតជាជាងការសិក្សាពីការពិតរបស់ប្រវត្តិសាស្ត្រ ។ ដោយប្រឈមមុខនឹងប្រវត្តិសាស្ត្រចំពោះការឈឺចាប់នៅអតីតកាល ជ័យជម្នះ និងកំហុស យើងត្រូវតែយល់ដឹងពីការទទួលខុសត្រូវចំពោះឥទ្ធិពលដោយផ្ទាល់នៃប្រវត្តិសាស្ត្រ ។ ដោយរួមបញ្ចូលអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ដូច្នេះអតីតកាលក្លាយទៅជាការដឹកនាំនៅបច្ចុប្បន្ន ហើយយើងអាចដឹកនាំអនាគតរបស់យើងឲ្យមានភាពប្រសើរជាងមុន ។

សារមន្ទីរនៃការចងចាំនិងមជ្ឈមណ្ឌលសិក្សាអំពីប្រវត្តិសាស្ត្រ មានតួនាទីសំខាន់ដើម្បីការពារនិងរក្សាទុកប្រវត្តិសាស្ត្រ ព្រមទាំងអប់រំកូនចៅជំនាន់ក្រោយឲ្យដឹងពីរឿងនេះ ។ ដូច្នេះសារមន្ទីរនិងមជ្ឈមណ្ឌលនេះ មានតួនាទីប្រាប់កូនចៅជំនាន់ក្រោយឲ្យដឹងពីប្រវត្តិសាស្ត្រដោយរក្សាទុកការចងចាំនៅពេលដែលសាក្សីបានឆ្លងកាត់ក្នុងហេតុការណ៍បាត់បង់ ។ នេះប្រហែលជាការទទួលខុសត្រូវខាងសីលធម៌ ធ្វើឲ្យមានការប្តេជ្ញាដើម្បីចងចាំប្រវត្តិសាស្ត្រដ៏ឈឺចាប់ ហើយធ្វើការសិក្សាអំពីប្រវត្តិនេះ ។

នៅកម្ពុជា សាក្សីដែលឆ្លងកាត់ក្នុងហេតុការណ៍មានតួនាទីសំខាន់ដើម្បីធានាថា កូនចៅជំនាន់ក្រោយនឹងយល់ដឹងអំពីបទពិសោធន៍ដែលគេបានឆ្លងកាត់ ដូច្នេះរឿងនេះនឹងមិនត្រូវបានបំភ្លេច ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានធ្វើដំណើរជាមួយប្រធានឃុំប្រហែល៤០នាក់ ដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្តាប់សវនាការដំបូងរបស់ នួន ជា ឬ «បងធំទីពីរ» ។ អ្នកទាំងឡាយដែលខ្ញុំបាននិយាយជាមួយ មានតួនាទីសំខាន់ដើម្បីធានាថា ប្រវត្តិរឿងនឹងមិនត្រូវបានបំភ្លេចទេ ។ គឺសង្ឃឹមចំពោះអង្គជំនុំជម្រះគឺឲ្យចង់ចៅទួតរបស់គេជឿថា បទពិសោធន៍ដែលគេបានឆ្លងកាត់ពិតជាមានមែន ។

អង្គជំនុំជម្រះមានតួនាទីសំខាន់ដើម្បីធានាថា រឿងដ៏ឃោរឃៅនៅអតីតកាលគឺជាការពិត ហើយរឿងនេះត្រូវបានទទួលស្គាល់និងមានការចងចាំដែលនាំឲ្យសិស្សសាលាអាចសិក្សាយល់ដឹងអំពីជម្លោះពីអតីតកាលរបស់ប្រទេសខ្លួន ព្រមទាំងជឿលើអ្វីដែលគេបានឮ ។

អង្គជំនុំជម្រះនឹងធានាថា អាចរួមបញ្ចូលរឿងឈឺចាប់ដែលពាក់ព័ន្ធនឹងអតីតកាលដ៏ឃោរឃៅដោយប្រាប់អំពីដំណើររឿងប្រវត្តិសាស្ត្រដែលមានការចាប់ផ្តើមដ៏ច្បាស់លាស់ ចំណុចកណ្តាល និងទីបញ្ចប់ដែលអាចប្រាប់ទៅកូនចៅជំនាន់ក្រោយ ។

នេះប្រហែលជាចម្លើយមួយផ្នែកសម្រាប់សំណួរដែលពាក់ព័ន្ធនឹងអត្ថន័យនិងតម្លៃនៃចំណេះដឹងប្រវត្តិសាស្ត្រ ព្រមទាំងការយល់ដឹងពីប្រវត្តិសាស្ត្រក្នុងគោលបំណងសិក្សាពីអតីតកាលដើម្បីការពារមិនឲ្យកើតមានម្តងទៀតក្នុងទម្រង់ថ្មី ។ ចំណេះដឹងនិងការយល់ដឹងខាងប្រវត្តិសាស្ត្រទាំងនៅកម្ពុជានិងរ៉េវ៉េសក្លាយទៅជាមានតម្លៃដើម្បីធានាថា «មិនអាចកើតមានម្តងទៀត» ។ **ខ្ញីធីល ក្រូឌឹម**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# របាយការណ៍ពីខេត្តកំពង់ធំ : គម្រោងជួយជនរងគ្រោះបំពេញពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម

## ១) ប្រវត្តិការងារស្តីពីគម្រោងចូលរួមរបស់ជនរងគ្រោះ ក្នុងខេត្តកំពង់ធំ

ខេត្តកំពង់ធំស្ថិតនៅភាគកណ្តាលប្រទេសកម្ពុជានិងមានព្រំប្រទល់ខាងជើងជាប់ខេត្តព្រះវិហារ ខាងត្បូងជាប់ខេត្តកំពង់ចាម និងកំពង់ឆ្នាំង ខាងកើតជាប់ខេត្តក្រចេះនិងខាងលិចជាប់ខេត្តសៀមរាប មានផ្ទៃដីសរុប១៥.០៦១គីឡូម៉ែត្រការ៉េ ។ ខេត្តនេះមាន៨ស្រុក រួមមានស្រុកបារាយណ៍ កំពង់ស្វាយ ស្ទឹងសែន ប្រាសាទបល្ល័ង្ក ប្រាសាទសំបូរ សន្ទុក ស្ទោង និងសណ្តាន់ ។ ទីរួមខេត្តកំពង់ធំស្ថិតនៅខាងជើងក្រុងភ្នំពេញចម្ងាយ១៦២គីឡូម៉ែត្រ ។ ខេត្តនេះមានប្រជាជនប្រហែល៥៧០.០០០នាក់ ដែលភាគច្រើនធ្វើស្រែនិងធ្វើឧស្សាហកម្មឈើ ។

នៅឆ្នាំ១៩៧៦ ខេត្តកំពង់ធំស្ថិតនៅភូមិភាគខាងជើងទាំងមូល ទោះបីផ្នែកខ្លះក្រោយមកបានក្លាយជាផ្នែកនៃភូមិភាគបូព៌ាក៏ដោយ ។ តាមរបាយការណ៍ផ្អែកលើញត្តិរណសិរ្ស មនុស្សស្លាប់ទាំងអស់ក្នុងខេត្តកំពង់ធំមានចំនួន៣២៤.៥៤៧នាក់ ដែលក្នុងនោះជនរងគ្រោះចំនួន២៧៣.៣៤២ ជាកសិករ ។ ជាងនេះទៅទៀត មនុស្សចំនួន ៥.០៩២នាក់ ត្រូវធ្លាក់ខ្លួនពិការដោយសាររបបនេះ ។ នៅអំឡុងរបបនេះ មនុស្សជាច្រើនត្រូវបានសម្លាប់


អ្នកភូមិកំពុងអានសៀវភៅណែនាំអំពីសាលាក្តីខ្មែរក្រហម

នៅពេលសាងសង់ប្រឡាយទឹកធំៗ ។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០០៨ គម្រោងគូសផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញទីតាំងសម្លាប់ចំនួន១៧ (ដែលក្នុងនេះមានរណ្តៅជាង១.៦០០កន្លែងនិងមានសាកសពប្រមាណ១៨ម៉ឺននាក់) គុក១០កន្លែង និងបូជនីយដ្ឋាន៦កន្លែងនៅក្នុងខេត្តកំពង់ធំនេះ ។

ខេត្តកំពង់ធំមានសារសំខាន់សម្រាប់ការងារគម្រោងចូលរួមរបស់ជនរងគ្រោះ ពីព្រោះចំនួនប្រជាជននៅក្នុងខេត្តនេះបានចូលរួមធ្វើញត្តិរណសិរ្សក្នុងឆ្នាំ១៩៨២-៨៣ ដែលសព្វថ្ងៃរក្សាទុកក្នុងបណ្ណាសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

## ប្រវត្តិនៃញត្តិរណសិរ្សនៅខេត្តកំពង់ធំ

មជ្ឈមណ្ឌលរក្សាបានទុកនៅក្នុងបណ្ណាសាររបស់ខ្លួន «ញត្តិរណសិរ្ស» នេះ ។ នៅអំឡុងឆ្នាំ១៩៨២-៨៣ រដ្ឋាភិបាលក្រោយរបបខ្មែរក្រហមបានប្រមូលញត្តិចំនួន១.២៥០ ដែលរៀបរាប់ពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យវាយប្រជាជនខ្មែរជាង១លាន១សែននាក់ ។ គម្រោងនេះគ្រោងនឹងប្រើញត្តិទាំងនេះដើម្បីស្វែងរកអ្នកដាក់បណ្តឹងនិងដើមបណ្តឹងរដ្ឋប្បវេណីជាសំខាន់ ។ ធ្វើដូច្នេះ គម្រោងនឹងបង្កើតឡើងវិញនូវគណៈកម្មការស្វែងរកការពិតមិនផ្លូវការមួយដែលបានចាប់ផ្តើមដោយរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ នៅពេលបង្ហាញដល់អ្នកដាក់បណ្តឹងថាចម្លើយសក្ខីភាពមុនមិនត្រូវបានបំភ្លេចចោល គម្រោងនេះនឹងរួមចំណែកក្នុងដំណើរការផ្សះផ្សាជាតិ ។ បើទោះបីជាគម្រោងផ្តោតសំខាន់ទៅលើការស្វែងរកនិងជួយដល់អ្នកធ្វើញត្តិនៅឆ្នាំ១៩៨២-៨៣ ក្រុមនេះមានបំណងជួយដល់អ្នកនៅរស់ទាំងអស់ដែលចាប់អារម្មណ៍ក្នុងការបំពេញទម្រង់បែបបទព័ត៌មានជនរងគ្រោះរបស់តុលាការ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាមានញត្តិចំនួន៨៧មកពីខេត្តកំពង់ធំ ។ ញត្តិដែលបានប្រមូលពីខេត្តកំពង់ធំទាំងនេះមានលក្ខណៈសមូហភាពខុសប្លែកពីខេត្តដទៃ ។ ជាធម្មតាអ្នកតំណាង

ម្នាក់ឬពីរនាក់បានសរសេរនិងចុះហត្ថលេខា ឬផ្តិតមេដៃលើញត្តិតំណាងឲ្យក្រុមធំមួយ ដែលមានមនុស្សប្រមាណពី២០០ទៅ ១០០០នាក់ ។ ដូច្នេះ ញត្តិដែលបានមកពីខេត្តនេះពុំមានឈ្មោះ និងហត្ថលេខាឬស្នាមមេដៃមនុស្សគ្រប់គ្នាទេ ។ ក្រុមអ្នកតំណាងក្នុងញត្តិជាមនុស្សមកពីគ្រប់ស្រទាប់សង្គម ដូចជាគ្រូបង្រៀន បញ្ញវន្ត និងអ្នកភូមិ ។

## ២) សកម្មភាពរបស់បុគ្គលិកគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមនៅថ្ងៃទី២៨ ខែមីនា

### ក) គោលបំណង

គោលបំណងនៃគម្រោងនេះ គឺដើម្បីផ្តល់ព័ត៌មានដល់អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យអំពីសិទ្ធិចូលរួមរបស់ពួកគាត់ក្នុងការកាត់ក្តីនៅមុនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជួយពួកគាត់ក្នុងការបំពេញទម្រង់បែបបទ បើសិនគាត់មានបំណងចូលរួម ។ គម្រោងនេះបានស្វែងរកនិងជួបប្រជាជនក្នុងខេត្តដែលបានបំពេញញត្តិរំលាយសិរ្សក្នុងឆ្នាំ១៩៨២-៨៣ ។ ជាងនេះទៅទៀត គម្រោងបានព្យាយាមប្រែក្លាយការបណ្តុះបណ្តាលនាពេលថ្មីៗឲ្យទៅជាការអនុវត្តនិងផ្តល់បទពិសោធន៍ជាក់ស្តែងដែលមានប្រយោជន៍ដល់បុគ្គលិករបស់គម្រោងនេះ ។

### ខ) ការរៀបចំសម្រាប់ការចុះទៅធ្វើការតាមខេត្ត

នៅខែមករា ឆ្នាំ២០០៨ សហការីច្បាប់មកពីសាកលវិទ្យាល័យហាវើដឈ្មោះ ជេឌី ក្លាស្បាយ, នៀល ប៉ាយ និង អេនឌ្រូ ស្តេនមេន និងដោយមានជំនួយពី ចន ឈីង៍រី (ទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា) បានផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកគម្រោង និងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សហការីផ្នែកច្បាប់បានរៀបចំកម្រងសំណួរសម្រាប់សម្ភាសន៍ចំនួន១៦ទំព័រ ដែលរៀបរៀងដើម្បីណែនាំបុគ្គលិកពីរបៀបចូលរួមផ្សេងៗ ណែនាំអំពីការបំពេញទម្រង់ព័ត៌មានជនរងគ្រោះដើម្បីផ្តល់នូវប្រវត្តិនៃញត្តិរំលាយសិរ្សនិងផ្តល់ព័ត៌មានទាក់ទងនឹងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ។ នៅថ្ងៃទី២១ ខែមករា សហការីផ្នែកច្បាប់បានបើកការបណ្តុះបណ្តាលមួយសម្រាប់បុគ្គលិក ដោយផ្តោតត្រង់ចំណុចដែលមាននៅក្នុងបែបបទព័ត៌មានជនរងគ្រោះ ផ្តោតលើវិធីសាស្ត្រសម្ភាសន៍ដើរតួសាកល្បង និងបង្ហាញពីធាតុផ្សំនៃឧក្រិដ្ឋកម្ម ។ លោក ចនឈីង៍រី មកមជ្ឈមណ្ឌលពីថ្ងៃទី១៥ ដល់ថ្ងៃ២៣ ខែមករា និងបានត្រួតពិនិត្យកម្មវិធីបណ្តុះបណ្តាលរបស់សហការីផ្នែកច្បាប់ព្រមទាំងបានជួបមន្ត្រីតុលាការដើម្បីពិភាក្សាពីបញ្ហាដែលពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះ ។ លើសពីនេះ ន័រមេន ផេនថ-ឡូវីឌ បានរៀបចំការវាយតម្លៃជាបឋមចំពោះគម្រោងជួយជនរងគ្រោះចូលរួមដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហម ។

ភ្លាមៗនៅមុនដំណើរទស្សនកិច្ចនៅថ្ងៃទី៦ និងទី៧ ខែមីនា លោក ជី ទេវិទ្ធិ (អ្នកដឹកនាំក្រុម) និង សារ៉ា ថូម៉ាស សហការីច្បាប់) បានដឹកនាំវគ្គបណ្តុះបណ្តាលខ្លីចំនួនពីរ ។ អ្នកទាំងពីរបានពន្យល់ពីទម្រង់ព័ត៌មានរបស់ជនរងគ្រោះដល់ក្រុមមួយសំណួរៗ ណែនាំក្រុមឲ្យផ្តោតទៅលើការសួរសំណួរនៅពេលបំពេញសំណួរពណ៌នាពីឧក្រិដ្ឋកម្មក្នុងផ្នែក-ខ និងបានពន្យល់ពីឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការតុលាការ ។

### គ) សេចក្តីលម្អិតនៃការរៀបចំនិងបុគ្គលិក

ក្រុមគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងបានប្រើផ្ទះមួយខ្នងក្នុងទីរួមខេត្តកំពង់ធំធ្វើជាមូលដ្ឋាននៅអំឡុងពេលបំពេញការងារ ។ ដំណើរនេះមានរយៈពេល៣សប្តាហ៍ ចាប់ផ្តើមពីថ្ងៃទី១០ ខែមីនា ហើយបញ្ចប់នៅថ្ងៃទី២៨ ខែមីនា ។ បុគ្គលិក១០នាក់បានចូលរួមដំណើរទស្សនកិច្ចនេះ ។

### លទ្ធផលនៃដំណើរទស្សនកិច្ច

នៅអំឡុងពេលដំណើរទស្សនកិច្ច ក្រុមរបស់យើងបានទៅធ្វើការនៅក្នុងស្រុកចំនួន៩ក្នុងខេត្តកំពង់ធំដោយជោគជ័យ ។ ដោយឡែកក្រុមយើងបានរៀបចំការប្រជុំក្នុងភូមិចំនួន៣០ នៃឃុំ១២ផ្សេងគ្នា ។ សមាជិកក្រុមបានផ្តល់ព័ត៌មានដល់អ្នកនៅរស់ពីរបបកម្ពុជាប្រជាធិបតេយ្យស្តីពីសិទ្ធិចូលរួមរបស់គាត់និងបានជួយបំពេញទម្រង់ព័ត៌មានជនរងគ្រោះដល់អ្នកនៅរស់ចំនួន៣១៧នាក់ ។ ក្រុមនេះសង្ឃឹមថា ព័ត៌មាននៅក្នុងទម្រង់ទាំងនេះនឹងមានផលប្រយោជន៍ដល់ការងាររបស់តុលាការ ។

### ក) ភាពជោគជ័យរបស់ក្រុមជួបនឹងអ្នកធ្វើញត្តិរំលាយសិរ្ស

មុនចុះទៅធ្វើការ បុគ្គលិកគម្រោងបានសម្រេចទៅទស្សនាភូមិជាច្រើនផ្អែកលើញត្តិដែលមានក្នុងភូមិទាំងនោះ ។ ក្រុមយើង

បានរកឃើញញត្តិរណសិរ្សដែលមានឈ្មោះមនុស្សចំនួន១៨នាក់ រស់នៅក្នុងភូមិទាំងនោះនៅឆ្នាំ១៩៨២-៨៣ ។ ក្នុងចំណោមមនុស្សទាំង១៨នាក់នោះ ក្រុមបានរកឃើញកន្លែងរបស់អ្នកធ្វើញត្តិចំនួន៨នាក់ដោយជោគជ័យ ។ ចំណែកអ្នកធ្វើញត្តិ១០នាក់ទៀតអាចស្លាប់ ផ្លាស់ទីលំនៅ ឬ មានជំងឺ មិនអាចបំពេញទម្រង់នេះបាន ។ អ្នកដាក់បណ្តឹង៨នាក់នេះ មានតែម្នាក់ទេដែលមិនបានបំពេញទម្រង់នេះដោយសារគាត់គិតថាតុលាការមិនអាចផ្តល់យុត្តិធម៌បាន ព្រោះតែឥទ្ធិពលនយោបាយ ។

ក្រុមបានរកឃើញថា ដំបូងអ្នកធ្វើញត្តិទាំងនោះមិនបានចុះហត្ថលេខាលើពាក្យបណ្តឹងកាលពីឆ្នាំ១៩៨២-៨៣ ។ ក្នុងករណីជាច្រើនបន្ទាប់ពីបង្ហាញញត្តិនិងហត្ថលេខា គាត់បានចាំនូវការចុះហត្ថលេខា ហើយច្រើននាក់ទៀតចាំមិនច្បាស់ពីការប្រជុំចុះហត្ថលេខា ។ ក្រុមបានរកឃើញថា អ្នកដាក់បណ្តឹងមិនបានចងចាំពីស្ថានភាពពេលប្រជុំ ឬផលប៉ះពាល់នៃឥទ្ធិពលនយោបាយលើញត្តិទាំងនោះទេ ។

### ១) ការប្រជុំជាមួយដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗតាមសំណូមពររបស់ក្រុមជនរងគ្រោះ

ក្នុងឱកាសពីរផ្សេងគ្នា បុគ្គលិកបានជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីដែលជ្រើសរើសដោយអង្គភាពជនរងគ្រោះដែលបានបញ្ជូនឯកសារទម្រង់ព័ត៌មានជនរងគ្រោះដោយមានជំនួយពីគម្រោង ។ តាមសំណូមពររបស់ក្រុមជនរងគ្រោះ បុគ្គលិកបានស្វែងរកឯកសារបន្ថែមនិងបានផ្តល់ព័ត៌មានស្តីពីវិធានការការពារដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ នៅពេលអនាគតឆាប់ៗនេះ ក្រុមជនរងគ្រោះនឹងប្រគល់ព័ត៌មាននៃដើមបណ្តឹងរដ្ឋប្បវេណីដល់សហចៅក្រមស៊ើបអង្កេតសម្រាប់ធ្វើការពិចារណា ។

### ក) ការផ្តល់ឯកសារដល់សាច់ញាតិរបស់អ្នកទោសគុកទួលស្លែង

បុគ្គលិកយើងបានជួយស្ត្រីម្នាក់នៅស្រុកបារាយណ៍ដើម្បីបំពេញទម្រង់នេះ ។ គាត់បានបំពេញពាក្យបណ្តឹងជម្រាបដល់សហព្រះរាជអាជ្ញាអំពីការស្លាប់របស់ជីតាគាត់ នៅពេលជាប់គុកនៅទួលស្លែង ។ គាត់បានប្រាប់បុគ្គលិកថា គាត់បានដឹងពីការស្លាប់របស់ជីតាគាត់នៅទួលស្លែងតាមរយៈមិត្តភក្តិគ្រួសារគាត់ដែលបានឃើញរូបថតដាក់បង្ហាញនៅទីនោះ ។ គាត់បានទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ តែអ្នកយាមម្នាក់បានហាមគាត់មិនឲ្យយករូបថតនៃការបាញ់សម្លាប់ជីតារបស់គាត់ទេ ។ ដោយសារគាត់តូចចិត្តមិនបានរូបថត គាត់បានសុំឲ្យបុគ្គលិកស្រាវជ្រាវរកឯកសារទាក់ទងនឹងជីតាគាត់និងរូបថត ។

នៅពេលក្រុមបានត្រឡប់មកមជ្ឈមណ្ឌលវិញ បុគ្គលិកបានរកឃើញប្រវត្តិរូបជីតាគាត់និងរូបថត ។ មជ្ឈមណ្ឌលនឹងជូនប្រវត្តិរូបនេះទៅឲ្យគាត់ព្រមទាំងរូបថតនោះផង ។

### ការយល់ដឹងជាសាធារណៈនៃគម្រោង

នៅថ្ងៃទី១៧ ខែមីនា កាសែតខេមបូឌាដេលី បានបោះពុម្ពផ្សាយអត្ថបទមួយដោយ អេរីកា ឃីណេត និង យន់ សាមៀន ស្តីពីក្រុមការងាររគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការខ្មែរក្រហមក្នុងខេត្តកំពង់ធំ ។ តាមរយៈចំណងជើងថា «ក្រុមមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកអ្នកដាក់បណ្តឹងខ្មែរក្រហម» អត្ថបទនេះបានខទ្ទេសនាមការងារនៃគម្រោងនិងដកស្រង់ពាក្យសម្តីពីលោក ជី ទេវិទ្ធិ និង នួន ដោក អាយុ៦១ឆ្នាំ ជាអ្នកភូមិម្នាក់មកពីភូមិបារាយណ៍ ។ នួន ដោក បានដាក់ពាក្យបណ្តឹងនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ និងបានឆ្លៀតឱកាសដាក់បណ្តឹងលើកទីពីរនៅថ្ងៃនេះ ។ ឃីណេត បានដកស្រង់ពាក្យសម្តីរបស់ នួន ដោក ដែលថា «ខ្ញុំចង់ឲ្យគេសរសេរពីអំពើឃោរឃៅនៃរបបខ្មែរក្រហមដើម្បីឲ្យកូនចៅជំនាន់ក្រោយយល់ដឹងពីរឿងនេះ» ។

និយាយពីពាក្យបណ្តឹងរណសិរ្ស ឃីណេត បានសរសើរពីបំណងរបស់មជ្ឈមណ្ឌលដែលចង់បំផុសសំឡេងរបស់អ្នកនៅរស់បន្ទឹឡើងក្នុងពាក្យបណ្តឹងដែលមិនទទួលឥទ្ធិពលនយោបាយជាលើកដំបូង ។ នៅពេលដែលភាសារបស់ពួកគេធ្វើឲ្យមានជាលក្ខណៈនយោបាយ អ្នកសរសេរញត្តិពិតជាបង្ហាញពីការឈឺចាប់របស់ប្រជាជនដោយមិនអាចបដិសេធបាន ។

### ផលវិជ្ជមាននៃការងារនៅខេត្តកំពង់ធំ

១) ការប្រជុំរបស់ក្រុមបានផ្តល់ឱកាសដ៏ល្អដល់អ្នកនៅរស់ដើម្បីឲ្យគាត់អាចនិយាយរឿងប្រាប់ដល់ក្រុមដែលចាប់អារម្មណ៍ ដូច្នេះគាត់អាចមានការធូរស្រាលក្នុងករណីជាច្រើន ។ ឧទាហរណ៍ៈ ស្រី សុទ្ធ អាយុ៧៦ឆ្នាំ រស់នៅភូមិស្មោង បាននិយាយថា គាត់មាន

អារម្មណ៍ធូរស្រាល នៅពេលដែលគាត់បានប្រាប់រឿងនេះ ។

២) ឱកាសដើម្បីបំពេញទម្រង់ព័ត៌មានជនរងគ្រោះនិងការជួយបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ បានធ្វើឲ្យអ្នកនៅរស់សប្បាយចិត្តព្រោះមនុស្សជាច្រើនបានសម្តែងការព្រួយបារម្ភថា អ្នកជំនាន់ក្រោយមិនជឿអំពើឃោរឃៅនៃសម័យខ្មែរក្រហម ។

ឧទាហរណ៍ៈ បុរសម្នាក់បានប្រាប់បុគ្គលិករបស់យើងថា នៅពេលគាត់ប្រាប់កូនគាត់ថា ទាហានខ្មែរក្រហមក្មេងៗបានយកមនុស្សទៅសម្លាប់ កូនគាត់មិនយល់ថាហេតុអ្វីមនុស្សទាំងនោះមិនតដៃ ហើយមិនជឿថា គាត់ខ្សោយពេកមិនអាចតដៃបាន ។

៣) ការប្រជុំរបស់ក្រុមបានផ្តល់ឱកាសដ៏មានសារសំខាន់ ដើម្បីជម្រាបដលអតីតខ្មែរក្រហមថ្នាក់ក្រោមថា តុលាការនឹងកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ដូច្នេះ វាអាចធ្វើឲ្យគាត់ស្ងប់ចិត្តនិងបង្កើនលទ្ធភាពនៃការសហការជាមួយតុលាការ ។

៤) វត្តមានរបស់ក្រុមនៅខេត្តកំពង់ធំអាចឲ្យបុគ្គលិកជួយដល់ក្រុមជនរងគ្រោះតាមរយៈការជួបជុំនៅក្នុងឱកាសទាំងពីលើកជាមួយដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗដែលធ្លាប់បានជួយដោយមជ្ឈមណ្ឌល ។

៥) ការចុះទៅធ្វើនៅខេត្តកំពង់ធំនេះបានផ្តល់នូវបទពិសោធន៍ដ៏មានសារសំខាន់ដល់បុគ្គលិករបស់យើងក្នុងការជួយដល់អ្នកនៅរស់បំពេញទម្រង់នេះ ដោយប្រើប្រាស់បទពិសោធន៍ពីមុន ព្រមទាំងការបណ្តុះបណ្តាលពេលថ្មីៗនេះ ។

## សេចក្តីសន្និដ្ឋាន

ការចុះទៅធ្វើការនៅខេត្តកំពង់ធំនេះបានបង្ហាញភាពជោគជ័យដ៏ធំ នៅពេលក្រុមបានប្រមូលទម្រង់ព័ត៌មានជនរងគ្រោះជាង៣០០ ដើម្បីប្រគល់ឲ្យអង្គភាពជនរងគ្រោះ ។ ក្រុមនេះសង្ឃឹមថា ព័ត៌មានដែលមានក្នុងទម្រង់ទាំងនេះនឹងមានប្រយោជន៍ដល់ការងាររបស់តុលាការ ។ ជាការគួរឲ្យសប្បាយដែលទម្រង់បានប្រមូលពេញលេញច្រើនជាងទម្រង់ដែលប្រមូលពីលើកមុន ដោយសារការបណ្តុះបណ្តាលបានល្អជាងមុន ការត្រួតពិនិត្យ និងការពិនិត្យរកកំហុស ឬការខ្វះខាត ។ ជាទូទៅ ទម្រង់បែបបទព័ត៌មានជនរងគ្រោះមានចម្លើយលម្អិតចំពោះសំណួរផ្នែក-ខ ស្តីពីការពណ៌នាឧក្រិដ្ឋកម្មដោយមានការពិពណ៌នាយ៉ាងតិច២ទំព័រក្នុងករណីភាគច្រើន ។

ការចុះទៅធ្វើការនៅខេត្តនេះ ផ្តល់ឱកាសដ៏សំខាន់ដើម្បីជម្រាបដល់អ្នកនៅរស់ក្នុងរបបខ្មែរក្រហមស្តីពីសិទ្ធិចូលរួមនិងធានាដល់អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមថាតុលាការនឹងកាត់ទោសតែអ្នកដឹកនាំជាន់ខ្ពស់ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ។ ជាងនេះទៀត ការបំពេញទម្រង់ដ៏ច្រើនដែលមានការត្រួតពិនិត្យ បានផ្តល់បទពិសោធន៍មានតម្លៃដល់ក្រុម ។ ដូចដែលបានរំពឹងទុកពីលក្ខណៈសម្ហភាពនៃញត្តិពីខេត្តនេះ ក្រុមអាចជួបអ្នកធ្វើញត្តិតែមួយចំនួនតូចប៉ុណ្ណោះ ។ **សារ៉ា ថូម៉ាស និង ឌី ឆេរិទ្ធិ**



បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាណែនាំប្រជាជនអំពីការបំពេញពាក្យបណ្តឹងនៅខេត្តកំពង់ធំ

00180678

C26/I/25

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៤)**

**នៅចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 04 / 2008
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍**
**ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន**

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**
ខៀវ សំផន

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ធី
លោក គង់ ពិសី
លោកស្រី Silke STUDZINSKY

**សហមេធាវីការពារក្តី**
លោក សាយ បូរី
លោក Jacques VERGÈS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00180679

C26/I/25

០០២/១៨-០៩-២០០៧-អវតក/កសចស(អបជ០៤)

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានបើកសវនាការមួយនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ លើបណ្តឹងឧទ្ធរណ៍ដែលជនត្រូវចោទបានប្តឹងប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន។ សវនាការនេះបានដំណើរការជាសាធារណៈ ហើយ បន្ទាប់មក បានបន្តជាសម្ងាត់ ដោយអនុវត្តតាមសេចក្តីបង្គាប់ពីដំបូងរបស់អង្គបុរេជំនុំជម្រះ។

២. នៅពេលចាប់ផ្តើមសវនាការសម្ងាត់ បន្ទាប់ពីអង្គបុរេជំនុំជម្រះ បានធ្វើការពិភាក្សាសម្រេចលើបញ្ហាផ្សេងៗ ដែលភាគីបានលើកឡើង ជនត្រូវចោទបានធ្វើការស្នើសុំឱ្យពន្យារសវនាការនេះ។ សំណើនេះ បានធ្វើឡើងដោយសម្អាងថា សហមេធាវីការពារក្តីអន្តរជាតិបានបដិសេធ មិនព្រមបន្តធ្វើជាតំណាងរបស់ខ្លួន ដោយសារឯកសារទាំងអស់នៅក្នុងសំណុំរឿងមិនមានជាភាសាបារាំង។ ជនត្រូវចោទបានលើកឡើងថា ខ្លួនត្រូវបានដកហូតមេធាវីការពារក្តីមួយរូប ហេតុដូច្នេះហើយ មិនមានជំនឿទុកចិត្តនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍នេះឡើយ។

៣. បន្ទាប់ពីអង្គបុរេជំនុំជម្រះបានស្តាប់ការសន្និដ្ឋានរបស់ភាគី អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចផ្ទាល់មាត់ ដោយអនុញ្ញាតិតាមសំណើនេះ។ ក្នុងនាមអង្គបុរេជំនុំជម្រះ លោកប្រធានបានធ្វើការប្រកាសថា អង្គបុរេជំនុំជម្រះនឹងចេញសេចក្តីសម្រេចដោយមានសម្អាងហេតុទាំងស្រុងជាលាយលក្ខណ៍អក្សរ ភ្លាមៗបន្ទាប់ពីការពន្យារពេលនៃសវនាការនេះ។

៤. មូលហេតុដែលនាំឱ្យមានការដាក់សំណើនេះដោយសារ បន្ទាប់ពីសវនាការបានចាប់ផ្តើម សហមេធាវីការពារក្តីអន្តរជាតិ បានប្រកាសបំណងរបស់ខ្លួនដោយចង់រក្សាសិទ្ធិនៅស្ងៀមមិននិយាយស្តី នៅក្នុងអំឡុងពេលនៃសវនាការ ដោយសារឯកសារទាំងអស់នៅក្នុងសំណុំរឿងមិនមានជាភាសាបារាំង។ ហេតុដូច្នេះ សហមេធាវីការពារក្តីអន្តរជាតិរូបនេះ បានប្រកាសថា ខ្លួននឹងមិនចូលរួមនៅក្នុងសវនាការនេះឡើយ។ សហមេធាវីការពារក្តីអន្តរជាតិបានលើកឡើងថា ក្នុងនាមជាមេធាវីជាតិបារាំងមួយរូប ខ្លួនមានសិទ្ធិទទួលបានឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង ជាភាសាបារាំង ដែលជាភាសាផ្លូវការមួយនៅក្នុងអ.វ.ត.ក ដើម្បីឱ្យខ្លួនអាចការពារកូនក្តីរបស់ខ្លួនបាន។

មូលហេតុនៃការពន្យារពេលសវនាការ

00180680

C26/I/25

០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៤)

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ បានដាក់ជូនអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ហើយមានការចុះហត្ថលេខាពីសហមេធាវីការពារក្តីទាំងពីរ។ ពាក្យសុំចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលស្នើសុំឱ្យសវនាការធ្វើឡើងជាសាធារណៈ ក៏មានការចុះហត្ថលេខាពីសហមេធាវីការពារក្តីអន្តរជាតិ។ ឯកសារដាក់ជូនទាំងអស់ដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ បានរៀបចំឡើងជាភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០៨ បន្ទាប់ពីមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន សហមេធាវីការពារក្តីជាតិ បានដាក់ពាក្យសុំ និងចុះហត្ថលេខា ក្នុងនាមសហមេធាវីការពារក្តី ដោយលើកឡើងថា សូមឱ្យមានការបកប្រែសារណាទាំងនោះជាភាសាខ្មែរ និង ភាសាបារាំង ជាប្រញាប់។ ហើយមុនថ្ងៃសវនាការ សារណាទាំងនោះបានបកប្រែរួចរាល់ ហើយបានប្រគល់ជូនសហមេធាវីការពារក្តី។

៦. គ្មានការចង្អុលបង្ហាញណាមួយជូនអង្គបុរេជំនុំជម្រះ នៅចន្លោះពេលដាក់សារណាបណ្តឹងឧទ្ធរណ៍ និង ថ្ងៃសវនាការឡើយ ដែលលើកឡើងថា ឧបសគ្គធ្ងន់ធ្ងរនឹងកើតមាននៅក្នុងកិច្ចដំណើរការនីតិវិធី។ ជាការពិតណាស់ សំណើដែលធ្វើឡើងនៅថ្ងៃទី១៨ ខែមេសា អាចចាត់ទុកជាការចង្អុលបង្ហាញមួយថា សហមេធាវីការពារក្តីបានត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។

៧. វិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង មានចំនុចមួយបានចែងថា ជនត្រូវចោទមានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន។ អនុលោមតាមវិធាន២២ ជនត្រូវចោទមានសិទ្ធិជ្រើសរើសដោយសេរីពីក្នុងចំណោមមេធាវីជាតិ និង អន្តរជាតិ ដែលមានឈ្មោះនៅក្នុងបញ្ជីដូចមានចែងក្នុងវិធាន ១១-២(ឃ)។

៨. តាមការកត់សម្គាល់ សហមេធាវីការពារក្តីអន្តរជាតិមិនបានស្នើសុំ ឬ ជូនដំណឹងអំពីការសុំពន្យារពេលសវនាការជាមុន ទៅអង្គបុរេជំនុំជម្រះ ដែលថា ខ្លួនមិនមានលទ្ធភាពការពារកូនក្តីរបស់ខ្លួននៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន នេះឡើយ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

មូលហេតុនៃការពន្យារពេលសវនាការ

00180681

C26/I/25

០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៤)

៩. ការបដិសេធរបស់សហមេធាវីការពារក្ដីមិនបន្តធ្វើជាតំណាងឱ្យកូនក្ដី គឺជាការដកខ្លួនចេញពីសវនាការបណ្ដឹងឧទ្ធរណ៍ដោយជាក់ស្ដែងមួយ ហើយបានធ្វើឱ្យប៉ះពាល់ផ្ទាល់ និង អវិជ្ជមានដល់សិទ្ធិមូលដ្ឋានរបស់ជនត្រូវចោទ ដែលមានសិទ្ធិទទួលបានតំណាង នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

១០. ផ្អែកលើកាលៈទេសៈដូចដែលបានរៀបរាប់ដូចខាងលើ ជនត្រូវចោទស្ថិតនៅក្នុងស្ថានភាពមួយដែលខ្លួនមិនមានលទ្ធភាពអនុវត្តសិទ្ធិមូលដ្ឋានរបស់ខ្លួន។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ យល់ព្រមតាមសំណើសុំពន្យារពេលសវនាការទៅថ្ងៃក្រោយ ដោយអង្គបុរេជំនុំជម្រះនឹងជូនដំណឹងតាមក្រោយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការពន្យារពេលសវនាការនេះ គឺជានីតិវិធីតែមួយគត់ដែលអាចធានាដល់សិទ្ធិទាំងឡាយរបស់ជនត្រូវចោទ។

១១. លក្ខខណ្ឌ ដែលនាំឱ្យមានការដកសិទ្ធិតំណាងកូនក្ដីរបស់សហមេធាវីការពារក្ដីអន្តរជាតិ មានអត្ថិភាពចាប់ពីពេលដែលសហមេធាវីការពារក្ដីអនុវត្តសិទ្ធិតំណាងកូនក្ដីរបស់ខ្លួន។ អង្គបុរេជំនុំជម្រះមិនទទួលបានពាក្យសុំពន្យារពេលសវនាការ ឬ បណ្ដឹងដែលពាក់ព័ន្ធនឹងបញ្ហាភាសានោះឡើយ។ ការបដិសេធមិនធ្វើជាតំណាងឱ្យកូនក្ដីនៅក្នុងសវនាការបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីការពារក្ដី ត្រូវបានប្រកាសឱ្យដឹងជាលើកដំបូង នៅថ្ងៃសវនាការនេះតែម្ដង ហើយបានបណ្ដាលឱ្យកូនក្ដីរបស់ខ្លួនបាត់បង់ឱកាសទទួលបានសវនាការជំនុំជម្រះនេះភ្លាមៗ។ បញ្ហានេះបានបង្កឱ្យមានការរំលោភដល់សិទ្ធិមូលដ្ឋានរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះទាន់ពេលវេលា និងសិទ្ធិទទួលបានមេធាវីការពារក្ដីតាមជម្រើសរបស់ខ្លួន ដែលជាសិទ្ធិទទួលស្គាល់ជាអន្តរជាតិដែលនៅជាធរមាន នៅចំពោះមុខអ.វ.ត.ក។

១២. បញ្ញត្តិរបស់វិធានផ្ទៃក្នុង ទទួលស្គាល់អំពីភាពចាំបាច់ឱ្យមានការចូលរួមការពារក្ដីរួមគ្នាពីសហមេធាវីជាតិ និង អន្តរជាតិ។ វិធាន២១(១)នៃវិធានផ្ទៃក្នុង បង្គាប់ឱ្យមាននីតិវិធីបែបនេះ។ ក្នុងករណីនេះ ក្រុមមេធាវីការពារក្ដី ដែលតំណាងជនត្រូវចោទ អាចដោះស្រាយបញ្ហាភាសានិងច្បាប់ទាំងស្រុងបាន។ ប្រសិនបើការការពារក្ដីរួមគ្នាមិនអាចធ្វើទៅបាននោះទេ ជម្រើសមួយទៀតដែលអាចធ្វើទៅបានគឺថា ជនត្រូវចោទអាចមានសិទ្ធិស្នើសុំឱ្យមានសហមេធាវីការពារក្ដីម្នាក់ទៀតមួយរូបផ្សេងមកធ្វើជាតំណាងរបស់ខ្លួន។

មូលហេតុនៃការពន្យារពេលសវនាការ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

00180682

C26/I/25

០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៤)

១៣. វិធាន៣៨ នៃវិធានផ្ទៃក្នុង ចែងថា:

១. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬ បដិសេធក្នុងការ ចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថ មើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬ ផ្ទុយទៅនឹងមាត្រា ២១-៣ នៃកិច្ចព្រមព្រៀង។

២. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។

៣. មេធាវីបរទេសដែលបំពេញវិជ្ជាជីវៈនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ដែលត្រូវទទួលរងការដាក់វិន័យ ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់គណៈមេធាវី។ បណ្តឹងឧទ្ធរណ៍នេះត្រូវព្យួរការអនុវត្តសេចក្តីសម្រេច លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចផ្សេង។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះបិទផ្លូវប្តឹងតវ៉ា។

៤. នៅពេលដែលទទួលបានលទ្ធផលនៃការដាក់វិន័យនេះ មេធាវីដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីមេធាវី ដើម្បីការពារក្តីនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ ត្រូវប្រគល់សម្ភារៈទាក់ទងទៅនឹងរឿងក្តីទាំងអស់ទៅអង្គភាព ពាក់ព័ន្ធនៃការិយាល័យរដ្ឋបាល ដើម្បីធានាដល់និរន្តរភាពក្នុងការការពារក្តី។

១៤. មាត្រា ២១(៣) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា "មេធាវីណាដែលមានសញ្ជាតិខ្មែរឬមិនមែនខ្មែរ ដែលត្រូវជួលឬចាត់តាំងឱ្យធ្វើការជាមួយជនសង្ស័យ ឬ ជនជាប់ចោទក្នុងការការពារកូនក្តីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាននិងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់។"

១៥. ដោយសារអាកប្បកិរិយារបស់សហមេធាវីការពារក្តីអន្តរជាតិ ដែលមិនបានជូនដំណឹងថា ខ្លួននឹងមិនចូលរួមតំណាងកូនក្តីនៅក្នុងសវនាការ ក្នុងកាលៈទេសៈដូចដែលបានលើកឡើងខាងលើ អនុលោមតាមវិធាន៣៨(១) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះបានចេញការព្រមានមួយដល់សហមេធាវីការពារក្តីអន្តរជាតិ ដោយសារខ្លួនបានរំលោភលើដំណើរការក្តីរបស់អង្គបុរេជំនុំជម្រះ និងសិទ្ធិទាំងឡាយរបស់ជនត្រូវចោទ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

មូលហេតុនៃការពន្យារពេលសវនាការ

00180683

C26/I/25

០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៤)

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

(១) ពន្យារពេលសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន ទៅថ្ងៃក្រោយ ដោយអង្គបុរេជំនុំជម្រះនឹងធ្វើការជូនដំណឹងតាមក្រោយ

(២) ចេញការព្រមានមួយដល់សហមេធាវីការពារក្តីអន្តរជាតិ ដោយអនុលោមតាមវិធាន៣៨ នៃវិធានផ្ទៃក្នុង។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

Rowan DOWNING ន័យ ថុល Katinka LAHUIS ហួត វុធី ប្រាក់ គឹមសាន

មូលហេតុនៃការពន្យារពេលសវនាការ ៦

00184967

C22/I/28

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

អង្គបុរេជំនុំជម្រះ

ចំពោះមុខ:
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ៣០ មេសា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ មទួល (Date of receipt/Date de reception): 30 / 04 / 2008
ម៉ោង (Time/Heure): 15h40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

---

## សេចក្តីសម្រេចលើសំណើសុំឲ្យមានសវនាការដាច់ដោយឡែកខាងសវនាការអំពីយុត្តាធិការ និងសវនាការអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់ អៀង សារី

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ធី
គង់ ពិសី
Silke STUDZINSKY

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G.KARNAVAS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥) -២៣-២១៩-៨១៤ ទូរសារ: (៨៥៥) -២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00184968

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

C22/I/28

១- **អង្គបុរេជំនុំជម្រះ** ទទួលបាន "សំណើសុំឱ្យមានសវនាការដាច់ដោយឡែករវាងសវនាការអំពីយុត្តាធិការ និងសវនាការអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់ **អៀង សារី** " ដែលបានដាក់ចូលមកនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៨ (*"សំណើ"*) ។

២- នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបទៅនឹង *សំណើ* នេះ។

៣- មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីពុំបានដាក់សារណាតបណាមួយឡើយ។

៤- នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៨ ជនត្រូវចោទបានដាក់សារណាតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា។

៥- សហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ បើកសវនាការ និងប្រកាសសាលដីកាអំពីបញ្ហាយុត្តាធិការដាច់ដោយឡែកពីសវនាការ និងប្រកាសសាលដីកាអំពីការឃុំខ្លួនបណ្តោះអាសន្ន។

៦- នៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសំណើសុំឱ្យផ្អាកពិចារណា **ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៨** អង្គបុរេជំនុំជម្រះ បានបដិសេធសំណើសុំផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន។មូលហេតុស្នើសុំឱ្យធ្វើដាច់ដោយឡែកពីគ្នាដែលសហមេធាវីការពារក្តីលើកឡើងមានកម្រិតចំពោះ "មូលហេតុក្នុងការកំណត់ពេលវេលាជាក់ស្តែង" បន្ទាប់ពីសេចក្តីសម្រេចនេះ។ សហមេធាវីការពារក្តីពុំបានធ្វើការពន្យល់ថាតើហេតុអ្វីបានជាមូលហេតុក្នុងការកំណត់ពេលវេលាជាក់ស្តែង តម្រូវឱ្យមានការធ្វើដាច់ដោយឡែកពីគ្នាបែបនេះទេ។

៧- អង្គបុរេជំនុំជម្រះពុំបានមើលឃើញមូលហេតុក្នុងការកំណត់ពេលវេលាជាក់ស្តែងណាមួយ ដែលនាំឱ្យមានការធ្វើដាច់ដោយឡែកពីគ្នាបែបនេះឡើយ។ ដូចបានពិចារណាក្នុងសេចក្តីសម្រេចចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ កម្មវត្ថុនៃយុត្តាធិការត្រូវបានបញ្ចូលទៅក្នុងរឿងបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះនឹងដោះស្រាយបញ្ហាទាំងអស់នៅពេលជាមួយគ្នានៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេច:**

*បដិសេធសំណើសុំបើកសវនាការ និងប្រកាសសាលដីកាដាច់ដោយឡែកពីគ្នា របស់ជនត្រូវចោទ។*

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER · CHAMBRE PRELIMINAIRE · E.C.C.C · C.E.T.C

**ប្រាក់ គីមសាន**

សេចក្តីសម្រេចស្តីពីសំណើសុំបើកសវនាការ និងប្រកាសសាលដីកាដាច់ដោយឡែកពីគ្នា

2/2

00184976

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/I/30

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

អង្គបុរេជំនុំជម្រះ

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2008
ម៉ោង (Time/Heure): 15h40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

កាលបរិច្ឆេទ: ៣០ មេសា ២០០៨

---

ដីកាណែនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាជាលាយលក្ខណ៍អក្សរ

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 30 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G.KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00184977

០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

C22/I/30

១- នៅក្នុង "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះស្តីពីសំណើជាបន្ទាន់របស់សហមេធាវីក្នុងការសុំបន្ថែមចំនួនទំព័រ និងពន្យារពេលក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ" ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ខ្លួននៅក្នុងរឿងបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ន បន្ទាប់ពីប្រកាសសាលដីកាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន។ សាលដីកានេះប្រកាសនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៨។

២- សហមេធាវីការពារក្តីបានដាក់ "សារណាបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន របស់ **អៀង សារី**" នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ("សារណាបណ្តឹងឧទ្ធរណ៍")។ នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ តាមដីកាណែនាំរបស់អង្គបុរេជំនុំជម្រះ សហមេធាវីការពារក្តីបានដាក់សារណារបស់ **អៀង សារី** ស្របតាមសេចក្តីសម្រេចស្តីពីសំណើជាបន្ទាន់របស់សហមេធាវីក្នុងការសុំបន្ថែមចំនួនទំព័រ និងពន្យារពេលក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ ("សារណាស្តីពីបញ្ហាយុត្តាធិការ")។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះណែនាំ:**

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាតបតែមួយប៉ុណ្ណោះ ប្រសិនបើមាន ទៅនឹងសារណាបណ្តឹងឧទ្ធរណ៍ និងសារណាស្តីពីបញ្ហាយុត្តាធិការ មិនអោយលើសពី ១៥ ទំព័រ ជាភាសាអង់គ្លេស ឬ ភាសាបារាំង និង ៣០ ទំព័រ ជាភាសាខ្មែរ ក្នុងរយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីដីកាណែនាំនេះ។ សារណារួមគ្នាមិនអោយលើសពី ៤៥ ទំព័រ ជាភាសាអង់គ្លេស ឬ ភាសាបារាំង ឬ មិនអោយលើសពី ៩០ ទំព័រ ជាភាសាខ្មែរ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ E.C.C.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

**ប្រាក់ គឹមសាន**

# ដំណើរទស្សនកិច្ចរបស់សិស្ស និស្សិតអ៊ីស្លាមទៅកាន់អគារអ
# និងសារមន្ទីរប្រល័យពូជសាសន៍ទួល







# ង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាលពិឃាតជើងឯក ស្លួង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨










# ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ៈ
# កំណែទម្រង់គតិយុត្តិ ផ្អែកព្រហ្មទណ្ឌជាតិនិងការផ្ដល់អំណាចក្នុងតំបន់

***(តចប់)***

### ក) បន្ទុកហិរញ្ញវត្ថុចំពោះសាលាក្ដីអន្ដរជាតិសុទ្ធសាធ

ក្រុមអ្នកធ្វើអត្ថាធិប្បាយមួយចំនួនបានកត់សម្គាល់ឃើញថា ការចូលរួមកាន់តែខ្លាំងឡើងរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការអន្ដរជាតិកាន់តែបង្កភាពងាយស្រួលនៅក្នុងការធានានូវនិរន្ដរភាពនៃប្រភពមូលនិធិ ។ នេះគឺនិយាយសំដៅជាពិសេសចំពោះតុលាការខ្លះដូចជា សាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងសាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ដែលទទួលថវិកាពីប្រាក់វិភាគទានដែលបានកំណត់របស់បណ្ដាប្រទេសជាសមាជិកអង្គការសហប្រជាជាតិ ។ បើទោះបីជាតាមភាពជាក់ស្ដែង មានការលំបាកខ្លាំងក្នុងការស្វែងរកមូលនិធិសម្រាប់ទ្រទ្រង់តុលាការដែលពឹងផ្អែកទៅលើការផ្ដល់ប្រាក់វិភាគទានដោយការស្ម័គ្រចិត្ត ដូចជា ក្នុងករណីមួយចំពោះតុលាការនៃប្រទេសស៊ីរ៉ាឡេអូនក៏ដោយ តុលាការកូនកាត់ (ដែលស្ថិតនៅដាច់ឆ្ងាយពីអង្គការសហប្រជាជាតិ ហើយដែលជានិច្ចកាលពឹងផ្អែកទៅលើប្រាក់វិភាគទានតាមការស្ម័គ្រចិត្ត) ប្រើប្រាស់ថវិកាតិចតួចបំផុតមិនដូចជាតុលាការអន្ដរជាតិសុទ្ធសាធនោះទេ ។ កាលណាអង្គការសហប្រជាជាតិចូលពាក់ព័ន្ធកាន់តែខ្លាំងឡើងនៅក្នុងតុលាការអន្ដរជាតិ នោះថវិកាដែលតុលាការត្រូវការក៏កាន់តែច្រើនឡើងដែរ ។ សាលាក្ដីពិសេសពីរបានវិវត្តទៅជាស្ថាប័នដ៏ធំដែលក្នុងនោះមានមុខងារច្រើនជាង២០០០កន្លែង ព្រមទាំងមានថវិការួមផ្សំប្រចាំឆ្នាំលើសពីមួយភាគបួននៃប្រាក់ចំនួនមួយពាន់លានដុល្លារ ឬស្មើនឹងជាង១០ភាគរយនៃថវិកាអចិន្ត្រៃយ៍សរុបរបស់អង្គភាពទាំងមូល ។ ការចំណាយរបស់សាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់ប្រទេសរ៉្វាន់ដានៅរវាងឆ្នាំ១៩៩៥ដល់ឆ្នាំ២០០៣ សរុបមានចំនួនប្រហែល ៤១០លានដុល្លារ ដែលក្នុងនោះ៨លានដុល្លារត្រូវបានចំណាយទៅលើការចេញដីកាចោទប្រកាន់មួយ ហើយ៤៥,៥លានដុល្លារសម្រាប់ការដាក់ទោសមួយ ។ ថវិកាសម្រាប់សាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនៅក្នុងរយៈពេលដដែលនេះ បានកើនឡើងរហូតដល់ប្រមាណជា ៨៧១លានដុល្លារ ដែលក្នុងនោះគិតជាមធ្យមទឹកប្រាក់ចំនួន៩,៥លានដុល្លារ ត្រូវចំណាយទៅលើការចេញដីកាចោទប្រកាន់មួយ និង២២,៥លានដុល្លារ ទៅលើការដាក់ទោសមួយ ។ បើប្រៀបធៀបការចំណាយទាំងនេះទៅនឹងការចំណាយជាមធ្យម ចំនួន២លានដុល្លារសម្រាប់ករណីដាក់ទោសប្រហារជីវិតមួយនៅក្នុងសហរដ្ឋអាមេរិកយើងឃើញថា «ដូច្នេះវាមានរហូតដល់ជាង២០ដងក្នុងការចំណាយទៅលើដំណើរការកាត់ក្ដី (មិនឃុំខ្លួន) ក្រុមឧក្រិដ្ឋជននៃរបបប្រល័យពូជសាសន៍នៅក្នុងសាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់ប្រទេសរ៉្វាន់ដាគឺមានបរិមាណច្រើនជាងការកាត់ទោសប្រហារជីវិតឃាតករម្នាក់នៅក្នុងសហរដ្ឋអាមេរិកនិងច្រើនជាង១០ដងនៅក្នុងសាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។ នៅទីបំផុត ក្រុមប្រឹក្សាសន្ដិសុខរបស់អង្គការសហប្រជាជាតិបានចំណាយប្រាក់ច្រើនជាង១,៦ពាន់លានដុល្លារទៅលើដំណើរការសាលាក្ដីព្រហ្មទណ្ឌនៅក្នុងប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉្វាន់ដា ។

បុគ្គលិកជំនាញភាគច្រើនដែលបម្រើការនៅក្នុងសាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងសាលាក្ដីព្រហ្មទណ្ឌអន្ដរជាតិសម្រាប់ប្រទេសរ៉្វាន់ដាគឺ ស្ថិតនៅក្នុងកម្រិត **P-2, P-3** និង **P-4** ចំណែកឯចៅក្រមស្ថិតនៅក្នុងកម្រិត **D-1** ។ បុគ្គលិកដែលស្ថិតក្នុងកម្រិត **P-3** ឬ **P-4** អាចរកចំណូលបានចាប់ពី៦០.០០០ដុល្លារអាមេរិកទៅ៨០.០០០ដុល្លារអាមេរិក ។ តុលាការកូនកាត់ត្រូវចំណាយថវិការវាង៦០.០០០ដុល្លារអាមេរិកទៅ១០០.០០០ដុល្លារអាមេរិក ទៅលើប្រាក់បៀវត្សរ៍មួយចំនួនដើម្បីទាក់ទាញបុគ្គលិកសំខាន់ៗខ្លះមកបម្រើការងារ ក៏ប៉ុន្ដែ

ប្រាក់បៀវត្សរ៍ភាគច្រើនគឺអាចមានកម្រិតទាបជាងនេះឆ្ងាយណាស់ ។ ប្រសិនបើយើងធ្វើការគណនាដើម្បីបង្ហាញពីចំណាយសម្រាប់ការរស់នៅក្នុងស្រុកនោះ បៀវត្សរ៍ទាំងនេះគឺនៅតែអាចផ្តល់នូវប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់បុគ្គលិកក្នុងស្រុកនៅលើទីផ្សារការងារក្នុងស្រុកដែលអាចនឹងជួយកាត់បន្ថយនូវអ្វីៗគ្រប់យ៉ាង ដែលជាទូទៅគឺការចំណាយតែមួយមុខដ៏ច្រើនបំផុតរបស់តុលាការ ។ ម្យ៉ាងវិញទៀត ការចំណាយរបស់សាលាក្តីរបស់អង្គការសហប្រជាជាតិ ភាគច្រើនក៏មានទំហំធំឡើងដោយសារមានតម្រូវការលើសេវាបកប្រែភាសាជាច្រើន ។ ជាតួយ៉ាង ថវិការបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មួយភាគធំត្រូវចំណាយទៅលើការបកប្រែភាសា ដែលក្នុងនោះមានបុគ្គលិកច្រើនជាង១៧០នាក់ ស្ថិតនៅក្នុងផ្នែកបម្រើសេវាកម្មបកប្រែ ។ ក្នុងការសន្សំសំចៃថវិកាទាំងនេះ តុលាការកូនកាត់អាចនឹងត្រូវផ្លាស់ប្តូររចនាសម្ព័ន្ធដោយការកាត់បន្ថយឲ្យដល់កម្រិតអប្បបរមាការងារខាងភាសានៅក្នុងតុលាការ ដែលនេះនឹងជួយកាត់បន្ថយចំនួនអ្នកបកប្រែខ្លះ ។

ការចំណាយលើការប្រមែប្រមូលនិងបង្កើតភស្តុតាងសម្រាប់តុលាការកូនកាត់អាចនឹងត្រូវកាត់បន្ថយផងដែរ តាមរយៈការបន្ថយចំណាយលើការធ្វើដំណើរនិងធ្វើកិច្ចសហប្រតិបត្តិការដ៏ខ្លាំងក្លាជាសក្តានុពលជាមួយនឹងក្រុមអាជ្ញាធរជាតិ ។

ជាក់ស្តែងណាស់ ការចំណាយរបស់តុលាការព្រហ្មទណ្ឌក្នុងតំបន់គឺមានទំហំតិចតួច នៅពេលប្រៀបធៀបសាលាក្តីអន្តរជាតិនានា ដូចជាសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាជាមួយនឹងតុលាការកូនកាត់ ។ តុលាការកូនកាត់នៃប្រទេសស៊ីរ៉ាឡេអូនប្រើប្រាស់ថវិកាតិចជាង**ICTs** ដោយតុលាការនេះបានប្រើថវិកាសម្រាប់ឆ្នាំដំបូងចំនួន១៩លានដុល្លារ គឺប្រមាណជា១,៥ នៃថវិកាប្រចាំឆ្នាំរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ តាមការប៉ាន់ស្មាន តុលាការនេះប្រើប្រាស់ថវិកាសរុបអស់ប្រមាណជា៧៥លានដុល្លារសម្រាប់ឆ្នាំទីបី ។ ជាការពិតណាស់ កង្វះខាតថវិកាសម្រាប់ចំណាយលើតុលាការកូនកាត់នៃប្រទេសទីម័រខាងកើត បាននាំទៅរកភាពបរាជ័យយ៉ាងច្រើន(ថវិកាឆ្នាំ២០០១ របស់តុលាការកូនកាត់នៃប្រទេសទីម័រខាងកើតគឺមានត្រឹមតែ ៦,៣លានដុល្លារប៉ុណ្ណោះ ដែលក្នុងនោះ ប្រាក់ប្រមាណជា៦លានដុល្លារត្រូវបានចំណាយលើការវិនិច្ឆ័យទោស ហើយ ៣០ម៉ឺនដុល្លារអាមេរិកត្រូវបានប្រើប្រាស់សម្រាប់ដំណើរការតុលាការនេះតែម្តង) ។ ទោះជាយ៉ាងណាក៏ដោយ ការចំណាយខុសគ្នាៗដ៏គួរជាទីកត់សម្គាល់នេះ រវាងយន្តការអនុវត្តក្រៅប្រទេសដូចជា សាលាក្តីជាមួយនឹងតុលាការពិសេសរបស់ប្រទេសស៊ីរ៉ាឡេអូន គឺជាភស្តុតាងមួយដ៏រឹងមាំដែលបង្ហាញអំពីថវិកាសន្សំដែលអាចនឹងផ្តល់តាមរយៈការអនុវត្តច្បាប់ព្រហ្មទណ្ឌអន្តរជាតិក្នុងតំបន់ ដោយពុំធ្វើឲ្យប៉ះពាល់ទៅដល់លក្ខណៈសម្បត្តិរបស់តុលាការ ។ ថវិកាសន្សំទាំងនេះងាយនឹងបង្វែរទៅជាឆន្ទៈនយោបាយដ៏ខ្លាំងក្លាបន្ថែមទៀតរបស់រដ្ឋនានា នៅក្នុងការគាំទ្រចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ពីព្រោះក្តីព្រួយបារម្ភដែលកើតមានជាញឹកញាប់អំពីការចំណាយ គ្មានការត្រួតពិនិត្យត្រឹមត្រូវនឹងរលាយសាបសូន្យ ។

បញ្ហាហិរញ្ញវត្ថុគឺជាឧបសគ្គរួមចំណែកមួយធំចំពោះសាលាក្តីពិសេសនានា នៅក្នុងការបង្កើតនូវធម្មានុរូបក្នុងស្រុក ។ ការចំណាយដ៏ច្រើនសន្ធឹកសន្ធាប់របស់សាលាក្តីនៃប្រទេសរ៉្វាន់ដានិងយូហ្គោស្លាវីបង្កឲ្យមានភាពទោមនស្សខ្លាំងក្លាឡើងៗ ហើយការចំណាយរបស់សាលាក្តីទាំងពីរនេះទៀតសោត គឺធ្វើឲ្យប្រជាប្រិយភាពរបស់តុលាការកាន់តែធ្លាក់ចុះខ្លាំងជាលំដាប់នៅក្នុងចំណោមប្រជាជនដែលគាំទ្រលើសាលាក្តីនេះ ក៏ដូចជាការបរាជ័យនៅក្នុងការពង្រឹងវប្បធម៌យុត្តិធម៌ក្នុងប្រទេស ។

ការទិតៀនចំពោះសាលាក្តីពិសេសទាំងនេះ មិនថាដោយមធ្យោបាយណានោះទេគឺធ្វើឡើងក្នុងគោលបំណងថ្កោលទោសជាទូទៅចំពោះស្ថាប័នទាំងនេះ ដូច្នេះដើម្បីដឹងអំពីបរិមាណទាំងនេះគឺទាមទារឲ្យមានការស្វែងរកឲ្យបានគ្រប់គ្រាន់នូវរាល់ចំណុចខុសគ្នាបន្តិចបន្តួច និងអំណះអំណាងទាំងឡាយរបស់ភាគីទាំងសងខាងនៅក្នុងកិច្ចពិភាក្សាវែកញែកមួយ ។ តាមពិត យុត្តិសាស្ត្ររបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា រួមចំណែកយ៉ាងច្បាស់នៅក្នុងកិច្ចអភិវឌ្ឍន៍សំខាន់ៗ និងការពង្រីកបន្ថែម

លើច្បាប់មនុស្សធម៌អន្តរជាតិដែលនឹងកំណត់នូវយុត្តិសាស្ត្រដ៏មានតម្លៃមួយ ។ សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវីនិងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិរ៉្វាន់ដា គួរទទួលបាននូវការលើកសរសើរចំពោះការបំពេញតួនាទីជាអ្នកផ្សព្វផ្សាយនូវនិយាម និងការជំរុញឲ្យមានការផ្សព្វផ្សាយទូទាំងពិភពលោកនូវសិទ្ធិមនុស្សនិងច្បាប់អន្តរជាតិ ។ ឯកសារនេះមិនបានបង្ហាញឲ្យបានលម្អិតអំពីបញ្ហារិះគន់ទាំងនេះទេ ហើយនិយាយសង្កត់ធ្ងន់តែទៅលើសមត្ថភាពរបស់សាលាក្តីពិសេស ឬការខកខានមិនបានធ្វើទំនាក់ទំនងជាមួយនឹងប្រជាជនក៏ដូចជាស្ថាប័នក្នុងស្រុកដែលផ្តល់ឥទ្ធិពលជាវិជ្ជមាននៅក្នុងដំណើរការនេះប៉ុណ្ណោះ ។

តាមការសន្និដ្ឋាន សាលាក្តីអន្តរជាតិពិសេសអាចមានលទ្ធភាពពង្រឹងនូវកិច្ចប្រឹងប្រែងក្នុងយុទ្ធនាការផ្សព្វផ្សាយរបស់ខ្លួនបាននៅពេលដែលខ្លួនទទួលបាននូវការគាំទ្រខ្លាំងពីប្រជាជន និងអាចពង្រឹងឲ្យកាន់តែរឹងមាំនូវប្រព័ន្ធតុលាការក្នុងស្រុក ។ យោងតាមការសិក្សាជាក់ស្តែងមួយដែលស្ទង់មតិប្រជាជនក្នុងស្រុកអំពីថាតើសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃអតីតយូហ្គោស្លាវីអាចមានលើកកម្ពស់យុត្តិធម៌ ការទទួលខុសត្រូវនិងការស្តាបនាអតីតប្រទេសយូហ្គោស្លាវីឡើងវិញ បានគាំទ្រថាសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "គួរប្រកាន់យកនូវជម្រើសមួយ គឺថាសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ត្រូវដំណើរការជំនុំជម្រះក្តីនៅក្នុងទឹកដីប្រទេសប៊ូស្នៀនិងហឺហ្សេហ្គោវីណាដែលគាំទ្រដោយកម្មវិធីគាំពារយ៉ាងហ្មត់ចត់ចំពោះសាក្សី ចៅក្រម និងក្រុមអ្នកច្បាប់ទាំងឡាយ" ហើយ "ត្រូវពង្រីកកម្មវិធីផ្សព្វផ្សាយរបស់ខ្លួនឲ្យកាន់តែធំឡើង" ។ ការបង្កើននូវផ្នែកទំនាក់ទំនងសាធារណៈរបស់សាលាក្តីពិសេសអាចជួយបង្ការនូវហេតុផលសំខាន់បំផុតសម្រាប់តុលាការកូនកាត់ ។ ទោះជាយ៉ាងនេះក្តី សាលាក្តីអន្តរជាតិស្ទើរតែគ្មានលទ្ធភាពក្នុងការចុះផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយនិងធ្វើការជាមួយតុលាការក្នុងស្រុកដោយសារតែគ្មានធនធានសំខាន់នៅក្នុងស្រុក ឬដោយសារតែគ្មានការរួមបញ្ចូលគ្នាខ្លះៗរវាងឥទ្ធិពលក្នុងស្រុកនិងអន្តរជាតិ ដូច្នេះហើយតុលាការបានងាកទៅរករចនាសម្ព័ន្ធតុលាការកូនកាត់កាន់តែខ្លាំងឡើង ។


ប្រជាជនក្នុងភូមកភូមិក្រសាំង-១ កំពុងអានសេចក្តីណែនាំការចូលរួមនៃជនរងគ្រោះ

### ៦-តើតុលាការកូនកាត់និងតុលាការព្រហ្មទណ្ឌអន្តរជាតិអាចនៅជាមួយគ្នាដោយរបៀបណា?

ការបង្កើតឡើងនូវតុលាការព្រហ្មទណ្ឌអន្តរជាតិបាននាំមកនូវឥទ្ធិពលខ្លាំងមួយទៅលើយុត្តិធម៌អន្តរជាតិពិភពលោក ។ ក៏ប៉ុន្តែតុលាការនេះពុំមានលទ្ធភាពដោះស្រាយមួយផ្នែកនៃករណីឧក្រិដ្ឋកម្មសង្គ្រាមជាច្រើនរបស់ពិភពលោក ។ ដូច្នេះហើយ តុលាការកូនកាត់បានលេចរូបរាងឡើងដោះស្រាយករណីទាំងអស់នោះ ។ ជាការពិតណាស់ សក្តានុពលសម្រាប់ទំនាក់ទំនងរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការកូនកាត់បង្ហាញពីសារសំខាន់របស់តុលាការកូនកាត់ ។ តុលាការកូនកាត់មិនត្រឹមតែមិនបង្កការប៉ះពាល់ដល់តុលាការព្រហ្មទណ្ឌអន្តរជាតិប៉ុណ្ណោះទេ តែថែមទាំងមានភាពចាំបាច់សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិទៀតផង ។

*ក) តុលាការព្រហ្មទណ្ឌអន្តរជាតិមិនចាត់ទុកតុលាការកូនកាត់ថាគ្មានប្រយោជន៍ទេ*

មិនថាតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងតាមមធ្យោបាយណានោះទេ វានឹងកាត់បន្ថយសេចក្តីត្រូវការចំពោះ

តុលាការកូនកាត់ ។ សូម្បីតែអ្នកដែលចង់ឲ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិជាងសាលាក្តីអន្តរជាតិក៏បានសារភាពថា សាលាក្តីទាំងនេះពិតជាមានសារសំខាន់នៅក្នុងរយៈពេលខ្លីដែរ ដោយសារតែអាជ្ញាយុកាលរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនេះ ។ យោងតាមមាត្រា១១នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិចែងថា តុលាការព្រហ្មទណ្ឌអន្តរជាតិមានសមត្ថកិច្ចតែទៅលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តក្រោយពីសន្ធិសញ្ញាចូលជាធរមានប៉ុណ្ណោះ ។ ជាលទ្ធផល ពិភពលោកទាំងមូលជួបនូវបញ្ហាខ្វះចន្លោះខាងតុលាការចំពោះការបំពានលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលមុនពេលបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិឬប្រព្រឹត្តនៅក្នុងបណ្តាប្រទេសដែលមិនមែនជាហត្ថលេខីនៃសន្ធិសញ្ញានេះ ។

ជាការពិតណាស់ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទទួលស្គាល់ពីតម្លៃនៃដំណើរការកាត់ក្តីក្នុងស្រុកដោយសារខ្លួនផ្តល់អាទិភាពចំពោះនីតិវិធីច្បាប់ក្នុងស្រុក ។ លក្ខន្តិកៈនេះទទួលស្គាល់ពីបឋមភាពរបស់តុលាការជាតិ ដូចដែលបង្ហាញជាភ័ស្តុតាងនៅក្នុងសេចក្តីថ្លែងគោលការណ៍ដែលចែងថា តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាអ្នកបំពេញបន្ថែមលើយុត្តាធិការព្រហ្មទណ្ឌក្នុងប្រទេសប៉ុណ្ណោះ

គោលគំនិតនៃការបំពេញបន្ថែម គឺជាមូលដ្ឋានគ្រឹះមួយនៃការបង្កើតឡើងនូវលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បើទោះនៅក្នុងករណីមួយដែលស្ថិតក្រោមការពិនិត្យពិចារណារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ ការពិនិត្យជាក់ស្តែងទៅលើការចោទប្រកាន់ពីបទឧក្រិដ្ឋ គឺរដ្ឋជាអ្នកពិនិត្យនិងសម្រេច (មិនថារដ្ឋនោះជាភាគីឬមិនមែនជាភាគីនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិក៏ដោយ) ។ រឿងនោះមិនអនុញ្ញាតឲ្យធ្វើឡើងនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ថ្វីបើមានភាពល្បីល្បាញពីរឿងអំពើពុករលួយក៏ដោយ ក៏ការវិនិច្ឆ័យនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺគ្រាន់តែជាជម្រើសមួយក្នុងការបង្កើតនូវភាពទទួលខុសត្រូវប៉ុណ្ណោះ ហើយដែលគេត្រូវគិតពិចារណាក្នុងការដាក់បញ្ចូលករណីផ្សេងទៀតរបស់តុលាការដើម្បីដោះស្រាយរឿងក្តីដ៏ច្រើន ។

បើទោះជាស្ថិតនៅក្នុងករណីដែលអាចដោះស្រាយបានល្អបំផុតក៏ដោយ តុលាការព្រហ្មទណ្ឌអន្តរជាតិគ្រាន់តែអាចមានលទ្ធភាពកាត់ក្តីលើជនល្មើស សិទ្ធិមនុស្សមួយភាគតូចនៅក្នុងស្ថានភាពជាក់លាក់មួយប៉ុណ្ណោះ ។ សមត្ថភាពពិសេសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងការចាត់ចែងដំណើរការកាត់ក្តីថ្មីៗទៅលើឧក្រិដ្ឋជនកំពូលៗចោទជាសំណួរមួយថា តើករណីតូចៗមិនសំខាន់ផ្សេងទៀតនឹងត្រូវធ្វើឡើងនៅក្នុងតុលាការណាមួយ? នៅក្នុងន័យនេះ យន្តការកូនកាត់អាចត្រូវបានចាត់ទុកជាផ្នែកបំពេញបន្ថែមដ៏មានប្រយោជន៍មួយចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ប្រសិនបើការកាត់ទោសអ្នកដែលទទួលខុសត្រូវចំពោះការបំពានលើសិទ្ធិមនុស្ស ទ្រង់ទ្រាយធំត្រូវអនុវត្តទៅតាមច្បាប់ដោយពុំមានករណីលើកលែងនោះ ដូច្នេះជំនួយអន្តរជាតិត្រូវតែប្រុងប្រយ័ត្ន... 

ផ្នែកតាមទំនាក់ទំនងដែលគ្មានជម្លោះរវាងតុលាការកូនកាត់នៃប្រទេសកូសូវ៉ូ និងប៊ូស្នៀ និងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបង្ហាញឲ្យដឹងថា តុលាការកូនកាត់មិនចាំបាច់ប្រើជំនួសប្រព័ន្ធយុត្តិធម៌អន្តរជាតិ ( ឬប្រព័ន្ធយុត្តិធម៌ក្នុងស្រុកទេ) ។ ជាក់ស្តែង សាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានជួយឲ្យតុលាការឧក្រិដ្ឋកម្មសង្គ្រាមរបស់ប៊ូស្នៀទទួលបានកាន់តែច្រើនឡើងនូវព័ត៌មានដែលមិនមានភាពសម្ងាត់របស់សាលាក្តីនេះ ។

ក្រុមអយ្យការនីមួយៗនៅក្នុងផ្នែកឧក្រិដ្ឋកម្មសង្គ្រាមពិសេសរបស់ប៊ូស្នៀ បានទទួលនូវលេខកូដសម្ងាត់ ដើម្បីអាចឆែកមើលសំណុំភ័ស្តុតាងដែលបានលាតត្រដាង (EDS) របស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់យូហ្គោស្លាវី... មិនត្រឹមតែប៉ុណ្ណោះថ្មីៗនេះមានសំណូមពរឲ្យផ្តល់ការអនុញ្ញាតចូលឆែកមើលប្រព័ន្ធទិន្នន័យតុលាការ (JDB) ដែលទិន្នន័យនេះនឹងជួយសម្រួលដល់ដំណើរការស្វែងរកសាលក្រម សេចក្តីសម្រេច និងដីកានានាដែលចេញដោយសាលាក្តី ។

ការិយាល័យព្រះរាជអាជ្ញារបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់យូហ្គោស្លាវី បានបង្កើតកិច្ចសហប្រតិបត្តិការជាផ្លូវការ

ជាមួយផ្នែកឧក្រិដ្ឋកម្មសង្គ្រាម ពិសេសតាមរយៈអនុស្សរណៈនៃការយោគយល់គ្នាមួយ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៥ ហើយគ្រោងនឹងបង្កើតមួយផ្សេងទៀត ។ កិច្ចសហប្រតិបត្តិការដ៏ពិសេសនេះគប្បីហៅថាជានិមិត្តរូបគំរូមួយ ។

នៅក្នុងករណីដែលតុលាការកូនកាត់មានតួនាទីត្រួតគ្នាជាមួយនឹងសាលាក្តីអន្តរជាតិ តុលាការកូនកាត់ត្រូវទទួលបន្ទុកកាត់ក្តីឧក្រិដ្ឋជនសង្គ្រាមកំពូលៗ ដែលសាលាក្តីអន្តរជាតិពុំមានសមត្ថកិច្ចលើដំណើរការក្តី ។ វាអាចជាចំនួនដ៏ច្រើនបំផុត ព្រោះថាសាលាក្តីអន្តរជាតិធ្វើការជំនុំជម្រះក្តីតែទៅលើមនុស្សមួយក្តាប់តូចដែលត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋក្រោមយុត្តាធិការរបស់តុលាការប៉ុណ្ណោះ ដូច្នេះហើយបានជាបណ្តោយឲ្យឧក្រិដ្ឋជនភាគច្រើន ជាពិសេសឧក្រិដ្ឋជនកំពូលៗទទួលបាននូវសេរីភាពពេញលេញ ។

### ១) តុលាការកូនកាត់មិនកាត់បន្ថយនូវតម្រូវការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

ផ្អែកតាមទិដ្ឋភាពច្បាប់ដ៏ពិតប្រាកដ តុលាការកូនកាត់នឹងមិនដកហូតនូវយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយសារតែគោលការណ៍នៃការបំពេញឲ្យគ្នាទៅវិញទៅមកនោះទេ គឺវាគ្រាន់តែផ្តល់នូវយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងករណីដែលតុលាការក្នុងស្រុក «គ្មានឆន្ទៈ» ឬ«អសមត្ថភាព» ក្នុងការដំណើរការក្តីណាមួយប៉ុណ្ណោះ ។ តុលាការកូនកាត់មិនមែនជាធាតុពិតប្រាកដមួយនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុកនោះទេ ព្រោះតាមនិយមន័យកំណត់ថា តុលាការនេះជាបន្សំរវាងតុលាការក្នុងស្រុក/អន្តរជាតិ ។ ដូច្នេះហើយ ប្រសិនបើតុលាការក្នុងស្រុកពុំអាចកាត់ទោសលើបទឧក្រិដ្ឋកម្រិតធ្ងន់នោះ តុលាការកូនកាត់អាចនឹងត្រូវបង្កើតឡើងដើម្បីដំណើរការក្តីរួមគ្នាជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិ បើទោះជាយោងតាមគោលការណ៍របស់ *resjudicata* ការកាត់ទោសជនជាប់ចោទពុំអាចធ្វើឡើងពីរដងក៏ដោយ ដោយមានគណៈវិនិច្ឆ័យចម្រុះដែលទទួលបន្ទុកដោះស្រាយក្តីមួយចំនួន តែមិនមែនដោះស្រាយលើករណីដទៃទៀតនោះ ជាតួយ៉ាងការកាត់ទោសជនក្រោមបង្គាប់ ឋានៈកណ្តាលមិនមែនមេដឹកនាំកំពូលទេ ។ ម្យ៉ាងវិញទៀត រដ្ឋមួយដែលមិនចង់ដំណើរការក្តីណាមួយឬមិនចង់ឃើញការជម្រះក្តីនោះនៅក្នុងតុលាការកូនកាត់ដែលមានស្រាប់អាចនឹងប្រគល់ចំណាត់ការក្តីនោះទៅដល់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ស្ថានការណ៍ជាច្រើនអាចនឹងកើតឡើងហួសពីព្រំដែននៃសមត្ថភាពប្រកបដោយសក្តានុពលរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិនិងតុលាការកូនកាត់ នៅក្នុងករណីដែលពាក់ព័ន្ធនឹងទង្វើឃោរឃៅយង់ឃ្នងដូចគ្នាមកលើមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ខណៈដែលក្រុមអ្នកផ្តល់ជំនួយនឹងចូលពាក់ព័ន្ធនិងមិនបានផ្តល់មូលនិធិដល់សាលាក្តីកូនកាត់ ។ នៅក្នុងបរិបទនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិមានតួនាទីជាគោលនយោបាយមួយធានារ៉ាប់រងប្រឆាំងនឹងការផ្លាស់ប្តូរនិងនយោបាយពិភពលោកដែលប្រកាន់យកសីលធម៌តាមទំនើងចិត្ត ដែលរហូតទៅដល់ការបង្កើតសាលាក្តីពិសេសដោយឡែកឯងនៅក្នុងប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវី ហើយបានទុកឲ្យតំបន់មួយចំនួនដែលកើតមានជម្លោះខ្លាំងឬដែលបោះបង្គោលជាសញ្ញាមិនសូវមានអាទិភាពខាងនយោបាយ ដូចជា នៅ *Darfur* ឬ*Chechnya* កំពុងទទួលរងនូវអំពើដ៏ឃោរឃៅដែលគ្មានសង្ឃឹមថានឹងទទួលបានការផ្តល់យុត្តិធម៌ពីអន្តរជាតិ ។ នៅក្នុងករណីខ្លះ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចធ្វើចំណាត់ការដោយឯករាជ្យជាសាកលមួយលើរឿងក្តីធ្ងន់ធ្ងរនៅក្នុងកាលៈទេសៈដែលអង្គការសហប្រជាជាតិខ្វះនូវឆន្ទៈនយោបាយក្នុងការបង្កើត



សកម្មភាពបំពេញពាក្យបណ្តឹងរបស់ប្រជាជនក្នុងភូមិទំពេជ ខេត្តកំពង់ធំ

តុលាការកូនកាត់ ឬក្នុងករណីដែលភាគីពាក់ព័ន្ធក្នុងស្រុកធ្វើការប្រឆាំងចំពោះការបង្កើតឡើងនូវតុលាការកូនកាត់នេះ ។ សូម្បីតែនៅក្នុងកាលៈទេសៈដែលរដ្ឋក្រោយជម្លោះប្រដាប់អាវុធនិងពីសំណាក់អ្នកមានអំណាចកំពូលប្រកបដោយឥទ្ធិពល ទំនងជាមានឆន្ទៈរួមគ្នាក្នុងការកាត់ទោសឧក្រិដ្ឋជនកំពូលៗដែលមានតួនាទីទទួលខុសត្រូវចំពោះទង្វើដ៏ព្រៃផ្សៃរបស់ខ្លួនក៏ដោយ ការអំពាវឲ្យមានដំណើរការក្តីក្នុងស្រុក តុលាការកូនកាត់ ជួនកាលមិនអាចធ្វើទៅបានដោយសារតែដំណើរការកាត់ទោសឧក្រិដ្ឋជនសង្គ្រាមប្រកបដោយគ្រោះថ្នាក់និងដ៏មានអំណាចខ្លាំងក្លាបំផុត ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងប្រកាន់នូវគោលជំហរក្នុងការកាត់ក្តីអំពើហិង្សាខាងនយោបាយដ៏លេចធ្លោ តាមមធ្យោបាយមួយដែលតុលាការក្នុងស្រុក ឬសូម្បីតែតុលាការកូនកាត់មិនអាចធ្វើទៅរួចដោយសារតែការគំនាបដែលមិនអាចទ្រាំទ្របានដែលតុលាការទាំងនេះអាចជួបប្រទះ ។

*គ) បញ្ហាក្នុងទំនាក់ទំនងរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិនិងប្រជាជនក្នុងស្រុកបង្កើតនូវតម្រូវការតុលាការកូនកាត់*

តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងជួបនូវឧបសគ្គខាងភាសានិងវប្បធម៌នៅក្នុងការប្រាស្រ័យទាក់ទងប្រជាជនក្នុងស្រុក ហើយអាចនឹងពឹងពាក់លើអង្គភាពមួយដែលមានសមត្ថភាពជាងខ្លួនក្នុងកិច្ចទំនាក់ទំនងជាមួយប្រជាជនក្នុងស្រុក ។ លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសង្កត់ធ្ងន់ទៅលើការចុះទំនាក់ទំនង ជាតួយ៉ាងក្នុងគោលបំណងស្វែងរកលទ្ធភាពបង្កើតមូលដ្ឋានតុលាការនៅក្នុងតំបន់ ។ បើទោះជាតុលាការព្រហ្មទណ្ឌអន្តរជាតិមានមូលដ្ឋាននៅក្នុងទីក្រុងឡាអេក៏ដោយ យោងតាមមាត្រា៣នៅក្នុងលក្ខន្តិកៈក្រុងរ៉ូមចែងថា តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានអនុញ្ញាតឲ្យផ្លាស់ទីតាំងរបស់ខ្លួនទៅកាន់កន្លែងមួយទៀតនៅក្នុងស្ថានការណ៍ពិសេសដូចជា ទៅកាន់ប្រទេសឬតំបន់មួយដែលអំពើព្រៃផ្សៃបានប្រព្រឹត្តឡើងនៅទីនោះ ។ យ៉ាងណាមិញ ថ្វីបើក្រុមអ្នកធ្វើសេចក្តីសម្រេចនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិបានដឹងអំពីសារសំខាន់នៃការប្រាស្រ័យទាក់ទងតាមរយៈការបរាជ័យរបស់សាលាក្តីពិសេសក៏ដោយ ក៏ការព្រួយបារម្ភទាំងឡាយអាចនឹងកើតឡើង ។ ដោយផ្អែកតាមទស្សនៈរបស់ប្រជាជនភាគច្រើនដែលរស់នៅក្នុងបណ្តាប្រទេសក្រោយរបបដ៏ឃោរឃៅ តុលាការព្រហ្មទណ្ឌអន្តរជាតិហាក់ដូចជាពុំសូវមានគេស្គាល់ដដែល ដោយសារមានជាបុគ្គលិកបរទេសធ្វើការនៅក្នុងទឹកដីដែលស្ថិតនៅឆ្ងាយ ហើយប្រើភាសាដែលពិបាកស្តាប់ ព្រមទាំងអនុវត្តនូវច្បាប់ដែលអ្នកស្រុកពុំបានដឹងឮពីមុន ។ លើកលែងតែមានបញ្ញត្តិចែងនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិស្តីពីការចូលរួមយ៉ាងខ្លាំងក្លាពីសំណាក់ជនរងគ្រោះ និងការប្តេជ្ញាចិត្តរបស់រដ្ឋអាជ្ញា *Luis Moreno Ocampo* ក្នុងការប្រាស្រ័យទាក់ទងជាមួយក្រុមអ្នកពាក់ព័ន្ធ ពុំដូច្នេះទេ តុលាការព្រហ្មទណ្ឌអន្តរជាតិអាចនឹងស្ថិតក្នុងសភាពដូច *deus ex machina* ខ្លាំងជាងសាលាក្តីពិសេសទៅទៀត មិនត្រឹមតែប៉ុណ្ណោះអាចនឹងមិនដឹងអំពីតថភាពនៅក្នុងតំបន់ទៀតផង ។

ដោយមើលឃើញនូវសារសំខាន់នៃការចុះទំនាក់ទំនងយ៉ាងទូលំទូលាយនៅក្នុងបណ្តាប្រទេសក្រោយរបបគ្រប់គ្រងដ៏ព្រៃផ្សៃក្នុងទិសដៅដើម្បីបង្កើតនូវវប្បធម៌នៃការទទួលខុសត្រូវនិងការគោរពសិទ្ធិមនុស្ស តុលាការព្រហ្មទណ្ឌអន្តរជាតិអាចគ្រាន់តែជាភាគីមួយនៅក្នុងល្បែងប៉ុណ្ណោះ ដូច្នេះហើយយើងមិនអាចទាមទារឲ្យតុលាការផ្តល់នូវដំណោះស្រាយទាំងស្រុងនោះទេ ។

## ៧) សេចក្តីសន្និដ្ឋាន

ការមានចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ក្រុមឧក្រិដ្ឋជនដែលប្រព្រឹត្តបទល្មើសដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌និងសិទ្ធិមនុស្ស បានជំរុញទៅដល់ការបង្កើតនូវវេទិកាតុលាការអន្តរជាតិជាច្រើន ។ ខណៈដែលយន្តការរបស់ស្ថាប័នក្នុងការផ្តន្ទាទោសលើទង្វើដ៏ព្រៃផ្សៃត្រូវបានបង្កើតឡើងជាហូរហែ រាប់ចាប់ពីការជម្រះក្តីក្នុងស្រុករហូតដល់សាលាក្តីកូនកាត់និងតុលាការអន្តរជាតិ ការអភិវឌ្ឍនិងការកែលម្អនូវយន្តការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាពខ្លាំងឡើងគឺកាន់តែមានសារសំខាន់ជាចាំបាច់ ។

អាណត្តិរបស់សាលាក្តីអន្តរជាតិពិសេសទំនងជានឹងត្រូវកំណត់ ដែលភាគច្រើនគឺដោយសារតែអ្នកផ្តល់ជំនួយនឿយណាយយ៉ាងខ្លាំងចំពោះការចំណាយរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃប្រទេសយូហ្គោស្លាវីនិងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៃប្រទេស

វ៉ាន់ដា បើទោះជាមិនមានការរិះគន់ចំពោះភាពទន់ខ្សោយ និងអសមត្ថភាពរបស់ខ្លួនដែលសាលាក្តីទាំងនេះសមនឹងទទួល នៅក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយប្រជាជនក្នុងស្រុកក៏ដោយ ។ សាលាក្តីទាំងពីរនេះត្រូវបានបង្កើនល្បឿនប្រតិបត្តិការក្នុងក្តីសង្ឃឹមដើម្បីបញ្ចប់ការងាររបស់ខ្លួន ។ ទ្រនិចនាឡិកាបន្លឺសូរកាន់តែញាប់ឡើងៗ ដើម្បីស្វែងរកអ្វីផ្សេងមកជំនួសសាលាក្តីពិសេស ។

ទន្ទឹមនឹងការបាត់មុខមាត់របស់សាលាក្តីពិសេសនៅលើឆាកតុលាការថ្នាក់ជាតិជាច្រើនគ្មានសមត្ថភាពដោះស្រាយករណីនៃអំពើដ៏ព្រៃផ្សៃកម្រិតធ្ងន់ធំៗតែម្នាក់ឯងបាន ក៏ដូចជាធនធានដ៏ស្តួចស្តើង ព្រមទាំងដែនយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូច្នេះយើងត្រូវតែទទួលស្គាល់និងគាំទ្រតុលាការកូនកាត់ដែលជាទម្រង់ថ្មីដ៏ល្អបំផុតមួយសម្រាប់ប្រព័ន្ធតុលាការអន្តរកាល ។ ការយកគំរូតុលាការកូនកាត់ គឺផ្តល់នូវជោគជ័យកាន់តែខ្លាំងថែមទៀតក្នុងការប្រឆាំងនឹងវប្បធម៌និទ្ទណ្ឌភាព នៅពេលផ្សារភ្ជាប់ទៅនឹងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។ អាណត្តិរបស់តុលាការកូនកាត់ត្រូវមានរយៈពេលវែងជាងមុន ដើម្បីជំរុញទៅដល់ការធ្វើកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក ឧទាហរណ៍តាមរយៈកម្មវិធី *CLE* កម្មវិធីបង្ហាត់បង្រៀន ឬកម្មវិធីអ្នកសង្កេតការណ៍លើដំណើរការក្តីជាដើម ។ល ។ ការរៀបចំឲ្យមានប្រព័ន្ធយុត្តិធម៌ថ្នាក់ជាតិដើម្បីសង្កេតតាមដាននិងផ្តន្ទាទោសឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងរបបប្រល័យពូជសាសន៍ គឺជាការពង្រឹងនូវសមត្ថភាពរបស់ប្រព័ន្ធច្បាប់ក្នុងស្រុកដើម្បីផ្តល់នូវយុត្តិធម៌ក្នុងរយៈពេលយូរអង្វែង ។ ការចូលរួមយ៉ាងផុសផុលជាមួយនឹងស្ថាប័នច្បាប់ និងវប្បធម៌ក្នុងស្រុកអាចពង្រឹងនូវការឆ្លើយតប និងភាពទទួលខុសត្រូវជាសាកលដែលពិតនិងប្រកបដោយប្រសិទ្ធភាព ។

ប្រព័ន្ធយុត្តិធម៌មិនត្រឹមតែសម្អាងទៅលើសកម្មភាពអនុវត្តជាក់ស្តែងនានា ដូចជា ការចាប់ខ្លួនឧក្រិដ្ឋជនណាម្នាក់ ឬក្រុមឧក្រិដ្ឋជនណាមួយមកទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែត្រូវស្ថិតនៅក្នុងចិត្តរបស់មនុស្សផងដែរ ។ ប្រជាជនក្នុងស្រុកត្រូវតែទទួលយកនូវយន្តការនៃការដាក់ឲ្យទទួលខុសត្រូវចំពោះទង្វើដែលបានប្រព្រឹត្តនៅក្នុងតំបន់ក្រោយអំពើព្រៃផ្សៃនានាដែលជាការរួមបញ្ចូលទាំងស្មារតីនិងវប្បធម៌ច្បាប់ក្នុងតំបន់ ។ ថ្វីបើតុលាការកូនកាត់មិនបានធានាដោយស្វ័យប្រវត្តិនូវទំនាក់ទំនងល្អជាមួយប្រជាជនក្នុងស្រុកក៏ដោយ ប៉ុន្តែរចនាសម្ព័ន្ធដ៏រឹងមាំរបស់តុលាការបានជួយសម្រួលដល់ការជួបទំនាក់ទំនងជាមួយប្រជាជនក្នុងតំបន់ ។ អាស្រ័យហេតុនេះ តុលាការកូនកាត់ផ្តល់នូវការបញ្ចូលគ្នារវាងអំណាចដ៏មានសក្តានុពលនៃភាពស្របច្បាប់ជាអន្តរជាតិនិងការស្វែងយល់នៅតាមតំបន់ ។ ការសិក្សារបស់តុលាការកូនកាត់នានាគួរតែរំកិលទៅរកការពិភាក្សាប្រកបដោយអត្ថន័យរវាងសាស្ត្រាចារ្យនិងអ្នកប្រកបវិជ្ជាជីវៈដើម្បីរិះរកមធ្យោបាយថាតើត្រូវសម្របយន្តការនៃការទទួលខុសត្រូវដោយរបៀបណាទៅនឹងស្ថានភាពខុសប្លែកគ្នានៃប្រទេសនីមួយៗក្រោយអំពើព្រៃផ្សៃ? សាលាក្តីទាំងនេះអាចសម្រេចយ៉ាងពេញទំហឹងនូវសក្តានុពលភាពរបស់ខ្លួនបាន តែនៅពេលដែលមានការសិក្សាប្រៀបធៀបយ៉ាងល្អិតល្អន់រវាងគំរូតុលាការកូនកាត់និងតុលាការចម្រុះដែលមានស្រាប់ប៉ុណ្ណោះ ។ នៅក្នុងការស្វែងរកយន្តការផ្សេងៗរបស់យើង ដើម្បីលុបបំបាត់នូវនិទ្ទណ្ឌភាពនិងដើម្បីស្វែងរកនូវយុត្តិធម៌ជូនជនរងគ្រោះដែលគួរទទួលបាននូវយុត្តិធម៌ទាំងនោះ យើងត្រូវតែយកចិត្តទុកដាក់ទៅលើការសន្យារបស់តុលាការកូនកាត់ ។



សកម្មភាពបំពេញពាក្យបណ្តឹងរបស់ប្រជាជនក្នុងភូមិទំពេជ នៅខេត្តកំពង់ធំ

**អេរីតែល ហ៊ីហ្គូនេត**

# ទំនាក់ទំនងចិន-កម្ពុជា

*ការពិពណ៌នាលើកដំបូងបង្អស់អំពីអង្គរវត្តដែលមានភាពរីកចម្រើនដល់កំពូលរបស់ខ្លួន ត្រូវបានរកឃើញនៅក្នុង «កំណត់ហេតុអំពីប្រពៃណីទំនៀមទម្លាប់របស់កម្ពុជា» របស់លោក ហ្ស៊ូ ដាក្វាង ឬ ជាវ តាក្វាន់ ។*

*លោក ជាវ មានដើមកំណើតជាជនជាតិយុងជាវ នៅខេត្តចេកៀង (ហ្សឺចាង) ដែលជាខេត្តដែនសមុទ្រភាគនិរតីរបស់ចិន ហើយត្រូវបានចាត់តាំងឲ្យទៅធ្វើរាជទូតរបស់ប្រទេសចិននៅអំឡុងឆ្នាំ១២៩៦ និង ឆ្នាំ១២៩៧ ដោយបានចំណាយពេលស្ទើរពេញមួយឆ្នាំក្នុងការធ្វើដំណើរពេញទាំងប្រទេសកម្ពុជា ។ បន្ទាប់ពីត្រឡប់ទៅស្រុកវិញ លោក ជាវ បានសរសេរនូវកំណត់ហេតុរបស់គាត់ដែលត្រូវបានយកទៅបោះពុម្ពផ្សាយមុនឆ្នាំ១៣១២ ។ មុនការដួលរំលំនៃរាជវង្សម៉ុងហ្គោលតែបន្តិច (ឆ្នាំ១៣៦៨) កំណត់ហេតុរបស់លោក ជាវ ត្រូវបានដាក់បញ្ចូលទៅក្នុងការចងក្រងមួយដែលមានកម្រាស់ដល់ទៅរាប់រយជំពូក ដែលភាគច្រើនគឺជាការដកស្រង់ទាំងស្រុង ហើយត្រូវបានបោះពុម្ពទៅជា «ហ្ស៊ូហ៊ូ» ។ ទោះបីជាយ៉ាងនេះក្តី កំណត់ហេតុរបស់គាត់ត្រូវបានបោះពុម្ពក្រោមទឹកខ្មៅរបស់គាត់ដែលមានឈ្មោះ តៅគីងអ៊ីមីង ។*

*នៅអំឡុងពេលនោះ ប្រទេសកម្ពុជាត្រូវបានចិនស្គាល់ថា ចេនឡានិងអ្នករស់នៅចេនឡាហៅថា កម្ពូជីញ ឬកាំបូជ្យា ។ លោក ជាវ តាក្វាន់ បានរៀបរាប់យ៉ាងសន្ទឹកសន្ធាប់និងរស់រវើកអំពីប្រពៃណីទំនៀមទម្លាប់ ការរស់នៅរបស់ប្រជាជន ប្រជាជនដែលតាំងទីនៅ ភាសានិងគម្ពីរសាសនារបស់ប្រទេសដែលបច្ចុប្បន្នហៅថាកម្ពុជានេះឯង ។*

*សូមត្រឡប់មកនិយាយពីសម័យទំនើបវិញម្តង ។ មានសំណួរជាច្រើនចោទសួរខ្ញុំថា ហេតុអ្វីបានជាព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិនមានទំនាក់ទំនងយ៉ាងស្អិតរមួតតាំងតែពីទសវត្សរ៍ឆ្នាំ១៩៥០មក ហើយដែលអាចមានទំនាក់ទំនងរហូតមកនៅក្នុងបរិស្ថាននយោបាយនៃប្រទេសទាំងពីរយ៉ាងដូច្នេះ ។*

*តាមពិត ប្រសិនបើក្រឡេកមើលតែមួយភ្លែត កម្ពុជានិងចិនហាក់ដូចជាមានភាពដូចគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ ចិន គឺជារដ្ឋមួយនៅអាស៊ីភាគខាងកើតដែលមានចំនួនប្រជាជនច្រើនជាងគេបង្អស់លើពិភពលោក ហើយដែលលេចធ្លោឡើងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ជាមហាអំណាចខាងយោធានិងសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។ ចំណែកឯកម្ពុជាវិញជាព្រះរាជាណាចក្រតូចមួយនៅអាស៊ីអាគ្នេយ៍ដែលតស៊ូរស់ទាំងត្រដាបត្រដួសក្រោយសង្គ្រាមជាច្រើនឆ្នាំ ការឈ្លានពានរបស់បរទេស ព្រមទាំងរបបប្រល័យពូជសាសន៍ខ្មែរក្រហមជាបន្តមកទៀត ។*

*ទំនាក់ទំនងដ៏ជិតស្និទ្ធរបស់កម្ពុជាជាមួយចិនបានចាប់ផ្តើមមានតាមរយៈការប្រជុំមួយនិងការសន្ទនាដ៏វែងអន្លាយរវាងសម្តេចព្រះ នរោត្តម សីហនុ ដែលកាលណោះលោកធ្វើជាព្រះប្រមុខរដ្ឋនៃកម្ពុជាជាមួយនឹងនាយករដ្ឋមន្ត្រីក្រោយរបបសាធារណរដ្ឋប្រជាមានិតចិន គឺលោក ជូ អេនឡាយ នៅក្នុងក្របខ័ណ្ឌការងារនៅសន្និសីទបាន់ឌុង នៅប្រទេសឥណ្ឌូនេស៊ី ឆ្នាំ១៩៥៥ ។*

*មុនការប្រជុំបាន់ឌុង ព្រះមហាក្សត្រ នរោត្តម សីហនុ ត្រូវបានទូលជាដំណឹងប្រាប់ដោយអ្នកតំណាងរបស់ព្រះអង្គនៅឯសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ ស្តីអំពីឥណ្ឌូចិនថា ឥរិយាបថចិនគឺគោរពនូវអធិបតេយ្យភាពរបស់ប្រទេសផ្សេងៗ ។ នៅក្នុងសន្និសីទនោះ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បានអន្តរាគមន៍ជួយបញ្ចុះបញ្ចូលប្រតិភូវៀតណាមខាងជើងឲ្យទទួលស្គាល់កម្ពុជា គោរពបូរណភាពដែនដីកម្ពុជា និងឲ្យដកកងទ័ពរបស់ខ្លួនចេញពីទឹកដីកម្ពុជា ។*

*ចំពោះសម្តេចព្រះ នរោត្តម សីហនុ នៃកម្ពុជា នេះគឺជាព្រះរាជកិច្ចនិងសេចក្តីប្រាថ្នាដ៏សំខាន់បំផុតក្នុងមួយជីវិតព្រះអង្គដែលបានធ្វើចំពោះជាតិ ទីមួយនិងសំខាន់ជាងគេ ការសម្រេចបានយ៉ាងពេញលេញនិងការពារបានក្នុងគ្រប់កាលៈទេសៈនូវឯករាជ្យភាពនៃកម្ពុជានិងបូរណភាពទឹកដី ទីពីរការសម្រេចបានសន្តិភាពនិងស្ថិរភាពតាមរយៈការឯកភាពជាតិ និងផ្សះផ្សា ហើយទីបីការ*

នាំប្រទេសរបស់ព្រះអង្គចាកចេញពីភាពក្រីក្រជាបណ្តើរតាមរយៈកិច្ចប្រឹងប្រែងរបស់ប្រជាជនគ្រប់រូប ទាំងបុរស ទាំងស្ត្រី ។

លើសពីនេះទៅទៀត ខ្ញុំមានអារម្មណ៍ថា ការដឹកនាំប្រទេសនីមួយៗនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ នៅពេលដែលទំនាក់ទំនងទ្វេភាគីចាប់មានឡើង មានចក្ខុវិស័យរឹងមាំអំពីអនាគតរបស់ប្រទេសខ្លួន បើទោះបីជាទស្សនៈនយោបាយមានលក្ខណៈខុសគ្នាខ្លាំងយ៉ាងណាក៏ដោយ ។

សម្តេច នរោត្តម សីហនុ មានព្រះហឫទ័យខ្លាំងលើការតស៊ូដែលដឹកនាំដោយលោកប្រធាន ម៉ៅ សេទុង និងលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលនៅក្នុងគំនិតអ្នកដឹកនាំខ្មែរបានចាត់ទុកជាគំរូតស៊ូរបស់មហាប្រជាជនចិនដើម្បីបុព្វហេតុឯករាជ្យ ឯកភាពជាតិ និងបូរណភាពទឹកដីពេញលេញនៃប្រទេសចិន ។

ព្រះអង្គក្នុងព្រះនាមជាមេដឹកនាំនៃកម្ពុជាវ័យក្មេង មានព្រះតម្រិះថា ការតស៊ូរបស់ប្រជាជនចិនគឺជាគំរូដ៏ប្រសើរមួយ ហើយថាប្រទេសកម្ពុជារបស់ព្រះអង្គ រួមទាំងព្រះអង្គផ្ទាល់ អាចធ្វើមិនចាញ់គ្នាប៉ុន្មានទេ ទោះក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីសម្រេចបានឯករាជ្យនិងបូរណភាពទឹកដីពេញលេញសម្រាប់ព្រះរាជាណាចក្ររបស់ព្រះអង្គ ។

ក្នុងឆ្នាំ១៩៥៥ បន្ទាប់ពីការប្រជុំនៅបាន់ឌុង សម្តេច សីហនុ បានសម្រេចមួយជំហានទៅមុខទៀតដោយទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន តាមរយៈផ្តាច់ទំនាក់ទំនងការទូតជាមួយតៃវ៉ាន់ ដែលប្រទេសកម្ពុជាបានកសាងឡើង បន្ទាប់ពីប្រទេសទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ។

នៅពេលដែលសម្តេច សីហនុ ធ្វើព្រះរាជទស្សនកិច្ចនៅចិនក្នុងខែកុម្ភៈ ឆ្នាំ១៩៥៦ លោកប្រធាន ម៉ៅ បានកោតសរសើរនយោបាយរបស់ព្រះអង្គលើបញ្ហាសន្តិភាពនិងអព្យាក្រឹតភាពដោយថ្លែងថា នយោបាយបែបនេះមានឥទ្ធិពលដ៏សម្បើមនៅលើពិភពលោក ។ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បានសង្កត់ធ្ងន់លើគោលការណ៍ស្មើភាពរវាងរដ្ឋទាំងអស់នៅក្នុងកិច្ចការអន្តរជាតិដោយមិនគិតពីរដ្ឋនោះតូចឬធំឡើយ ។

សេចក្តីថ្លែងការណ៍រួមដែលធ្វើឡើងនៅពេលចុងបញ្ចប់នៃព្រះរាជទស្សនកិច្ចរបស់សម្តេច សីហនុ មានខ្លឹមសារថា ប្រទេសទាំងពីរគាំទ្រលើគោលការណ៍រួមរស់ដោយសន្តិសហវិជ្ជមានទាំង៥ ជាជាបន្ទាត់នយោបាយសម្រាប់ទំនាក់ទំនងរវាងកម្ពុជា-ចិន ។ ប្រទេសកម្ពុជាបានក្លាយជាប្រទេសមិនមែនសង្គមនិយមទី១ដែលទទួលបានជំនួយផ្នែកសេដ្ឋកិច្ចដោយឥតសំណងពីសំណាក់ប្រទេសចិន សម្រាប់ការសាងសង់រោងចក្រតម្បាញ ស៊ីម៉ង់ និងក្រដាស ការសាងផ្លូវ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងជួយកែលម្អអគារសុខភាពនិងសិក្សារបស់ព្រះរាជាណាចក្រនេះ ។

ក្នុងដំណើរទស្សនកិច្ចមកកាន់កម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ១៩៥៦ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បញ្ជាក់សាជាថ្មីអំពីការគោរពរបស់ចិនលើអព្យាក្រឹតរបស់កម្ពុជា និងព្យាយាមបន្ថយកង្វល់របស់កម្ពុជាដែលថា ចិននឹងស្វែងរកការគ្រប់គ្រងលើកម្ពុជាដោយប្រយោលតាមរយៈឥទ្ធិពលជំនួញរបស់ចិន និងរបស់មេដឹកនាំចិន និងអ៊ីផ្សេងៗទៀតដែលប្រជាជនចិននៅកម្ពុជាមានចំនួនដល់ទៅ៤សែននាក់ មុនឆ្នាំ១៩៧០ ។ លោក ជូ បានស្នើសុំឲ្យមានការស្មោះត្រង់ជាមួយកម្ពុជា ។

សម្រាប់ប្រទេសចិនវិញ កម្ពុជាគឺជាគំរូមួយឥតខ្ចោះអំពីនយោបាយការបរទេសដែលសាធារណរដ្ឋប្រជាមានិតបានប្រកាសក្តែងៗ បន្ទាប់ពីខ្លួនបានទាមទារដោយឈរលើគោលការណ៍រស់នៅដោយសន្តិសហវិជ្ជមានទាំង៥ ។ ព្រមជាមួយនោះ ការគាំទ្រអព្យាក្រឹតភាពរបស់កម្ពុជាដោយមេដឹកនាំចិននៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ គឺជាការចេញដំណើរដ៏មានសារៈសំខាន់ពីទ្រឹស្តីផ្តាច់ការដែលថ្លែងដោយ «សមភាគី» ដែលតាមរយៈទ្រឹស្តីនេះ លោកប្រធាន ម៉ៅ សេទុង បានប្រកាសក្តែងៗថា មិនអាចមាន «ផ្លូវទីពក្នុងក្តីស្រមៃ» ណាមួយទេ ហើយមើលឃើញថាពិភពលោកបានបែងចែកជាពីរ គឺអ្នកដែលគាំទ្រ «ការកសាងសង្គមនិយម និង អ្នកដែល «ជាអាយ៉ងពួកចក្រពត្តិ» ហើយស្នើសុំឲ្យដើរតាមកុម្មុយនីស្តដែលហៅថា «រដ្ឋអព្យាក្រឹតក្នុងការតស៊ូអាវុធដូចមានប្រទេសចិនជាគំរូស្រាប់» ។

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨ ព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន ហើយសម្តេច សីហនុ បានបង្កើតទំនាក់ទំនងផ្ទាល់អស់កាលយូរអង្វែងជាមួយលោកនាយករដ្ឋមន្ត្រីចិន គឺលោក ជូ អេនឡាយ ព្រមទាំងមេដឹកនាំ

ចិនក្រោយៗមកទៀត ។

មានការគិតគូរយ៉ាងល្អិតល្អន់ថា សម្តេច សីហនុ បានសម្រេចព្រះហឫទ័យទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិនថាជាផ្នែកមួយនៃការធ្វើតុល្យភាពរបស់ព្រះអង្គដើម្បីរក្សាប្រទេសរបស់ព្រះអង្គឲ្យជៀសផុតពីសង្គ្រាមនៅវៀតណាមនិងទំនាក់ទំនងដែលកាន់តែយ៉ាប់យ៉ឺនរបស់កម្ពុជាជាមួយប្រទេសជិតខាងដែលធ្លាប់មានការប្រទូសរ៉ាយនឹងគ្នា ដូចជាថៃនិងវៀតណាមខាងត្បូងជាដើម ដែលប្រទេសទាំងនេះនឹងមិនគោរពបូរណភាពទឹកដីរបស់កម្ពុជាឡើយ ។

តាមការពិត ក្នុងខែមិថុនា ឆ្នាំ១៩៥៨ ភាពតានតឹងរវាងកម្ពុជានិងរបបក្រុងព្រៃនគរបានកើនឡើង ដោយសារតែជម្លោះព្រំដែននិងសកម្មភាពមួយចំនួនរបស់ទីភ្នាក់ងារសម្ងាត់ក្រុងព្រៃនគរក្នុងការជួយទម្លាក់សម្តេច សីហនុ ដែលនេះត្រូវបានជឿជាក់យ៉ាងទូលំទូលាយថា បានទទួលការគាំទ្រពីសំណាក់ភ្នាក់ងារសម្ងាត់របស់អាមេរិកនិងអង្គភាពខ្លះរបស់កងយោធាអាមេរិកាំង ។

ទោះបីជាយ៉ាងនេះក្តី ការពិតនៅជាការពិតដែលថា ក្នុងព្រះនាមជាអគ្គមហាក្សត្រវ័យក្មេងក្នុងទសវត្សរ៍ឆ្នាំ១៩៤០ សម្តេច សីហនុ បានសិក្សាប្រវត្តិសាស្ត្រចិន ហើយចាប់ព្រះហឫទ័យខ្លាំងលើប្រវត្តិសាស្ត្រចិនទាំងសម័យកាលបុរាណនិងសម័យកាលថ្មីៗ ព្រមទាំងប្រវត្តិសាស្ត្រនៃទំនាក់ទំនងពីបរមបុរាណរវាងអធិរាជអង្គរនិងចិន ដែលនាំមកកម្ពុជានូវភៀវប្រវត្តិវិទូចិនល្បីៗ ព្រមទាំងអន្តោប្រវេសន៍ និងចុងក្រោយគឺព្រះអង្គស្ងើចសរសើរចំពោះស៊ុន យ៉ាត់សេន ដែលជាឥស្សរជនដ៏ខត្តុង្គខត្តមម្នាក់របស់ចិនក្នុងប្រវត្តិសាស្ត្រសម័យទំនើប ។

លើសពីនេះទៅទៀត ប្រសិនបើសាធារណរដ្ឋប្រជាមានិតចិនអាចជួយកម្ពុជាឲ្យរស់រានមានជីវិតជាប្រទេសដែលមានសេរីភាពនិងឯករាជ្យដោយទទួលបានការការពារបូរណភាពទឹកដីក្នុងតំបន់ដែលហ៊ុមព័ទ្ធដោយសង្គ្រាមនៅវៀតណាម និងការជ្រៀតជ្រែករបស់សហរដ្ឋអាមេរិកមែននោះ អ៊ីចឹងវាជាការច្បាស់ណាស់ថា សម្តេច សីហនុ រឹតតែចង់ពង្រីកមិត្តភាពជាមួយចិនកាន់តែខ្លាំងថែមទៀត ។

ជាការពិត មានពេលវេលាខុសៗគ្នានិងនៅពេលដែលរក្សាទំនាក់ទំនងល្អជាមួយរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយសម្តេច សីហនុ ចិនបានជួយដោយសម្ងាត់ដល់ចលនាតស៊ូនៅក្នុងព្រៃរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចដែលធ្លាប់បានផ្តល់ជាជំនួយនិងការណែនាំផ្នែកមនោគមវិជ្ជាដល់ទ័ពព្រៃកុម្មុយនីស្តនៅភូមាម៉ាឡេស៊ីនិងថៃដែរ ។ ទោះបីជាយ៉ាងនេះក្តី ប្រទេសចិនសង្ឃឹមថាគំរូរបស់កម្ពុជានឹងត្រូវបានប្រទេសនៅអាស៊ីនិងអាហ្វ្រិកយកគំរូតាម ។

ផ្ទុយទៅវិញ ទំនាក់ទំនងនេះនាំទៅដល់ជម្លោះនៅក្នុងអំឡុងពេលនៃបដិវត្តន៍វប្បធម៌ដោយសារតែសមាជិកខ្លះក្នុងស្ថានទូតចិននៅភ្នំពេញបានចាប់ផ្តើមបាចលិខិតឃោសនាអំពីបដិវត្តន៍វប្បធម៌និងដាក់តាំងរូបភាពអ្នកប្រយុទ្ធជាឆ្នាំក្រហម ។ ក៏ប៉ុន្តែ គួរតែអរគុណចំពោះចំណងទាក់ទងជាបុគ្គលដែលនៅមានរវាង សម្តេច សីហនុ និងលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដែលបញ្ហានេះត្រូវបានដោះស្រាយបានយ៉ាងឆាប់រហ័ស ហើយទំនាក់ទំនងក៏វិលត្រឡប់ទៅរកភាពជាប្រក្រតីវិញ ព្រមទាំងបន្តពង្រីកនិងពង្រឹងជាថ្មីតាមរយៈការយកចិត្តទុកដាក់ជាលក្ខណៈបុគ្គលដែលមានរវាងសម្តេច សីហនុ និងលោក ជូ អេនឡាយ ។

ព្រមជាមួយគ្នានោះ ចិនចាំបាច់ធ្វើការវាយតម្លៃឡើងវិញដែរអំពីតួនាទីរបស់ខ្លួននៅក្នុងតំបន់នេះ ដោយសារតែចិនបារម្ភអំពីការរីករាលដាលនៃឥទ្ធិពលរបស់សូវៀតនៅអាស៊ីអាគ្នេយ៍ ។ ថ្នាក់ដឹកនាំចិនមានការជឿជាក់យ៉ាងច្បាស់ថា ការគំរាមកំហែងខ្លាំងក្លាបំផុតដល់អធិបតេយ្យភាពរបស់ចិនកើតចេញមកពីសហភាពសូវៀតនិងជម្លោះរវាងប្រទេសទាំងពីរនេះដែលឡើងដល់ចំណុចកំពូលក្នុងអំឡុងពេលនៃការប៉ះទង្គិចគ្នាកាលពីឆ្នាំ១៩៦៩ លើបញ្ហាទន្លេអ៊ុស្ស៊ូរី ។

ចិនគិតថា ប្រសិនបើសូវៀតអាចរួបរួមចំណងសាមគ្គីជាមួយបណ្តាប្រទេសនៅឥណ្ឌូចិនបានជោគជ័យ បន្ថែមជាមួយការងើបឡើងនៃការបះបោររបស់ពួកកុម្មុយនីស្តនៅកម្ពុជា ឡាវនិងវៀតណាមនោះ ចិនពិតជាត្រូវហ៊ុមព័ទ្ធដោយរបបដែលគាំទ្រដោយសូវៀតជាក់ជាពុំខាន ។ ដូច្នេះ ឥទ្ធិពលរបស់ចិនលើវៀតណាមខាងជើងត្រូវតែធ្វើក្លាមនៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ដោយជំទាស់ទៅនឹងការទំធ្វើសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិកព្រម

ទាំងការបដិសេធលើសំណើសុំហោះហើររបស់សហភាពសូវៀតកាត់ដែនអាកាសរបស់ចិនដើម្បីបញ្ជូនសម្ភារៈឲ្យដល់វៀតណាមខាងជើង ។

នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលដែលចិនបានសម្រេចបើកការសន្ទនាជាមួយសហរដ្ឋអាមេរិកក្នុងគោលបំណងបង្កើតទំនាក់ទំនងជាមួយក្រុងវ៉ាស៊ីនតោន វៀតណាមខាងជើងយល់ថាចិនបម្រុងនឹងបង្ខំឲ្យខ្លួនធ្វើការសម្របសម្រួលណាមួយដូចដែលចិនធ្លាប់បានធ្វើនៅអំឡុងពេលនៃសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ អ៊ីចឹង ។ ដូច្នេះ ក្រុងហាណូយបានងាកទៅរកក្រុងម៉ូស្គូ ហើយឥទ្ធិពលរបស់សូវៀតលើវៀតណាមខាងជើងចាប់ផ្តើមកើនឡើងភ្លាម ។

ក្នុងឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ ព្រះអង្គបានគង់ប្រថាប់នៅក្រុងប៉េកាំង ដែលនៅទីនោះថ្នាក់ដឹកនាំចិនបានទទួលព្រះអង្គយ៉ាងអធិកអធមក្នុងនាមជាព្រះប្រមុខរដ្ឋដោយថ្វាយនូវព្រះរាជដំណាក់ដ៏ពិសិដ្ឋ ព្រមទាំងមធ្យោបាយគ្រប់យ៉ាងក្នុងការតស៊ូប្រឆាំងនឹង លន់ នល់ ដែលជាមេធ្វើរដ្ឋប្រហារ ។ នៅពេលនោះ លោកប្រធាន ម៉ៅ សេទុង បានថ្លែងថាៈ

*សមមិត្ត ជូ អេនឡាយ បានធ្វើទស្សនកិច្ចពីរលើកទៅកាន់កម្ពុជាក្រោមរដ្ឋាភិបាលរបស់ព្រះអង្គនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និងឆ្នាំ១៩៦០ ។ គាត់បានសង្កត់ធ្ងន់នៅក្នុងរបាយការណ៍របស់គាត់ថា ព្រះអង្គគឺសម្តេច សីហនុ មានស្មារតីភក្តីនិងគាំទ្រយ៉ាងខ្លាំងក្លាដោយប្រជារាស្ត្រកម្ពុជា ហើយថាព្រះអង្គបានសម្រេចកិច្ចការធំៗជាច្រើនសម្រាប់ប្រជារាស្ត្រនិងប្រទេសរបស់ព្រះអង្គដែលទាំងនេះបាននាំមកនូវសុខុមាលភាពនិងមានការរីកចម្រើនដោយសុខដុមរមនាជាទៀងទាត់លើគ្រប់វិស័យក្នុងការកសាងជាតិ ។ ជាងនេះទៅទៀត នរណាៗក៏ដឹងដែរថា ព្រះអង្គបានដឹកនាំជាតិរបស់ព្រះអង្គឆ្ពោះទៅរកឯករាជ្យភាពនិងបូរណភាពដែនដី ។ មានអ្នកខ្លះនៅលើពិភពលោកនេះបាននិយាយថា កុម្មុយនីស្តមិនស្រឡាញ់ស្តេចទេ ។ ផ្ទុយទៅវិញ យើងជាចិនកុម្មុយនីស្តបានស្រឡាញ់និងគោរពស្តេចដូច នរោត្តម សីហនុ ដែលព្រះអង្គតែងតែគង់ប្រថាប់នៅក្បែរជានិច្ច ស្រឡាញ់ស្មោះស្ម័គ្រជានិច្ចនិងបូជាព្រះកាយជានិច្ចជូនចំពោះប្រជារាស្ត្ររបស់ព្រះអង្គ ។*

ក្នុងឆ្នាំ១៩៧២ ជាឆ្នាំដែលសាធារណរដ្ឋប្រជាមានិតចិនបានទៅអង្គុយនៅឯអង្គការសហប្រជាជាតិ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បានប្រកាសថា «ប្រជាជនចិននឹងមិនភ្លេចឡើយនូវអ្វីៗដែលព្រះរាជាណាចក្រកម្ពុជាបានធ្វើក្នុងការការពារនូវបុព្វហេតុដ៏ត្រឹមត្រូវរបស់សាធារណរដ្ឋប្រជាមានិតចិននៅឯអង្គការសហប្រជាជាតិ» ។

អ្នកដឹកនាំចិនក្រោយៗមកទៀតពុំដែលបំភ្លេចថា គឺកម្ពុជាដែលដឹកនាំដោយសម្តេច សីហនុ បានជួយបំបែកការនៅដាច់ឆ្ងាយរបស់ចិននៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ដោយសារតែបានធ្វើយុទ្ធនាការនៅឯអង្គការសហប្រជាជាតិក្នុងការបណ្តេញតៃវ៉ាន់ចេញដែលបានអង្គុយលើអាសនៈរបស់សាធារណរដ្ឋប្រមានិតចិននៅអង្គការសហប្រជាជាតិអស់រយៈពេលជាច្រើនឆ្នាំ ។

រវាងឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បានប្រដៅសហរដ្ឋអាមេរិកជារឿយៗដែលចង់ស្វែងរកការទាក់ទងជាមួយ សម្តេច សីហនុ ដែលតាមខ្ញុំដឹងគឺថា លោក ជូ មានការបារម្ភថាខ្មែរក្រហមនឹងកាន់កាប់ប្រទេសកម្ពុជាដោយពួកគេផ្ទាល់ ហើយអាចធ្វើឲ្យប្រទេសកម្ពុជាជួបជោគអាក្រក់ជាងអ្វីដែលចិនបានជួបប្រទះក្នុងអំឡុងពេលនៃបដិវត្តន៍វប្បធម៌ទៅទៀត ។ លោក ជូ គិតមិនខុសឡើយ ។ តែផ្ទុយទៅវិញ ការប្រដៅរបស់លោកចំពោះ ហង់រី គីស៊ីងហ្គ័រ និងប្រេសិតអាមេរិកដទៃៗទៀតមិនត្រូវបានគេយកចិត្តទុកដាក់ទេ ពីព្រោះសហរដ្ឋអាមេរិកបានសម្រេចចិត្តគាំទ្រ លន់ នល់ និងអ្នកធ្វើរដ្ឋប្រហាររួចស្រេចទៅហើយ ។

កាលណោះ លោក ជូ អេនឡាយ ថែមទាំងបានទទួលការជួយពីសំណាក់ប្រទេសបារាំងនិងបាននិយាយទៅកាន់ឯកអគ្គរដ្ឋទូតអូស្ត្រាលីនៅប៉េកាំងទៀតផង ។ ដោយបាត់បង់ឥទ្ធិពលរបស់ខ្លួនទៅក្នុងដៃសហរដ្ឋអាមេរិកវិញ បន្ទាប់ពីមានរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០ នៅកម្ពុជា ប្រទេសបារាំងបានចាប់អារម្មណ៍និងលើករឿងនេះទម្លាក់ទៅលើអាមេរិកាំង ដែលម្តងនេះសហរដ្ឋអាមេរិកពុំបានសម្រេចចិត្តចាំបាច់ណាមួយនិងទាន់ពេលវេលាក្នុងការធានាឲ្យបានថា កម្ពុជានឹងធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់ពួកខ្មែរក្រហមឡើយ ។

នៅពេលនោះ អាមេរិកាំងជាចុងបញ្ចប់បានសម្រេចចិត្តនឹង

ធ្វើអ្វីមួយចំពោះរឿងនោះ ក៏ប៉ុន្តែវាយឺតពេលទៅហើយ ។ ម្យ៉ាងទៀត ដោយសារមរណភាពរបស់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ដោយជំងឺមហារីក បានធ្វើឲ្យបាត់បង់ឥទ្ធិពលទៅលើមនុស្សដែលត្រូវបានហៅថា «បន៤នាក់» ដែលអ្នកទាំង៤នេះឯងជាអ្នកគាំទ្រដល់យោធាខ្មែរក្រហមក្នុងការឈានទៅកាន់កាប់ប្រទេសកម្ពុជា ហើយជំទាស់រាល់ការពាក់ព័ន្ធណាមួយរបស់ចិនក្នុងការចរចាសម្រាប់ឲ្យមានដំណោះស្រាយសន្តិភាពចំពោះសង្គ្រាមនៅកម្ពុជា ។

ក្នុងខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជាហើយ ចិនបានក្លាយជាអ្នកមានឥទ្ធិពលខ្លាំងក្លានៅក្នុងប្រទេសកម្ពុជា ហើយថែមទាំងបានបញ្ជូនអ្នកបច្ចេកទេសរាប់ពាន់នាក់ឲ្យមកជួយបដិវត្តន៍របស់ខ្មែរក្រហមទៀតផង ។ ចិនក៏បានបញ្ជូនមន្ត្រីជាន់ខ្ពស់របស់ខ្លួន ដូចជាលោកជំទាវមេម៉ាយរបស់លោកនាយករដ្ឋមន្ត្រី ជូ អេនឡាយគឺលោកស្រី តេង យីនជាវ ឲ្យមកផ្ដល់ដំបូន្មានដល់ថ្នាក់ដឹកនាំខ្មែរក្រហមចំពោះនយោបាយយង់ឃ្នងដែលខ្លួនអនុវត្តនៅកម្ពុជា ។ មិនគ្រាន់តែពុំព្រមស្ដាប់ប៉ុណ្ណោះទេ មេដឹកនាំខ្មែរក្រហមនៅតែបន្តអនុវត្តបដិវត្តន៍សង្គមនិយមជ្រុលហួសហេតុថែមទៀត ។

នៅពេលដែលលោកស្រី តេង យីនជាវ មកធ្វើទស្សនកិច្ចនៅកម្ពុជាក្នុងខែមករា ឆ្នាំ១៩៧៨ លោកស្រីបានទូន្មានច្រើនគួរសមចំពោះទង្វើរបស់កម្ពុជាទៅលើវៀតណាមដែលរួបរួមគ្នា ហើយដែលមានដូចជាការប៉ះទង្គិចគ្នាជាច្រើនលើកច្រើនសានៅតាមបណ្ដោយព្រំដែននិងការសម្លាប់វៀតណាមអស់ជាច្រើន ។ លោកស្រីបានព្យាយាមបញ្ចុះបញ្ចូលខ្មែរក្រហមឲ្យធ្វើការចរចាជាមួយវៀតណាម ហើយសុំឲ្យបញ្ឈប់ការវាយប្រហារគ្នានៅតាមទល់ដែនដែរ តែពុំបានសម្រេចអ្វីឡើយ ។ មានការរាយការណ៍ថា លោកស្រីបានប្រាប់មេដឹកនាំខ្មែរក្រហម ប៉ុល ពត ថា «ចិនគឺជាមិត្តរបស់កម្ពុជាមិនមែនជាសត្រូវរបស់កម្ពុជាទេ» ហើយថែមទាំងបានទទួចឲ្យកម្ពុជាដោះស្រាយបញ្ហាជាមួយវៀតណាម «ដោយឈរលើគោលការណ៍រួមរស់ជាមួយគ្នាដោយសន្តិវិធី ដូចដែលជំរុញឲ្យមានដោយសន្និសីទបាន់ឌុងអ៊ីចឹង» ។

លោកស្រីបានស្នើសុំការសាកសួរសុខទុក្ខចំពោះសម្ដេច សីហនុ ដែលកំពុងស្ថិតក្នុងការឃុំឃាំងព្រះកាយក្នុងវាំងនៅកណ្ដាលទីក្រុងនៃកម្ពុជាដែរ ប៉ុន្តែការស្នើសុំរបស់លោកស្រីត្រូវបានបដិសេធដែលជំនួសដោយការបញ្ជាក់ថា សម្ដេច សីហនុ នៅមានព្រះជន្មនៅឡើយ នៅពេលដែលរថយន្តរបស់លោកស្រីបើកកាត់មុខសួនច្បារជាកន្លែងដែល សម្ដេច សីហនុ កំពុងគង់ប្រថាប់ ។

បន្ទាប់មកទៀត ក្នុងឆ្នាំ១៩៧៩ ពេលដែលវៀតណាមវាយលុកចូលកម្ពុជា ចិនបានសម្រេចថាត្រូវតែផ្ដល់ «មេរៀនមួយ» សម្រាប់ការវាយលុក និងគ្រប់គ្រងកម្ពុជាបែបនេះនិងសម្រាប់ការដែលដេញកូនចៅរបស់ខ្លួនគឺខ្មែរក្រហមចេញពីអំណាចបើទោះបីជាមានហេតុការណ៍ថា មេដឹកនាំខ្មែរក្រហមពុំបានស្ដាប់តាមការណែនាំរបស់មេដឹកនាំចិនក៏ដោយ ហើយថាអាណិកជនចិនដែលរស់នៅកម្ពុជាឬខ្មែរកាត់ចិនត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហមដោយសារតែអ្នកទាំងនេះត្រូវបានចាត់ទុកថាជាពួកមូលធនឬអ្នកចេះដឹង ។

ការដួលរលំនៃទីក្រុងភ្នំពេញ និងការបង្កើតរបប «សាធារណរដ្ឋប្រជាមានិតកម្ពុជា» ដែលគាំទ្រដោយវៀតណាមនៅភ្នំពេញដោយអតីតសមាជិកខ្មែរក្រហមដែលស្ថិតនឹងភាគីមួយនៃបក្សកុម្មុយនីស្ដកម្ពុជាដែលគាំទ្រសូវៀតនិងវៀតណាម បានធ្វើឲ្យចិនបារម្ភយ៉ាងខ្លាំង ហើយធ្វើការវាយតម្លៃនយោបាយរបស់ខ្លួននៅក្នុងតំបន់នេះឡើងវិញ ។ ចិនគិតថានឹងមានការគំរាមកំហែងពីប្រទេសដែលគាំទ្រសូវៀតដែលកំពុងងើបឡើង ដូចជា កម្ពុជា ឡាវ និងវៀតណាម ហើយរឹតតែច្បាស់ទៅទៀតនៅពេលដែលប្រទេសនៅអាស៊ីអាគ្នេយ៍រួបរួមទៅជាសមាគមអាស៊ាន ។

ក្រោយមក ចិនក៏ចាប់ផ្ដើមប្រឹងប្រែងដើម្បីបណ្ដេញវៀតណាមចេញពីកម្ពុជា តាមរយៈការធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាស៊ាននិងសហរដ្ឋអាមេរិក ព្រមទាំងការបង្រួបបង្រួមកម្លាំងនយោបាយគ្រប់ភាគីកម្ពុជាទាំងអស់ ដែលរួមមានកម្លាំងខ្មែរក្រហមដែលនៅសេសសល់ កម្លាំងរបស់អតីតនាយករដ្ឋមន្ត្រី សឺន សាន រួមទាំងអ្នកដែលគាំទ្រសម្ដេច សីហនុ ដែលទាំងអស់នេះរួមបង្កើតបានជារដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យនៅខែមិថុនា ឆ្នាំ១៩៨២ ។

ការប្រមូលផ្ដុំការគាំទ្រដល់រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិប

គេយល់ឃើញថា ការផ្តល់ជំនួយរបស់ចិន ដោយសារតែខ្មែរក្រហម បានបង្កឲ្យមានអំពើឃោរឃៅលើប្រជាជនឯង ដែលសហគមន៍អន្តរជាតិមានការស្អប់ខ្ពើម ហើយព្រមជាមួយនោះប្រទេសមហាអំណាចធំៗមិនចង់ទាក់ទងនឹងបញ្ហានេះថែមទៀត ។ ប្រសិនបើអនុវត្តតាមច្បាប់អន្តរជាតិ ចិនអាចទូទាត់វិញទៅនឹងការខ្ពើមរអើមរបបខ្មែរក្រហមស្ទើរតែជាសកល និងខ្លួនចង់រក្សាអាសនៈកម្ពុជានៅអង្គការសហប្រជាជាតិផង ។

ព្រឹត្តិការណ៍ជាច្រើនដែលបានកើតឡើងនៅសហភាពសូវៀតក្នុងឆ្នាំ១៩៨៩ រួមជាមួយកិច្ចខិតខំប្រឹងប្រែងវាយបំបាក់វៀតណាមរបស់ចិនផងនោះ បានធ្វើឲ្យការក្តោបក្តាប់លើកម្ពុជាត្រូវចំណាយយ៉ាងច្រើនលើសលប់ ដែលចុងក្រោយបានធ្វើឲ្យវៀតណាមប្រកាសថា ខ្លួននឹងដកកងទ័ពចេញឲ្យអស់ពីកម្ពុជាត្រឹមដំណាច់ខែកញ្ញា ឆ្នាំ១៩៨៩ ។ កិច្ចប្រជុំកំពូលរវាងចិននិងសូវៀតក្នុងខែឧសភា ឆ្នាំ១៩៨៩ បានបង្កើតទំនាក់ទំនងជាធម្មតាឡើងវិញរវាងចិននិងសហភាពសូវៀត ដែលស្ទើរតែបែកបាក់និងក្លាយទៅជាសហព័ន្ធរុស្ស៊ីទៅហើយ ។

បន្ទាប់នោះ ចិនបានចាប់ផ្តើមចេញបន្តិចម្តងៗពីភាពជាមេដឹកនាំចលនាប្រឆាំងនឹងវៀតណាម ដោយចូលរួមជាមួយប្រទេសអាស៊ាន រួចហើយចិននិងសហរដ្ឋអាមេរិកក្នុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ក៏ចាប់ស្តារទំនាក់ទំនងជាធម្មតាជាមួយវៀតណាមឡើងវិញ ។ កិច្ចប្រជុំពេញអង្គលើកទី១ នៃសន្និសីទអន្តរជាតិនៅទីក្រុងប៉ារីសស្តីពីកម្ពុជាទទួលបរាជ័យ ដោយសារតែចិនបានគាំទ្រដល់ផែនការសម្រាប់រដ្ឋាភិបាលចម្រុះបួនភាគីកម្ពុជា (ខ្មែរក្រហម អ្នកគាំទ្រ សឺន សាន សាធារណរដ្ឋប្រជាមានិតកម្ពុជា និងអ្នកគាំទ្រសម្តេច សីហនុ) ហើយវៀតណាមបានស្នើសុំឲ្យមានការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នដែលមាន២ភាគីតែប៉ុណ្ណោះ (សាធារណរដ្ឋប្រជាមានិតកម្ពុជានិងភាគីសម្តេច សីហនុ) ។

ក្រោយមក នៅដើមខែកញ្ញា ឆ្នាំ១៩៩០ មេដឹកនាំចិន និងវៀតណាមបានជួបប្រជុំគ្នា ហើយអាចទំនងជាថា ភាគីទាំងពីរបានឈានដល់ការសម្របសម្រួលមួយលើបញ្ហារដ្ឋាភិបាលបណ្តោះអាសន្នកម្ពុជា ដែលក្រោយមកត្រូវបានអនុម័តយកតាមនៅក្នុងការចរចាជាបន្ថែមទៀត និងកិច្ចប្រជុំពេញអង្គលើកទី២ និងចុងក្រោយនៃសន្និសីទអន្តរជាតិនៅទីក្រុងប៉ារីសស្តីពីកម្ពុជា ។

ចិនបានបើកស្ថានទូតរបស់ខ្លួនឡើងវិញនៅភ្នំពេញក្នុងខែវិច្ឆិកា ឆ្នាំ១៩៩១ ហើយចាប់តាំងពីពេលនោះមកបានក្លាយជាសមភាគីនាំមុខគេរបស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្នក្នុងកិច្ចខិតខំប្រឹងប្រែងកសាងប្រទេសដែលបំផ្លិចបំផ្លាញដោយសង្គ្រាមស៊ីវិលអស់រាប់សិបឆ្នាំមកហើយ ។ សហគ្រាសនិងអ្នកវិនិយោគិនរបស់ចិនកំពុងជួយកសាងប្រទេសកម្ពុជាឡើងវិញយ៉ាងខ្លាំងក្លា ។

តាមការពិចារណាចុងក្រោយនេះ ខ្ញុំសូមនិយាយថា ចិនគឺជាមិត្តស្មោះស្ម័គ្រម្នាក់របស់កម្ពុជា ហើយតែងតែមានវត្តមានជានិច្ចនៅពេលដែលកម្ពុជាត្រូវការឲ្យជួយ ។ ប្រសិនបើគ្មានការគាំទ្រដ៏ខ្លាំងក្លារបស់ចិនទេ ខ្ញុំយល់ឃើញថា កម្ពុជាអាចនឹងគ្មានលទ្ធភាពថែរក្សាឯករាជ្យភាពនិងបូរណភាពដែនដីរបស់ខ្លួនបានឡើយ ដែលទាំងសម្តេច នរោត្តម សីហនុ និងលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ ក៏យល់ឃើញអ៊ីចឹងដែរថា ទាំងអស់ហ្នឹងបាននាំឲ្យកម្ពុជារស់ឡើងវិញ ។ **ហ្វូលីយ៉ូ អេ. ដេលវ៉ែរូស**

# ការចូលរួមរបស់ជនរងគ្រោះ

នៅអំឡុងឆ្នាំ២០០៨មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងចង់ឲ្យជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិច ១០,០០០នាក់ ចូលរួមបំពេញពាក្យបណ្តឹង (ជាខ្រិដ្ឋកម្ម ឬជាដើមបណ្តឹងរដ្ឋប្បវេណី) មុនពេលចូលទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញពីសកម្មភាពនេះថាជាការជួយដល់ប្រជាជនសាមញ្ញកម្ពុជាឲ្យចូលរួមក្នុងដំណើរការនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោសនៅមុខច្បាប់និងដំណើរការម្តងទៀតនូវ «គណៈកម្មការស្វែងរកការពិត» ជាលក្ខណៈមិនសូវផ្លូវការដែលគណៈកម្មការនេះបានចាប់ផ្តើមតាំងពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ម៉្លេះ ដោយការចុះហត្ថលេខាលើញត្តិរណសិរ្ស ។

សម្រាប់ព័ត៌មានលម្អិតសុំទំនាក់ទំនង លោក ដី ទេរិទ្ធិ តាមរយៈលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

# ការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ផលវិបាក ការវិភាគ និងអនុសាសន៍

***(តពីលេខមុន)***

ជាងនេះទៅទៀត មានការព្យាយាមតិចតួចក្នុងការជំរុញឲ្យមានការស្រាវជ្រាវទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម ក្នុងចំណោមសិស្ស និស្សិតខ្មែរ ។ ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហម មានការបោះពុម្ពផ្សាយជាច្រើនអំពីរបបនេះ ប៉ុន្តែសៀវភៅទាំងអស់ត្រូវបានសរសេរឡើងជាភាសាបរទេសដោយជនបរទេស ។ សៀវភៅទាំងអស់ត្រូវបានចងក្រងឡើងជាការវិភាគផ្នែកទ្រឹស្តីដែលសិស្សវិទ្យាល័យនិងសាកលវិទ្យាល័យនៅកម្ពុជាមានការលំបាកក្នុងការស្វែងយល់ ។ សៀវភៅមួយចំនួនត្រូវបានបកប្រែជាភាសាខ្មែរ ប៉ុន្តែមានច្រើនរាប់រយទំព័រដែលពិបាកនឹងយកមកធ្វើជាប្រភពព័ត៌មានសម្រាប់ស្រាវជ្រាវ ដោយសារកូនសិស្សខ្មែរភាគច្រើនមិនទាន់មានទម្លាប់ក្នុងការអាននៅឡើយ ។ ក្នុងចំណោមកម្មវិធីសិក្សាចំនួន២០របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលជាសាកលវិទ្យាល័យធំជាងគេនិងមានអាយុកាលយូរនៅកម្ពុជា មុខវិជ្ជាប្រវត្តិសាស្ត្រគឺជាមុខវិជ្ជាដែលមិនសូវទទួលការចាប់អារម្មណ៍ពីសិស្ស ។ ដោយសារតែមានសម្ពាធពីបញ្ហាសេដ្ឋកិច្ច និស្សិតខ្មែរភាគច្រើនបានងាកទៅរកការសិក្សាណាដែលអាចយកមកប្រើដើម្បីរកប្រាក់ចំណូលបានក្នុងរយៈពេលខ្លី ។ មិនមាននិស្សិតច្រើនទេដែលចុះឈ្មោះចូលរៀនថ្នាក់ប្រវត្តិសាស្ត្រ ។ នេះគឺជាចន្លោះប្រហោងសំខាន់មួយដែលរាជរដ្ឋាភិបាលគួរចាត់វិធានការក្នុងការលើកកម្ពស់ការយល់ដឹងរបស់សិស្សឲ្យយល់អំពីសារសំខាន់នៃប្រវត្តិសាស្ត្រ និងផ្តល់ការលើកទឹកចិត្តដល់សិស្សក្នុងការចុះឈ្មោះចូលរៀនថ្នាក់ប្រវត្តិសាស្ត្រ ។

បន្ថែមពីលើអវត្តមានអត្ថបទប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងកម្មវិធីសិក្សាថ្នាក់វិទ្យាល័យ និស្សិតសាកលវិទ្យាល័យក៏មានឱកាសតិចតួចក្នុងការសិក្សាអំពីរយៈកាលដ៏ខ្មៅងងឹតនេះដែរ ។ នៅក្នុងកម្មវិធីសិក្សាបរិញ្ញាប័ត្រប្រវត្តិសាស្ត្ររយៈពេលបួនឆ្នាំ និស្សិតថ្នាក់ប្រវត្តិសាស្ត្រត្រូវបានដាក់ឲ្យរៀនប្រវត្តិសាស្ត្រផ្សេងៗនៃពិភពលោក (ដូចជាប្រវត្តិសាស្ត្រចិន ប្រវត្តិសាស្ត្រអាមេរិក ប្រវត្តិសាស្ត្រវៀតណាម និងប្រវត្តិសាស្ត្រថៃ) ជាមុខវិជ្ជាសំខាន់ ។ ផ្ទុយទៅវិញ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានដាក់បញ្ចូលទៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាពីឆ្នាំ១៩៥៣មកទល់នឹងបច្ចុប្បន្នជាមុខវិជ្ជាចម្បងមួយនៅក្នុងឆមាសទីពីរនៃឆ្នាំទីបួន ។ ទោះបីជាការពិភាក្សានៅក្នុងថ្នាក់រៀនមានលក្ខណៈទូលំទូលាយនិងលម្អិតជាងការសិក្សានៅថ្នាក់វិទ្យាល័យក៏ដោយ ក៏ទំហំនៃការសិក្សាស្ថិតនៅក្នុងដែនកំណត់មួយដូចគ្នាសម្រាប់កម្រិតសិក្សាពីរដែលខុសគ្នា ។ ជាងនេះទៅទៀត ចំនួននិស្សិតប្រវត្តិសាស្ត្រដែលនឹងត្រូវចេញទៅបង្រៀននៅតាមវិទ្យាល័យនានានៅទូទាំងប្រទេស ហើយដែលមានលទ្ធភាពក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមមានចំនួនតិចតួចនៅឡើយ ។

ប្រជាជនកម្ពុជាដែលស្ថិតក្នុងលក្ខខណ្ឌជីវភាពរស់នៅលំបាក ទោះបីភាគច្រើនធ្លាប់រស់នៅឆ្លងកាត់របបខ្មែរក្រហមក្តី ហាក់ដូចជាមិនបានដឹងឬមិនចាប់អារម្មណ៍ចំពោះអវត្តមាននៃការសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែរ ។ ឪពុកម្តាយនៅតាមស្រុកស្រែចម្ការជាទូទៅមិនសូវលើកទឹកចិត្តកូនឲ្យបន្តការសិក្សានៅថ្នាក់ខ្ពស់ទេ ។ គាត់បែរជាឲ្យកូនមកជួយធ្វើកិច្ចការស្រែចម្ការឬស្វែងរកការងារធ្វើដើម្បីជួយសម្រាលបន្ទុកគ្រួសារវិញ ។ នៅក្នុងអត្ថបទស្រាវជ្រាវ «កំណែទម្រង់វិស័យអប់រំនៅកម្ពុជា» ឆាលលែនតាន់ អះអាងថា ក្មេងជាច្រើនមកពីគ្រួសារក្រីក្រដែលបានចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា «ប្រហែលជាមិនអាចបញ្ចប់ការសិក្សារបស់ខ្លួននៅថ្នាក់បឋមបានទេ ដោយសារភាគច្រើនមិនអាចទប់ទល់នឹងលក្ខខណ្ឌនៃការសិក្សាពេញម៉ោងផង និងផ្ទៀតធ្វើការពាក់កណ្តាលម៉ោងដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារផង» ។ ភាគច្រើនគឺសិស្សស្រីដែលជួបបញ្ហាបែបនេះ ។ ជាញឹកញយ

ឪពុកម្តាយបានបញ្ជូនកូនស្រីឲ្យទៅធ្វើជាកម្មករកាត់ដេរនៅទីក្រុង ដូច្នេះកូនស្រីត្រូវបង្ខំចិត្តបោះបង់ចោលការសិក្សារបស់ខ្លួន ។ កូនស្រីក៏ត្រូវបានប្រើឲ្យជួយការងាររកស៊ីនៅក្នុងគ្រួសារ ដើម្បីឲ្យកូនប្រុសអាចបន្តការសិក្សាបាន ។ កត្តានេះបាននាំឲ្យមានអត្រាអវិជ្ជាខ្ពស់នៅក្នុងចំណោមស្ត្រី និងការឈប់ចូលរៀនឬរៀនត្រួតថ្នាក់ក្នុងចំណោមសិស្សស្រីនៅគ្រប់កម្រិតសិក្សាទាំងអស់ ។

អំពើពុករលួយនៅក្នុងសង្គមខ្មែរ គឺជាបញ្ហាមួយទៀតដែលនាំឲ្យកម្រិតគុណភាពនៃការអប់រំមានការធ្លាក់ចុះ ។ មន្ត្រីក្រសួងអប់រំនិងគ្រូបង្រៀនទទួលបានប្រាក់បៀវត្សរ៍(២៨ដុល្លារអាមេរិកសម្រាប់គ្រូបឋមសិក្សា) ដែលមានចំនួនតិចតួចដើម្បីទ្រទ្រង់ការចំណាយប្រចាំថ្ងៃនៅក្នុងគ្រួសាររបស់ខ្លួន ។ ជាទូទៅគ្រូបង្រៀនមិនអាចរស់នៅជាមួយនឹងប្រាក់បៀវត្សរ៍ពីរដ្ឋាភិបាលបានទេ ។ គាត់ត្រូវតែបង្ខំចិត្ត «រកប្រាក់ចំណូលពីការងារទីពីរ» ។ ប្រភពចំណូលដែលល្បីល្បាញជាងគេ គឺការយកលុយពីសិស្សបន្ថែមនៅក្នុងថ្នាក់រៀន ឬទុកមេរៀនសំខាន់ៗមួយចំនួនដើម្បីបង្រៀននៅថ្នាក់ឯកជនរបស់ខ្លួន ។ សិស្សដែលគ្មានលទ្ធភាពបង់ថ្លៃបន្ថែមប្រហែលជាមិនអាចប្រលងជាប់ទេ បណ្តាលឲ្យមានការរៀនត្រួតថ្នាក់ជាច្រើន ។ ដូច្នេះប្រសិនបើការអប់រំជាទូទៅនេះមិនត្រូវបានធ្វើឲ្យប្រសើរឡើងទេ ការសិក្សាស្តីពីអំពើប្រល័យពូជសាសន៍នឹងមិនអាចក្លាយទៅជាប្រធានបទបន្ទាន់បានឡើយ ។

អំពើឃោរឃៅក្នុងរបបខ្មែរក្រហមបានបង្កឲ្យមានការប៉ះពាល់ដោយផ្ទាល់ចំពោះគ្រួសារខ្មែរទាំងអស់ និងប៉ះពាល់ដោយប្រយោលចំពោះប្រជាជនខ្មែរដែលកើតក្រោយរបបនេះ ។ កូនខ្មែរជំនាន់ក្រោយជាទូទៅទទួលរងនូវបន្ទុកគ្រួសារក្នុងការរកប្រាក់ចំណូលដោយសារតែឪពុកឬសមាជិកពេញកម្លាំងនៅក្នុងគ្រួសារបានស្លាប់ឬពិការនៅក្នុងអំឡុងពេលនៃអំពើប្រល័យពូជសាសន៍ឬសង្គ្រាមស៊ីវិល ។ មរតកនៃរបបខ្មែរក្រហមបានប៉ះពាល់ដល់ប្រជាជននិងក្មេងជំនាន់ក្រោយជាច្រើនសណ្ឋាន ជាពិសេសប៉ះពាល់ដល់ការរៀនសូត្រដូចដែលបានរៀបរាប់ពីខាងលើ ។ ជាងនេះទៅទៀត ប្រជាជនកម្ពុជាមួយចំនួនធំទាំងជនរងគ្រោះនិងជនដៃដល់ (អតីតកម្មាភិបាលខ្មែរក្រហម) កើតមានជំងឺផ្លូវចិត្តដែលគ្មានការព្យាបាលឲ្យបានត្រឹមត្រូវអស់រយៈពេលជិត៣០ឆ្នាំមកហើយតាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ យោងតាមការសិក្សាមួយរបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ «៨១ភាគរយនៃប្រជាជនកម្ពុជាធ្លាប់ឆ្លងកាត់អំពើហិង្សា ២៨.៤ភាគរយទទួលរងនូវការបាក់ស្បាត ១១,៥ភាគរយមានអារម្មណ៍វិបល្លាស, និង៤០ភាគរយមានជំងឺថប់អារម្មណ៍» ។ នេះគឺជាបញ្ហាសង្គមពិតប្រាកដមួយដែលរាជរដ្ឋាភិបាលត្រូវតែដោះស្រាយដើម្បីបង្កើនគុណភាពអប់រំដល់កូនខ្មែរជំនាន់ក្រោយនិងពន្លឿនបរិយាកាសនៃការផ្សះផ្សាជាតិ ។

ការទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះតាមរយៈការអប់រំជាផ្លូវការ គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយដើម្បីជំរុញដល់ដំណើរការផ្សះផ្សាររវាងជនរងគ្រោះនិងជនដៃដល់ ។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលជាជាងលើកយកបញ្ហានេះមកពិភាក្សាហាក់ដូចជាមានបំណងចង់កប់ចោលរឿងរ៉ាវពីអតីតកាលទៅវិញ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានគូសបញ្ជាក់ថា វាមានសារសំខាន់ណាស់ដែលប្រជាជនចាប់ផ្តើមនិយាយរឿងរ៉ាវពីជីវិតផ្ទាល់ខ្លួននៅក្នុងរបបខ្មែរក្រហម «ទោះជាមានការលំបាកយ៉ាងណា ឬរឿងរ៉ាវនោះសាហាវឃោរឃៅយ៉ាងណាក៏ដោយ» ។ លោកបានបន្ថែមទៀតថា «របបខ្មែរក្រហមគឺជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ហើយប៉ះទង្គិចលើប្រជាជនកម្ពុជាស្ទើរតែគ្រប់រូប ។ យើងត្រូវតែបង្រៀនកូនចៅអំពីរឿងនេះដើម្បីធានាឲ្យបានថាក្មេងជំនាន់ក្រោយរៀនសូត្រពីការឈឺចាប់របស់យើង ។ ធ្វើបែបនេះ យើងអាចចែករំលែកបទពិសោធន៍ពីអំពើប្រល័យពូជសាសន៍ជាមួយប្រជាជនកម្ពុជារាប់លាននាក់ផ្សេងទៀត និងប្រជាជនជាច្រើនលាននាក់ផ្សេងទៀតនៅលើពិភពលោក» ។ ដូចដែលលោក ឆាំង យុ បានលើកឡើង ទោះជាការរៀបរាប់ពីរឿងអតីតកាល «ជួបប្រទះនូវឧបសគ្គច្រើនដូចជា វប្បធម៌ ភាសា រឿងរ៉ាវផ្ទាល់ខ្លួន និងនយោបាយយ៉ាងណាក៏ដោយ» ក៏ការយល់ដឹងអំពីដើមហេតុនៃការឈឺចាប់ គឺជាជំហានដ៏មានសារសំខាន់ក្នុងការសម្រាលជំងឺផ្លូវចិត្តរបស់ជនរងគ្រោះនិងដោះលែងពួកគាត់ឲ្យមានសេរីភាពពីអតីតកាល ។ កត្តានេះនឹងជួយបង្កើតនូវគំនិតអាណិតអាសូរនិងកាត់បន្ថយគំនិតស្អប់ខ្ពើមនិងបំណងនៃការសងសឹកក្នុងចំណោមជនរងគ្រោះនិងជនដៃដល់ ។

សំខាន់ជាងនេះទៅទៀត  ការរៀបរាប់រឿងរ៉ាវផ្ទាល់ខ្លួននឹងជួយបង្កើតឲ្យមានការចាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងចំណោមសិស្សានុសិស្ស ។

ដំណើរការសាលាក្តីខ្មែរក្រហម  ទោះជាអ្នកវិភាគមួយចំនួនជឿថាវានឹងបើកកកាយដំបៅចាស់និងធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តជនរងគ្រោះជាថ្មីម្តងទៀត  គឺជាយន្តការដ៏ល្អមួយក្នុងការជីកគាស់រឿងរ៉ាវពីអតីតកាលនិងឆ្លើយតបនឹងសំណួរដែលថា  ហេតុអ្វីបានសោកនាដកម្មនេះកើតឡើងបាន ។  សាលាក្តីដែលមានឈ្មោះជាផ្លូវការថា  អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា  នឹងដើរតួបន្ថែមជាមជ្ឈមណ្ឌលអប់រំមួយដើម្បីបង្ហាត់បង្រៀនកូនខ្មែរជំនាន់ក្រោយ  ក៏ដូចជាប្រជាជននៅលើពិភពលោកពីអំពើឃោរឃៅនៅក្នុងរយៈកាលនៃរបបខ្មែរក្រហម ។ សវនាការនៅក្នុងសាលាក្តីខ្មែរក្រហមនឹងសើរើនិងបញ្ជាក់បង្ហាញជាថ្មីនូវព្រឹត្តិការណ៍មិនច្បាស់លាស់មួយចំនួននៅក្នុងរបបខ្មែរក្រហមដែលអ្នកនយោបាយនិងអ្នកស្រាវជ្រាវមួយចំនួនមានការខ្វែងយោបល់គ្នា ។

រដ្ឋាភិបាលកម្ពុជាត្រូវតែលើកយកបញ្ហានៃការអប់រំមកដោះស្រាយ  ប្រសិនបើកម្ពុជាត្រូវអភិវឌ្ឍតាមផ្លូវប្រជាធិបតេយ្យនិងការគោរពច្បាប់ ។ ការដាក់បញ្ចូលការសិក្សាស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងថ្នាក់រៀន គឺជាវិធីមួយដែលរាជរដ្ឋាភិបាលត្រូវធ្វើដើម្បីកែប្រែឥរិយាបថរបស់ប្រជាជនមករកការគោរពសិទ្ធិមនុស្ស ។  វាគឺជាកម្លាំងចលករដ៏មានប្រសិទ្ធភាពមួយដើម្បីបង្កើតមូលដ្ឋានក្នុងការស្វែងរកដំណោះស្រាយចំពោះបញ្ហាសង្គមផ្សេងៗទៀត ។

## ផលវិបាកផ្នែកនយោបាយ

ការដួលរលំនៃរបបខ្មែរក្រហមនិងការបង្កើតឡើងនូវរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក្រោមការជួយជ្រោមជ្រែងពីសំណាក់វៀតណាម  គឺជាការចាប់ផ្តើមនូវភាពចម្រូងចម្រាសនៃការបកស្រាយប្រវត្តិសាស្ត្រខ្មែរតាមផ្លូវនយោបាយ  ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម ។  នៅកម្ពុជា  ការសិក្សាពីអំពើប្រល័យពូជសាសន៍បានក្លាយទៅជាឧបករណ៍នយោបាយសម្រាប់ភាគីជម្លោះកម្ពុជាក្នុងការប្រកួតប្រជែងដើម្បីអំណាច ។  កុមារនៅក្នុងតំបន់ត្រួតត្រារបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្ហាត់បង្រៀនថាខ្មែរក្រហមគឺជាបិសាចឬសត្វសាហាវដែលសម្លាប់និងជញ្ជក់ឈាមប្រជាជន ។  ផ្ទុយទៅវិញ  កុមារនៅក្នុងតំបន់ត្រួតត្រារបស់ខ្មែរក្រហមត្រូវបានបណ្តុះមនោគមន៍វិជ្ជាឲ្យជឿថាវៀតណាមនឹងបញ្ចូលកម្ពុជាទៅក្នុងទឹកដីរបស់ខ្លួន  ហើយប្រជាជនកម្ពុជាទាំងអស់ដែលស្លាប់នៅក្នុងអំឡុងពេលសង្គ្រាមនិងអំពើប្រល័យពូជសាសន៍  គឺបណ្តាលមកពីឧបាយកលសាហាវឃោរឃៅរបស់វៀតណាម ។  ជាលទ្ធផលនៃការផ្សព្វផ្សាយនយោបាយទាំងនេះសោកនាដកម្មនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាបានក្លាយទៅជារឿងព្រេងសម្រាប់ក្មេងជំនាន់ក្រោយ ។


អ្នកភូមិកំពុងអានទម្រង់បែបបទព័ត៌មានជនរងគ្រោះ

ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃវត្តមានរបស់វៀតណាមនៅកម្ពុជា សាធារណរដ្ឋកម្ពុជាបានប្រើប្រាស់សៀវភៅសិក្សាសម្រាប់ថ្នាក់បឋមសិក្សាដើម្បីរៀបរាប់ពីអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមក្នុងន័យជាការឃោសនានយោបាយ ។  កុមារចាប់ពីថ្នាក់ទីមួយឡើងទៅត្រូវបានបង្ហាត់បង្រៀនឲ្យស្អប់និងខ្លាចខ្មែរក្រហម ។ ជាឧទាហរណ៍ សៀវភៅរៀនអានសម្រាប់ថ្នាក់ទី១  (បោះពុម្ពនៅឆ្នាំ១៩៧៩  ដោយក្រសួងសិក្សាធិការ

ជាតិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា) មានប្រយោគពីរឃ្លាដែលរៀបរាប់អំពីរយៈកាលនៃរបបខ្មែរក្រហម ៖ «ប្រជាជនយើងផ្គត់ផ្គង់ស្បៀងដល់បង១ យោធាដែលកំពុងតែដេញកម្ចាត់បនក្បត់ជាតិ ប៉ុល ពត អៀង សារី ។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាកម្ទេចចោលបនក្បត់ជាតិ ប៉ុល ពត អៀង សារី» ។ នៅពេលអ្នកស្រាវជ្រាវភាគច្រើនកំណត់ចំនួនមនុស្សស្លាប់នៅក្នុងរបបខ្មែរក្រហមពីមួយលានទៅពីរលាននាក់ សិស្សត្រូវបានបង្ហាត់បង្រៀនដោយមិនច្បាស់លាស់ថាប្រជាជនកម្ពុជាជាងបីលានបីសែននាក់ត្រូវបានខ្មែរក្រហមសម្លាប់ ។ នៅក្នុងសៀវភៅរៀនអានថ្នាក់ទី២ ប្រយោគមួយឃ្លាបាននិយាយថា «បន ប៉ុល ពត អៀង សារី សម្លាប់ប្រជាជនកម្ពុជាជាងបីលាននាក់និងកម្ទេចអ្វីៗទាំងអស់នៅកម្ពុជា ។ យើងមានកំហឹងឈឺចាប់យ៉ាងខ្លាំងក្លានិងតស៊ូដាច់ខាតប្រឆាំងនឹងអំពើឃោរឃៅទាំងនេះ» ។ ជាងនេះទៅទៀត រូបភាពនៅក្នុងសៀវភៅបង្ហាញពីគំនូរដែលខ្មែរក្រហមវះពោះមនុស្សការធ្វើទារុណកម្មដ៏ឃោរឃៅនៅក្នុងគុកទួលស្លែងនិងការសម្លាប់ដែលមានលក្ខណៈហិង្សាខ្លាំងសម្រាប់សិស្សក្នុងការសិក្សា ។ សៀវភៅសិក្សាទាំងនេះត្រូវបានប្រើប្រាស់ដើម្បីបង្ហាត់បង្រៀនកូនខ្មែរដែលកើតក្រោយរបបខ្មែរក្រហមក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៅកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ ។

នៅឆ្នាំ១៩៩១ ភាគីជម្លោះទាំងអស់ដែលរួមទាំងខ្មែរក្រហមផងបានឈានដល់កិច្ចព្រមព្រៀងសន្តិភាពមួយ ហើយបានយល់ព្រមឲ្យមានការបោះឆ្នោតជាលើកទីមួយក្រោមការត្រួតពិនិត្យផ្ទាល់របស់អ៊ុនតាក់ ។ ការបោះឆ្នោតនេះគឺជាចំណុចរបត់មួយនៅក្នុងនយោបាយកម្ពុជាក៏ដូចជាប្រព័ន្ធអប់រំផងដែរ ។ សៀវភៅសិក្សានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានជំនួសដោយសៀវភៅសិក្សាថ្មី ។ ប៉ុន្តែ មិនមានសៀវភៅសិក្សាណាមួយបានរៀបរាប់អំពីព្រឹត្តិការណ៍ដែលកើតមានឡើងក្នុងសម័យខ្មែរក្រហមឡើយ ។ រដ្ឋាភិបាលបានអះអាងថា អវត្តមាននៃប្រវត្តិសាស្ត្រខ្មែរក្រហមគឺមានសារសំខាន់ណាស់ «សម្រាប់ការផ្សះផ្សាជាតិ» ។ គ្រូបង្រៀនត្រូវបានណែនាំមិនឲ្យនិយាយរឿងខ្មែរក្រហមនៅក្នុងថ្នាក់រៀនទេ ។ សៀវភៅសិក្សាសង្គមថ្មីផ្ដោតទាំងស្រុងទៅលើប្រវត្តិសាស្ត្រខ្មែរនៅមុនសម័យអង្គរនិងសម័យអង្គរ (កម្ពុជាមុនសតវត្សរ៍ទី១២ និងក្រោយមកទៀត) និងសម័យទំនើបគឺកម្ពុជាក្នុងសម័យទសវត្សរ៍ឆ្នាំ១៩៥០និង១៩៦០ ។ ពីឆ្នាំ១៩៩១ទៅឆ្នាំ២០០០ អស្ថិរភាពនយោបាយបានធ្វើឲ្យប្រវត្តិសាស្ត្រខ្មែរក្រហមបន្តអវត្តមានពីកម្មវិធីសិក្សារបស់សាលា ទោះបីជាមន្ត្រីក្រសួងអប់រំយុវជននិងកីឡាធ្លាប់បានពិភាក្សាជាញឹកញាប់អំពីការដាក់បញ្ចូលប្រវត្តិសាស្ត្រនេះទៅក្នុងកម្មវិធីសិក្សារបស់សាលាក៏ដោយ ។ នៅឆ្នាំ១៩៩៦ លោក តុល ឡោះ ដែលនៅពេលនោះជារដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡាបានសន្យាចំពោះលោកគ្រូអ្នកគ្រូនិងអ្នកស្រាវជ្រាវថា ក្រសួងនឹងមិនព្រងើយកន្តើយចំពោះប្រវត្តិសាស្ត្រខ្មែរក្រហមនោះទេ ។ សម្ដីរបស់លោកត្រូវបានដកស្រង់ចុះក្នុងកាសែតខែមបូឌៀដេលី ដោយលោកបានមានប្រសាសន៍ថា «យើងនឹងមិនគាក់តែងប្រវត្តិសាស្ត្រសាឡើងវិញទេ ។ ប្រវត្តិសាស្ត្រត្រូវតែនៅជាប្រវត្តិសាស្ត្រ ។ ការពិតត្រូវតែរក្សាឲ្យនៅដដែល» ។ ទោះជាយ៉ាងនេះក្ដី សំណួរដែលថាតើនៅពេលណានឹងចាប់ផ្ដើមបង្ហាត់បង្រៀនកូនខ្មែរអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងបង្រៀនដោយរបៀបណានៅតែមិនមានដំណោះស្រាយដដែល ។

នៅឆ្នាំ១៩៩៦ រដ្ឋាភិបាលកំពុងតែធ្វើការចរចាជាមួយភាគីខ្មែរក្រហមដែលជាផ្នែកមួយនៃគោលនយោបាយផ្សះផ្សានិងបង្រួបបង្រួមជាតិ ។ នៅពេលនេះ អៀង សារី អតីតរដ្ឋមន្ត្រីការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យបានយល់ព្រមទម្លាក់អាវុធនិងដឹកនាំកម្មាភិបាលនិងកងទ័ពខ្មែរក្រហមរាប់ពាន់នាក់មកចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ នៅឆ្នាំ១៩៩៨ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបីនាក់ផ្សេងទៀត (ខៀវ សំផន, នួន ជា, និង កែ ពក) បានចុះចូលជាមួយរាជរដ្ឋាភិបាលដោយបន្សល់ទុកកងកម្លាំងខ្មែរក្រហមតែមួយផ្នែកតូចប៉ុណ្ណោះនៅក្បែរព្រំដែនថៃ ។ ព្រឹត្តិការណ៍វិវត្តន៍ទាំងនេះបានបង្អាក់ដល់ការពិចារណាក្នុងការបង្រៀនសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ដើម្បីការផ្សះផ្សាជាតិ រដ្ឋាភិបាលនៅក្នុងអំឡុងពេលនោះមិនយកចិត្តទុកដាក់ចំពោះប្រធានបទដ៏មានសារសំខាន់នេះឡើយ ។

បន្ទាប់ពីការចុះចូលរបស់ខ្មែរក្រហម អង្គការសង្គមស៊ីវិលចាប់ផ្ដើមទាមទារឲ្យមានការកែប្រែនិងដាក់បញ្ចូលអំពើប្រល័យពូជសាសន៍នៅកម្ពុជាទៅក្នុងកម្មវិធីសិក្សានោះ ។ នៅទីបំផុត

ក្រសួងអប់រំយុវជននិងកីឡាបានកែប្រែកម្មវិធីសិក្សាដែលមានស្រាប់នៅឆ្នាំ២០០០និង២០០១ និងបោះពុម្ពសៀវភៅសិក្សាសង្គមថ្មីសម្រាប់ថ្នាក់ទី៩និងថ្នាក់ទី១២ ។ សៀវភៅសិក្សាថ្មីនេះរួមបញ្ចូលទាំងប្រវត្តិសាស្ត្រសម័យទំនើបរបស់កម្ពុជា គឺកម្ពុជាចាប់តាំងពីសម័យសង្គមរាស្ត្រនិយមរបស់សម្តេចព្រះ នរោត្តមសីហនុ រហូតមកដល់ការបោះឆ្នោតជាតិឆ្នាំ១៩៩៨ ដែលរួមទាំងប្រវត្តិសាស្ត្រខ្មែរក្រហមផង ។ ប៉ុន្តែ ទោះបីជារដ្ឋាភិបាលកម្ពុជាបានបញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈសៀវភៅសិក្សាទាំងនេះក្តី ក៏ការរៀបរាប់អំពីព្រឹត្តិការណ៍ក្នុងរយៈកាលនោះមានចំនួនតិចតួចណាស់សម្រាប់កូនខ្មែរជំនាន់ក្រោយយល់ឲ្យបានច្បាស់នូវអ្វីដែលបានកើតឡើងនាពេលនោះ ។ សៀវភៅសិក្សាថ្នាក់ទី៩រៀបរាប់រឿងរ៉ាវក្នុងរបបខ្មែរក្រហមតែប្រាំបន្ទាត់ប៉ុណ្ណោះ ៖

ពីថ្ងៃទី២៥ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមបានប្រារព្ធមហាសន្និបាតពិសេសដើម្បីរៀបចំរដ្ឋធម្មនុញ្ញថ្មីមួយនិងប្តូរឈ្មោះប្រទេសទៅជា «កម្ពុជាប្រជាធិបតេយ្យ» ។ រដ្ឋាភិបាលថ្មីមួយនៃកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ ប៉ុល ពត ត្រូវបានបង្កើតឡើង ហើយដែលបានចាប់ផ្តើមការកាប់សម្លាប់ប្រជាជនកម្ពុជាយ៉ាងរង្គាល ។

នៅក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី១២ មេរៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមមានរហូតដល់ទៅបីទំព័រ ។ មេរៀននេះពិភាក្សាដោយសង្ខេបអំពីព្រឹត្តិការណ៍នយោបាយ ការបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនិងសេដ្ឋកិច្ច និងការរស់នៅរបស់ប្រជាជន ។ ប៉ុន្តែ សៀវភៅនេះមិនបានពិភាក្សាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងមិនបានបង្ហាញថាតើខ្មែរក្រហមជាអ្នកណា ហើយខ្មែរក្រហមឡើងកាន់អំណាចដោយរបៀបណាទេ ។ សៀវភៅសិក្សាថ្មីក៏មិនបានរៀបរាប់ពីផែនការបួនឆ្នាំរបស់ខ្មែរក្រហម ការបង្ខំឲ្យធ្វើការហួសកម្លាំង វិសុទ្ធកម្មនិងការសម្លាប់រង្គាល និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដទៃទៀតដែលបង្ហាញពីចរិតលក្ខណៈនៅក្នុងរយៈកាលនោះ ។ ជាងនេះទៅទៀត មេរៀនដ៏ខ្លីនេះបានបញ្ចប់ដោយថា តាមចំនួនមនុស្សស្លាប់ដែលបានសរសេរនៅក្នុងសៀវភៅរៀនអានដែលបោះពុម្ពដោយសាធារណរដ្ឋប្រជាមានិតកម្ពុជានិយាយថា «របបនេះបានសម្លាប់ប្រជាជនស្លូតត្រង់ជាងបីលាននាក់...កម្ពុជាប្រជាធិបតេយ្យបានពន្លិចប្រទេសទាំងមូលទៅក្នុងគ្រោះមហន្តរាយក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ» ។

ការដាក់បញ្ចូលព្រឹត្តិការណ៍សង្ខេបនៃប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងសៀវភៅសិក្សាបានបង្ហាញឲ្យឃើញថា មេដឹកនាំនិងអ្នកអប់រំនៅក្នុងក្រសួងអប់រំយុវជននិងកីឡាមើលឃើញសារសំខាន់នៃការសិក្សាពីអំពើប្រល័យពូជសាសន៍ផ្សេងគ្នា ។ វិធីក្នុងការដោះស្រាយបញ្ហាពីអតីតកាលគឺត្រូវបំភ្លេចអតីតកាលចោល ។ អ៊ិន អោមសាមេង ប្រធានគណកម្មាធិការរៀបចំកម្មវិធីសិក្សាបាននិយាយថា អត្ថបទសិក្សាមិនបានពិភាក្សាការកាប់សម្លាប់ជាលម្អិតទេ ពីព្រោះ «យើងមិនចង់ឲ្យកូនខ្មែរជំនាន់ក្រោយធ្វើត្រាប់តាមប្រវត្តិសាស្ត្រដ៏ជូរចត់នេះ ។ យើងចង់កប់ចោលសូម្បីតែក្លិនរបស់វា» ។ យោបល់នេះប្រហាក់ប្រហែលទៅនឹងការកត់សម្គាល់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបាននិយាយថា «វាដល់ពេលហើយដែលយើងត្រូវជីករណ្តៅដើម្បីកប់រឿងរ៉ាវពីអតីតកាល ទោះបីជាយើងទាំងអស់គ្នាចាត់ទុកអតីតកាលជាបន្ទុកដែលមិនអាចរ៉ាប់រងបានសម្រាប់ប្រជាជនកម្ពុជារាប់ពាន់ម៉ឺននាក់ក៏ដោយ» ។ ដូចគ្នានេះដែរ អតីតប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានបដិសេធថា លោកមិនបានដឹងថាមានរឿងអ្វីកើតឡើងទាំងអស់នៅក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន បានធ្វើការសុំទោសចំពោះអ្នកដែលបានស្លាប់និងរងគ្រោះនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ និងបានអំពាវនាវដល់ប្រជាជនកម្ពុជាឲ្យធ្វើការ «អភ័យទោសនិងបំភ្លេចចោល» ។ យ៉ាងណាមិញ ក្រសួងអប់រំយុវជននិងកីឡា ជាពិសេស គ្រូបង្រៀនមានកាតព្វកិច្ចក្នុងការបង្ហាត់បង្រៀនសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ពិសេសព្រឹត្តិការណ៍ដែលនៅបន្តចម្រូងចម្រាសរហូតមកទល់នឹងពេលបច្ចុប្បន្ននេះ ដូច្នេះទើបសិស្សអាចស្វែងរកការពិតឃើញ ។ ជាជាងកំណត់សាច់រឿងនៅក្នុងសៀវភៅសិក្សា គណៈកម្មាធិការរបស់ក្រសួងគួរតែអនុញ្ញាតឲ្យមានការរៀបរាប់ឲ្យបានទូលំទូលាយជាងនេះនៅក្នុងសៀវភៅសិក្សា ។ ជាងនេះទៅទៀត អ្នកនយោបាយខ្មែរត្រូវតែមានសេចក្តីក្លាហានហ៊ានប្រឈមមុខនឹងប្រវត្តិសាស្ត្រនិងអនុញ្ញាត

ឲ្យអ្នកជំនាញផ្នែកគរុកោសល្យធ្វើការសម្រេចថាអ្វីដែលគួរដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ។

ការបង្ហាត់បង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមថ្នាក់រៀននៅតែជាបញ្ហាមួយនៅកម្ពុជាដដែលនាពេលបច្ចុប្បន្ននេះ ។ សេចក្តីសម្រេចចិត្តសំខាន់ៗអំពីមាតិកាក្នុងកម្មវិធីសិក្សាបន្តស្ថិតនៅក្នុងដៃរបស់អ្នកនយោបាយ ។ ហើយការរៀបរាប់អំពីព្រឹត្តិការណ៍សម័យទំនើបរបស់កម្ពុជានៅក្នុងសៀវភៅសិក្សាសង្គមថ្មីទាំងពីរនៅតែមានលក្ខណៈជម្លោះផ្នែកនយោបាយនៅឡើយ ។ ជាឧទាហរណ៍ សៀវភៅសិក្សាសង្គមថ្នាក់ទី១២បានរៀបរាប់អំពីជោគជ័យរបស់គណបក្សប្រជាជនកម្ពុជាក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៨ ប៉ុន្តែមិនបាននិយាយអំពីជោគជ័យរបស់គណបក្សរាជានិយម ហ៊ុនស៊ិនប៉ិច ដែលបានឈ្នះឆ្នោតក្នុងការបោះឆ្នោតជាតិលើកទីមួយនាឆ្នាំ១៩៩៣ផងនោះ ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលនៅពេលនោះជាប្រធានគណបក្សហ៊ុនស៊ិនប៉ិចនិងជាប្រធានរដ្ឋសភាជាតិ បានរិះគន់អត្ថន័យនៅក្នុងសៀវភៅដែលមិនបាននិយាយពីជោគជ័យនៃគណបក្សរបស់ព្រះអង្គ ហើយបានអំពាវនាវឲ្យមានការកែប្រែ ។ ជាការឆ្លើយតប មន្ត្រីក្រសួងអប់រំ យុវជននិងកីឡាបានយល់ព្រមធ្វើការពិនិត្យឡើងវិញនិងបន្ថែមផ្នែកអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្តី ការពិភាក្សារវាងមេដឹកនាំនយោបាយសំខាន់ៗទាំងពីរ គឺព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានធ្វើឲ្យមានការលុបចោលកាន់តែច្រើនថែមទៀត ។ ប្រវត្តិសាស្ត្រទំនើបនៃប្រទេសកម្ពុជាដែលរួមមានទាំងប្រវត្តិសាស្ត្រខ្មែរក្រហមផងត្រូវបានដកចេញទាំងស្រុងពីសៀវភៅសិក្សាថ្នាក់ទី១២ ។ ការបោះពុម្ពផ្សាយថ្មីមានទំហំស្តើងជាង ហើយផ្តោតស្ទើរតែទាំងស្រុងទៅលើប្រវត្តិសាស្ត្របរទេស ។ ក្រោយមក នៅពាក់កណ្តាលឆ្នាំសិក្សា២០០២ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឲ្យដកសៀវភៅសិក្សាសង្គមថ្នាក់ទី១២ទាំងអស់ចេញពីកម្មវិធីសិក្សា ។ លោករដ្ឋមន្ត្រីក្រសួងអប់រំ តុលឡោះ បានបញ្ជាក់ពីការដកហូតនេះ ប៉ុន្តែលោកមិនអាចឆ្លើយនឹងសំណួរថាតើវាចំណាយពេលប៉ុន្មានដើម្បីដាក់បញ្ចូលសៀវភៅមកក្នុងកម្មវិធីសិក្សាវិញ ។ វាគឺជាសំណួរដែលហួសពីដែនសមត្ថកិច្ច ។

រហូតមកដល់បច្ចុប្បន្ននេះ សិស្សសាលាសិក្សាមុខវិជ្ជាប្រវត្តិសាស្ត្រដោយគ្មានសៀវភៅ ។ សមាគមគ្រូបង្រៀនឯករាជ្យបានអំពាវនាវឲ្យក្រសួងអប់រំដាក់សៀវភៅសិក្សាចូលក្នុងកម្មវិធីសិក្សាវិញ ប៉ុន្តែជាច្រើនលើកមិនបានសម្រេចសោះ ។ សេចក្តីសម្រេចចិត្តក្នុងការដកសៀវភៅចេញពីកម្មវិធីសិក្សា ត្រូវបានអ្នកអប់រំជាច្រើនមើលឃើញថា ជាការរំលោភទៅលើសិទ្ធិនិងសេរីភាពនៃការបោះពុម្ពផ្សាយ ។ ជាងនេះទៅទៀត សេចក្តីសម្រេចចិត្តនេះទោះជាមិនខុសតាមផ្លូវបច្ចេកទេស ប៉ុន្តែតាមផ្លូវសីលធម៌ វាជ្រៀតជ្រែកទៅលើសមត្ថកិច្ចរបស់ក្រសួងអប់រំដែលមានជំនាញច្បាស់លាស់ក្នុងការរៀបចំកម្មវិធីសិក្សា ។ លោកនាយករដ្ឋមន្ត្រីបានបញ្ជាឲ្យដកប្រវត្តិសាស្ត្រសម័យទំនើបរបស់ប្រទេសកម្ពុជាចេញពីកម្មវិធីសិក្សារបស់សាលា គួរតែផ្តល់ជាអនុសាសន៍ដល់ក្រសួងអប់រំឲ្យធ្វើការត្រួតពិនិត្យឡើងវិញនិងកែលម្អភាពត្រឹមត្រូវនិងភាពឥតលម្អៀងរបស់ប្រវត្តិសាស្ត្រ ។

ដោយមើលឃើញចន្លោះប្រហោងដ៏សំខាន់នៃការទទួលខុសត្រូវរបស់រដ្ឋាភិបាល មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានចងក្រងឯកសារពីអំពើប្រល័យពូជសាសន៍ក្នុងរបបខ្មែរក្រហមដោយ


អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត

ឯករាជ្យតាំងពីឆ្នាំ១៩៩៥មក បានបង្កើតគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ គោលបំណងនៃគម្រោងនេះគឺ «ពង្រឹងសមត្ថភាពគ្រូបង្រៀននិងក្រសួងអប់រំក្នុងការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដោយផ្តល់ជាគំនិត សម្ភារៈអនុសាសន៍ទៅលើកម្មវិធីសិក្សានិងសៀវភៅស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ។ គម្រោងនេះចាប់ផ្តើមឡើងនៅខែកញ្ញា ឆ្នាំ២០០៨និងបញ្ចប់នៅខែមីនា ឆ្នាំ២០០៧ ។ លទ្ធផលនៃគម្រោងគឺសៀវភៅប្រវត្តិសាស្ត្រដែលមានចំនួន១០០ទំព័រនិងដែលមានឈ្មោះថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ។ ស្របពេលជាមួយនឹងសាលាក្តីខ្មែរក្រហម សៀវភៅនេះទទួលបានការពេញចិត្តពីសំណាក់សិស្ស គ្រូបង្រៀន និងសាធារណជន ។ សៀវភៅចំនួន១៥០០ក្បាលត្រូវបានចែកចាយទៅសាលាវិទ្យាល័យចំនួន២៥៩នៅទូទាំងប្រទេស ។ នៅក្នុងកាលៈទេសៈនេះ រដ្ឋាភិបាលហាក់ដូចជាបើកឱកាសច្រើនជាងមុននិងដករបាំងក្នុងការបង្ហាត់បង្រៀនកូនខ្មែរជំនាន់ក្រោយពីអំពើប្រល័យពូជសាសន៍ ។ ទង្វើបែបនេះអាចចាត់ទុកថាជាលើកទីមួយដែលរដ្ឋាភិបាលអនុញ្ញាតឲ្យមានការបោះពុម្ពផ្សាយនិងចែកចាយនូវអត្ថបទប្រកបដោយលក្ខណៈនយោបាយនៅទូទាំងប្រទេស ។ នេះគឺជាជំហានប្រកបដោយផ្លែផ្កាលើកទីមួយឆ្ពោះទៅការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

រយៈកាលនៃរបបខ្មែរក្រហមគឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយដែលតភ្ជាប់ប្រវត្តិសាស្ត្រកម្ពុជាពីសម័យមួយទៅសម័យមួយទៀត ។ នៅពេលយើងនិយាយពីប្រវត្តិសាស្ត្រខ្មែរក្រហម យើងមិនអាចជៀសវាងមិនពិភាក្សាអំពីព្រឹត្តិការណ៍ក្នុងកំឡុងសម័យអាណានិគមបារាំងនៅកម្ពុជាក្រោមព្រះរាជកិច្ចដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ របបសាធារណរដ្ឋខ្មែរនិងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកបានទេ ។ ហើយយើងក៏មិនអាចជៀសវាងមិនពិភាក្សាអំពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជារយៈកាលអន្តរកាលនៃការគ្រប់គ្រងរបស់អ៊ុនតាក់និងរាជាណាចក្រទីពីរផងដែរ ។ ជាទូទៅ ស្ថានភាពប្រទេសកម្ពុជាពីសម័យអាណានិគមបារាំងរហូតមកពេលបច្ចុប្បន្ននេះ គឺជាបណ្តុំព្រឹត្តិការណ៍មួយដែលមិនអាចកាត់ផ្តាច់ពីគ្នាបាន ហើយព្រឹត្តិការណ៍ក្នុងរបបខ្មែរក្រហម គឺជាផ្នែកមួយដ៏សំខាន់នៃបណ្តុំព្រឹត្តិការណ៍នេះ ។ ដូច្នេះ រឿងរ៉ាវទាំងមូលនៃប្រវត្តិសាស្ត្រខ្មែរក្រហមនឹងមានការពិបាកក្នុងការស្វែងយល់បើសិនជារឿងរ៉ាវនោះមិនត្រូវបានបង្ហាញនៅក្នុងទម្រង់មួយដែលគូសបញ្ជាក់ពីការកកើតឡើងនៃចលនាកុម្មុយនីស្តនៅកម្ពុជាតាំងទសវត្សរ៍ឆ្នាំ១៩៤០ រហូតមកទល់នឹងពេលដែលខ្មែរក្រហមដួលរលំទាំងស្រុងនៅឆ្នាំ១៩៩៩ ។ ធ្វើបែបនេះ សិស្សអាចចាប់បាននូវរូបភាពទាំងមូលនៃរបបខ្មែរក្រហមនិងអនុញ្ញាតឲ្យពួកគេមានលទ្ធភាពសិក្សាទៅលើការវិវត្តនៃដំណើររបស់ខ្មែរក្រហម ហើយផ្សារភ្ជាប់ការវិវត្តនេះទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗទៀត ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវបន្ថែមនិងការយល់ដឹងឲ្យបានទូលំទូលាយថែមទៀត ។

ជាធម្មជាតិ ការសិក្សាពីប្រវត្តិសាស្ត្រគឺតែងតែជួបនូវបញ្ហា ។ ទោះជាយ៉ាងនេះក្តី ការយល់ដឹងរបស់យើងអំពីអតីតកាលនឹងជួយបណ្តុះគំនិតរបស់យើងក្នុងការដោះស្រាយបញ្ហានាពេលបច្ចុប្បន្នប្រកបដោយសុភនិច្ឆ័យ ។ ដូច្នេះ អវត្តមាននៃប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងសៀវភៅសិក្សានិងកម្មវិធីសិក្សារបស់សាលា បង្ហាញឲ្យឃើញនូវលទ្ធភាពដែលអាចបង្កឲ្យមានគ្រោះថ្នាក់នាពេលអនាគត ។ ការស្រាវជ្រាវប្រវត្តិសាស្ត្រ ដូចជាសៀវភៅប្រវត្តិសាស្ត្រដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា គួរតែត្រូវបានទទួលយកជាផ្នែកមួយនៃការពិតរបស់ប្រវត្តិសាស្ត្រប្រទេសសម្រាប់ការបង្ហាត់បង្រៀន ។ លោក ហ្វីលីប ហ្សិត អ្នកនិពន្ធសៀវភៅ ប៉ុល ពត ៖ ប្រវត្តិនៃការយល់សប្តិអាក្រក់បានអះអាងថា សៀវភៅប្រវត្តិសាស្ត្រដែលទើបបោះពុម្ពថ្មីនេះ «គឺជាសៀវភៅដែលរៀបរាប់ពីការពិតឥតលម្អៀងនៃរយៈកាលមួយដ៏ស្មុគស្មាញ ហើយសៀវភៅនេះមិនត្រឹមតែគួរត្រូវបានអនុញ្ញាតដាក់បញ្ចូលក្នុងកម្មវិធីសិក្សារបស់សាលានៅកម្ពុជាប៉ុណ្ណោះទេ តែជាអត្ថបទសិក្សាចាំបាច់ដែលសិស្សសាលាកម្ពុជាត្រូវតែតម្រូវឲ្យសិក្សា» ។ អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រនេះគួរតែត្រូវបានប្រើប្រាស់ដើម្បីបង្កើតឡើងនូវស្មារតីនិងការចងចាំប្រវត្តិសាស្ត្រ ។ ធ្វើដូច្នេះទើបប្រវត្តិសាស្ត្រនឹងមិនវិលមកសាជាថ្មីម្តងទៀត ហើយកូនខ្មែរជំនាន់ក្រោយអាចចាកចេញពីស្រមោលអតីតកាលនិងស្វែងរកវិធីក្នុងការកសាងប្រទេសជាតិឲ្យកាន់តែល្អ

ប្រសើរថែមទៀត ។ ដូច្នេះ ការពិតនៃប្រវត្តិសាស្ត្រខ្មែរក្រហមនឹងត្រូវបានរក្សាពីជំនាន់មួយទៅជំនាន់មួយទៀត ដែលជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការការពារ «ការភ្លេចភ្លាំងដែលតែងតែនៅជាប់គ្នាជានិច្ចជាមួយនឹងការចងចាំ» ។

មន្ត្រីនៃក្រសួងអប់រំយុវជននិងកីឡាបាននិយាយថា ក្រសួងមានផែនការកែប្រែកម្មវិធីសិក្សា ហើយនឹងយកសៀវភៅសិក្សាមកកាន់ថ្នាក់រៀនវិញនៅឆ្នាំ២០០៩ ។ សាស្ត្រាចារ្យ ដេវីដ ឆែនល័រ អ្នកជំនាញខាងប្រវត្តិសាស្ត្រខ្មែរ បាននិយាយថា «រដ្ឋាភិបាលហាក់ដូចមិនមានឆន្ទៈក្នុងការរៀបរៀងអត្ថបទប្រវត្តិសាស្ត្របៀបនេះឬក៏មិនបានចែករំលែកពីភាពចាំបាច់នៃការសិក្សារឿងរ៉ាវពីអតីតកាលមួយនេះ» ។ បញ្ហានយោបាយនិងថវិកាអាចបង្អាក់ដំណើរការនេះ ហើយគ្រូបង្រៀននឹងបន្តបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមក្រៅផ្លូវការឬបង្ហាញប្រវត្តិសាស្ត្រមិនសមស្របនៅក្នុងថ្នាក់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបន្តគម្រោងនៃការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរហូតដល់ឆ្នាំ២០១០ ដើម្បីធានាឲ្យបានថា ប្រវត្តិសាស្ត្រនេះនឹងត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាជាផ្លូវការ ។ ទោះជាយ៉ាងនេះក្តី ឆន្ទៈនយោបាយគឺជាកត្តាគន្លឹះនៅក្នុងការដោះស្រាយបញ្ហានេះ ។

**ឧបសគ្គផ្នែកគរុកោសល្យ**

ដើម្បីដាក់ឲ្យមានការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀននៅកម្ពុជា ការផលិតសៀវភៅសិក្សាប្រវត្តិសាស្ត្រខ្ចីសាមញ្ញ ត្រឹមត្រូវ ឥតលម្អៀង និងងាយស្រួលយល់ គឺជាជំហានសំខាន់ដំបូងមួយ ។ វាមានសារសំខាន់ណាស់ដែលក្រសួងអប់រំធ្វើការកែប្រែកម្មវិធីសិក្សាថ្នាក់វិទ្យាល័យដើម្បីដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សានោះ ។ ហើយវិធីសាស្ត្រក្នុងការបង្រៀនគឺរបៀបដែលគ្រូបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់ គឺជាជំហានចាំបាច់ទីពីរ ។

ដូចដែលបានរៀបរាប់ពីខាងលើ ប្រវត្តិសាស្ត្រខ្មែរក្រហមមានលក្ខណៈរសើបផ្នែកនយោបាយ ។ ដូច្នេះ ការបង្ហាត់បង្រៀនអំពីប្រវត្តិសាស្ត្រនេះអាចជំរុញឲ្យទៅមុខឬអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរលទ្ធិប្រជាធិបតេយ្យ សន្តិភាព និងឯកភាពជាតិ ។ ដូច្នេះ លទ្ធផលយ៉ាងណានោះគឺផ្អែកជាសំខាន់ទៅលើគរុកោសល្យក្នុងការបង្រៀន ។ តើប្រវត្តិសាស្ត្រខ្មែរក្រហមគួរត្រូវបានបង្រៀនដោយរបៀបណា? តើសៀវភៅសិក្សាប្រភេទណាដែលគ្រូគួរប្រើប្រាស់ក្នុងការបង្ហាត់បង្រៀនសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម? តើគ្រូអាចប្រើប្រាស់សៀវភៅផ្សេងៗទៀតក្រៅពីសៀវភៅដែលអនុញ្ញាតឲ្យប្រើដោយរដ្ឋាភិបាលបានដែរឬទេ? តើគ្រូបង្រៀនគួរទទួលបានការហ្វឹកហ្វឺនកម្រិតណា? តើត្រូវចំណាយពេលប៉ុន្មានក្នុងការបង្រៀនអំពីប្រវត្តិសាស្ត្រនេះ? តើគ្រូគួរទទួលបានការការពារយ៉ាងដូចម្តេចនៅក្នុងបរិស្ថានមួយដែលការបង្ហាត់បង្រៀនអំពីមុខវិជ្ជាដែលមានលក្ខណៈរសើបផ្នែកនយោបាយនេះអាចបង្កឲ្យមានអំពើហិង្សា? តើអ្វីខ្លះជាតួនាទីរបស់គ្រូប្រវត្តិសាស្ត្រ?

នាពេលបច្ចុប្បន្ននេះ ធនធានរបស់ក្រសួងអប់រំយុវជននិងកីឡា (ទាំងធនធានមនុស្សទាំងធនធានសម្ភារៈ) មានស្តួចស្តើង ។ ចំនួនគ្រូបង្រៀនដែលអាចបង្ហាត់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានសមស្របត្រឹមត្រូវនៅក្នុងថ្នាក់រៀនមានតិចតួចណាស់ ។ ចំនួននិស្សិតដែលទទួលបានសញ្ញាប័ត្រផ្នែកប្រវត្តិសាស្ត្រក៏មានចំនួនតិចដែរ ។ និស្សិតទាំងនេះដែលនឹងក្លាយទៅជាគ្រូបង្រៀននៅតាមសាលាវិទ្យាល័យនៅទូទាំងប្រទេស ត្រូវបានបង្ហាត់បង្រៀនពីប្រវត្តិសាស្ត្រខ្មែរ ប្រវត្តិសាស្ត្រអាស៊ី និងប្រវត្តិសាស្ត្រផ្សេងៗទៀតនៅលើពិភពលោក ។ មុខវិជ្ជាប្រវត្តិសាស្ត្រត្រូវបានរៀបចំឡើងនៅទសវត្សរ៍ឆ្នាំ១៩៨០ ហើយត្រូវបានកែប្រែជាបន្តបន្ទាប់ដោយមានជំនួយពីបរទេសនិងម្ចាស់ជំនួយ ។ ជាងនេះទៅទៀត សៀវភៅស្រាវជ្រាវភាគច្រើនត្រូវបានសរសេរជាភាសាអង់គ្លេសនិងបារាំង ដែលធ្វើឲ្យសិស្សមានការពិបាកថែមទៀតក្នុងការស្វែងយល់ ។ ប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានដាក់បញ្ចូលជាផ្នែកតូចមួយនៅក្នុងប្រវត្តិសាស្ត្រខ្មែរ នៅក្នុងឆមាសទីពីរនៃឆ្នាំទីបួនដែលធ្វើឲ្យសិស្សទទួលបានការយល់ដឹងក្នុងចំនួនកំណត់មួយអំពីប្រវត្តិសាស្ត្រនេះ ។ ទាំងនិស្សិតប្រវត្តិសាស្ត្រនិងគ្រូប្រវត្តិសាស្ត្រថ្នាក់វិទ្យាល័យត្រូវការសៀវភៅប្រវត្តិសាស្ត្រមួយ គម្រោងសម្រាប់បង្រៀននិងឯកសារបន្ទាប់បន្សំដទៃទៀត ដែលរៀបរាប់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រត្រឹមត្រូវ មិនលម្អៀងផ្នែកនយោបាយ ហើយមិនបង្កឲ្យមានការស្អប់ខ្ពើមនិងគំនុំសងសឹកនៅក្នុងផ្នត់គំនិតរបស់សិស្ស ។

ការហ្វឹកហ្វឺនប្រវត្តិសាស្ត្រខ្មែរក្រហមជូនដល់គ្រូបង្រៀន នៅទូទាំងប្រទេស គឺមានសារសំខាន់ខ្លាំងណាស់ក្នុងការធានាឲ្យបាន ថា គ្រូមានចំណេះដឹង ជំនាញនិងជំនឿចិត្តគ្រប់គ្រាន់ក្នុងការបង្ហាត់ បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានត្រឹមត្រូវ ។ ជាងនេះទៅ ទៀត គ្រូមានលទ្ធភាពផ្តល់នូវចម្លើយត្រឹមត្រូវនិងជួយសិស្ស របស់ខ្លួនក្នុងការស្វែងយល់រឿងរ៉ាវពីអតីតកាលដោយឈរលើ ស្មារតីនៃភាពត្រឹមត្រូវឥតលម្អៀង ។ វគ្គហ្វឹកហ្វឺននេះក៏នឹងជួយ ជំរុញដល់ការស្វែងយល់អំពីសារសំខាន់នៃការសិក្សាពីអំពើ ប្រល័យពូជសាសន៍ក្នុងការកសាងសង្គម ព្រោះថាប្រទេសដែលទើប តែងើបពីសង្គ្រាមច្រើនតែផ្តោតទៅលើមុខវិជ្ជាដែលមានតម្លៃ សម្រាប់ការអនុវត្តជាក់ស្តែងជាង ដូចជាភាសាបរទេស គណិតវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិជ្ជា និងវគ្គហ្វឹកហ្វឺនវិជ្ជាជីវៈ ។ ដូច្នេះប្រសិន បើគ្រូបង្រៀនមិនត្រូវបានហ្វឹកហ្វឺនឲ្យបានត្រឹមត្រូវទេ សូម្បីតែ សៀវភៅសិក្សាល្អឥតខ្ចោះយ៉ាងណាក៏ដោយ ក៏ប្រហែលជានឹង មិនមានប្រយោជន៍ដែរ ហើយកម្ពុជាប្រហែលជានឹងអាចជួប ប្រទះស្ថានភាពប្រហាក់ប្រហែលនឹងអតីតកាលប្តូរទម្រង់ថ្មីនៃបញ្ហា នៅក្នុងសង្គមដដែល ។

បន្ថែមពីលើការហ្វឹកហ្វឺនគ្រូបង្រៀន ក្រសួងអប់រំប្រហែល ជាត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់គរុកោសល្យ កម្រិតណាមួយ ដោយផ្តោតទៅលើសំណួរដែលថាតើសិស្សសាលា កម្រិតណាគួរត្រូវបានអនុញ្ញាតឲ្យសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម និងប្រវត្តិសាស្ត្រនេះគួរតែបញ្ចូលទៅក្នុងឬដាក់ឲ្យសិក្សាទន្ទឹមគ្នា នឹងមេរៀនស្តីអំពីសិទ្ធិមនុស្ស ។ មានបញ្ហាគួរឲ្យកត់សម្គាល់មួយ ក្នុងការបង្ហាត់បង្រៀនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្ម និង អំពើហិង្សា ។ អ្នកវិភាគមួយចំនួនជឿថា វាមានលក្ខណៈប្រសើរ ជាងក្នុងការបង្រៀនប្រធានបទនេះនៅកម្រិតបឋមសិក្សាព្រោះ ថាឥរិយាបថត្រឹមត្រូវត្រូវបានគាក់តែងឡើងតាំងពីនៅវ័យក្មេងៗ ។ ទោះជាយ៉ាងនេះក្តី នៅកម្ពុជាសិស្សថ្នាក់បឋមសិក្សានៅមានវ័យ ក្មេងណាស់ក្នុងការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ទារុណកម្ម និងការកាប់សម្លាប់ ។ ដោយស្របពេលជាមួយនឹងអត្រាខ្ពស់នៃ អ្នកមិនចេះអក្សរ អត្រាខ្ពស់នៃសិស្សដែលបោះបង់ចោលការ សិក្សាក៏ដូចជាឧក្រិដ្ឋកម្មនិងការសម្លាប់ក្រៅប្រព័ន្ធតុលាការដែល កើតមានឡើងស្ទើរតែរាល់ថ្ងៃ កូនក្មេងនិងសិស្សដែលបោះបង់ ចោលការសិក្សាអាចយកតម្រាប់តាមមេរៀននៅក្នុងសាលា ។ អ្នកវិភាគផ្សេងទៀតជឿថា «សិស្សគួរតែមានភាពចាស់ទុំផ្នែក គំនិតនិងបញ្ញាកម្រិតណាមួយសិន មុននឹងសិក្សាស្វែងយល់ពីទំហំ នៃភាពហិង្សានៅក្នុងអំពើប្រល័យពូជសាសន៍» ។ នៅក្នុងន័យនេះ សិស្សថ្នាក់វិទ្យាល័យមានភាពចាស់ទុំគ្រប់គ្រាន់ក្នុងការស្វែងយល់ វិភាគនិងអនុវត្តន៍មេរៀនឲ្យបានត្រឹមត្រូវ ។

ដោយសារតែភាពស្មុគស្មាញនេះ ជាគរុកោសល្យ មេរៀន អំពីប្រវត្តិសាស្ត្រខ្មែរក្រហមគួរត្រូវបានដាក់បញ្ចូលឬដាក់ឲ្យសិក្សា ទន្ទឹមគ្នានឹងមេរៀនអំពីសិទ្ធិមនុស្ស ។ ការរួមបញ្ចូលគ្នានៃការ សិក្សាពីអំពើប្រល័យពូជសាសន៍និងសិទ្ធិមនុស្សនឹងអនុញ្ញាតឲ្យ សិស្សធ្វើការប្រៀបធៀប និងដូចដែលលោក ហ្វីលីប ហ្វិរត បាន លើកឡើងអនុញ្ញាតឲ្យសិស្ស «ស្វែងយល់កាន់តែច្បាស់ ថែមទៀតទាក់ទងនឹងកត្តាដែលនាំឲ្យមានការកើតឡើង នូវការកាប់សម្លាប់ក្នុងទ្រង់ទ្រាយធំ និងជួយឲ្យសិស្សស្វែង យល់អំពីអត្តចរិតរបស់ជនដៃដល់និងជនរងគ្រោះ» ។ បញ្ហានេះនឹងមិនជាឧបសគ្គអ្វីធំទេ ដោយសារមេរៀន ស្តីអំពីសិទ្ធិមនុស្សត្រូវបានដាក់ឲ្យរៀនយ៉ាងទូលំទូលាយ នៅក្នុងកម្មវិធីសិក្សារបស់សាលា ហើយប្រជាជនក៏ទទួល បានការបង្ហាត់បង្រៀនអំពីសិទ្ធិមនុស្សពីសំណាក់អង្គការ ក្រៅរដ្ឋាភិបាលជាច្រើននៅកម្ពុជាផងដែរ ។ **(នៅមានត)**

**ឌី ខាំបូលី**


អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត

# ការចងចាំរបស់មីង ពីន ប៊ួយ


ពីន ប៊ួយ

បីឆ្នាំប្រាំបីខែម្ភៃថ្ងៃនៃរបបខ្មែរក្រហមបានធ្វើឲ្យប្រជាជនខ្មែរប្រហែលជិតពីរលាននាក់ស្លាប់បាត់បង់ជីវិតដោយសារការសម្លាប់ ការធ្វើការហួសកម្លាំងនិងការគ្មានថ្នាំព្យាបាល ។ អ្នកដែលបានឆ្លងកាត់របបនេះនៅតែមានរបួសស្នាមដក់ជាប់ក្នុងចិត្តមិនអាចបំភ្លេចបានដូចជាមីងរបស់ខ្ញុំឈ្មោះ ពីន ប៊ួយ ជាស្ត្រីមេម៉ាយរស់នៅជាមួយប្អូនស្រីព្រោះប្តីនិងកូនរបស់គាត់បីនាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហមអស់ហើយ ។

មុនឆ្នាំ១៩៧៥ មីងរបស់ខ្ញុំនិងស្វាមីគាត់ឈ្មោះ ឈី សុង-ហៀង រស់នៅយ៉ាងសុខដុមជាមួយកូន៣នាក់ (កូនស្រី២នាក់និងកូនប្រុសម្នាក់) នៅសង្កាត់លេខ៥ ក្រោយរោងកុនចេនឡាក្រុងភ្នំពេញ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោងប្រហែល៧ព្រឹក គ្រួសាររបស់មីងខ្ញុំបានធ្វើដំណើរទៅផ្សារដើមគដើម្បីលក់ត្រីងៀតតាមទម្លាប់ដូចសព្វដង ដោយគាត់បានយកកូនស្រីទីពីរឈ្មោះ ហុង ដែលមានអាយុ៦ឆ្នាំទៅជាមួយ ចំណែកឯកូនដទៃទៀតទុកឲ្យនៅចាំផ្ទះ ។ ពេលទៅដល់មុខផ្សារ ស្រាប់តែគាត់ឃើញក្រដាសជាច្រើនរបស់កងទ័ពខ្មែរក្រហមបិទនៅតាមខ្លោងទ្វារផ្សារថា «ហាមមិនឲ្យចូលទៅលក់ដូរអីវ៉ាន់ឬយករបស់របរអ្វីចេញពីផ្សារទាំងអស់» ។ បន្ទាប់មក ខ្មែរក្រហមបានប្រកាសថា សូមបងប្អូនចាកចេញពីទីក្រុង បើអ្នកណាហ៊ានរឹងរូសនឹងត្រូវបាញ់សម្លាប់ ។ ឃើញសភាពការណ៍នេះភ្លាម គ្មាននរណាម្នាក់ហ៊ានជំទាស់ទេ ។ ប៉ុន្តែ ដោយបារម្ភពីកូនពីរនាក់ទៀតនៅផ្ទះ ពូរបស់ខ្ញុំក៏លួចដើរត្រឡប់ទៅផ្ទះវិញដើម្បីយកកូនមកតាម ។ ពេលនោះ មីងខ្ញុំនិងកូនទីពីរក៏ដើរបណ្តើរៗទៅមុនតិចៗ ព្រោះថាបើចាំទៅទាំងអស់គ្នាខ្លាចយឺតដំណើរ ។ ម្យ៉ាងទៀតគាត់គិតថា ទៅតែរយៈពេល៣ថ្ងៃទេគាត់នឹងអាចវិលត្រឡប់មកវិញហើយ ។ ប៉ុន្តែ បីថ្ងៃ បីខែនិងសាមសិបឆ្នាំកន្លងទៅ នៅតែមិនឃើញប្តីនិងកូនទាំងពីរនាក់របស់គាត់ត្រឡប់មកទៀត ។

មីងរបស់ខ្ញុំនិងកូនស្រីត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ ។ រយៈពេលប្រហែលជាកន្លះខែគាត់ក៏បានមកដល់ស្អាងព្រែកជី ។ នៅទីនោះបានរយៈពេលពីរខែ កូនស្រីរបស់គាត់ឈ្មោះ ហុង បានចាប់ផ្តើមមានជំងឺដោយសារតែហូបអាហារមិនគ្រប់គ្រាន់ ។ ប៉ុន្មានថ្ងៃក្រោយមក សុខភាពរបស់កូនគាត់កាន់តែចុះខ្សោយទៅៗនិងលែងនិយាយស្តីអ្វីទាំងអស់ ។ មីងរបស់ខ្ញុំឃើញកូនមានសភាពបែបនេះ គាត់ពិតជាព្រួយបារម្ភនិងឈឺចិត្តខ្លាំងណាស់ ព្រោះមិនអាចជួយអ្វីកើត បានត្រឹមតែឈរមើលប៉ុណ្ណោះ ។ ពីរថ្ងៃក្រោយមកទៀត កូនរបស់គាត់ក៏ស្លាប់ទៅ ។ ចំណែករូបគាត់ត្រូវអង្គការជម្លៀសទៅខេត្តបាត់ដំបងទៀត ។ អង្គការបញ្ជាឲ្យគាត់ធ្វើការស្ទើរគ្មានពេលសម្រាក ដោយគាត់ត្រូវក្រោកតាំងពីព្រលឹមទៅធ្វើស្រែជាមួយប្រជាជននៅតំបន់នោះរហូតដល់ម៉ោងប្រហែលជា១២កន្លះថ្ងៃត្រង់ ទើបមានពេលហូបបបរ ។ ជួនកាលមីងរបស់ខ្ញុំមិនមានបបរហូបថែមទៀត ព្រោះតែគាត់ទៅក្រោយគេ ។ ប៉ុន្តែ ប្រហែលជាកន្លះខែក្រោយមក គាត់ទទួលបានបបរឆាប់វិញព្រោះគាត់ធ្វើការបានលឿនជាងមុន ។ បន្ទាប់ពីនោះមកគាត់ត្រូវទៅដកស្ទូងរហូតដល់ម៉ោង៥ - ៦ល្ងាចទើបអង្គការអនុញ្ញាតឲ្យសម្រាកនិងទៅបើកបបរ ។ ដោយសារតែហូបមិនឆ្អែត គាត់តែងតែឆ្លៀតទៅលួចបេះត្រកួនឬផ្ទីមកដាំលាយជាមួយបបរថែមទៀត ។ ប៉ុន្តែគាត់ត្រូវប្រថុយនឹងគ្រោះថ្នាក់ណាស់ ព្រោះពេលខ្លះគាត់ត្រូវរាកមួលដោយសារតែហូបរបស់ទាំងនេះ ។

ថ្ងៃមួយអង្គការបើកការប្រជុំ ដែលមានមិត្ត ហៃ ជាប្រធាន

ឡើងនិយាយអប់រំប្រជាជនឲ្យខិតខំធ្វើការជូនអង្គការ កុំខ្ជិលច្រអូស ភ្លាមនោះស្រាប់តែមានមិត្តនារីម្នាក់អាយុប្រហែល២០ឆ្នាំបាននិយាយត្អូញត្អែរអំពីការងារ ។ ប៉ុន្តែមិត្តនារីនោះនិយាយមិនទាន់ចប់ផង ស្រាប់តែមិត្ត ហៃ យកកាំបិតទៅចាក់ដើមទ្រូងហើយខ្វេះយកបេះដូងនារីនោះមកដាក់លើចានដើម្បីគំរាមដល់អ្នកដទៃកុំឲ្យយកតម្រាប់តាម ។ គ្មានប្រជាជនណាម្នាក់ហ៊ាននិយាយអ្វីទាំងអស់ សូម្បីតែបញ្ចេញទឹកមុខអាណិតមិត្តនារីដែលស្លាប់នោះក៏មិនហ៊ានផង ។ ពេលចប់ការប្រជុំ មីងរបស់ខ្ញុំបានជួបជាមួយអ្នកជិតខាងម្នាក់ដែលធ្លាប់រស់នៅក្បែរផ្ទះគ្នាតាំងពីមុនឆ្នាំ១៩៧៥ ។ គាត់មានអារម្មណ៍សប្បាយចិត្តណាស់ព្រោះគិតថាប្រហែលជាស្វាមីនិងកូនៗគាត់នៅក្បែរៗនោះដែរ ។ មីងរបស់ខ្ញុំក៏សួរគាត់ដើម្បីស្វែងរកព័ត៌មាន រំពេចនោះអ្នកជិតខាងនោះក៏ប្រែទឹកមុខជាក្រៀមស្រពោនហើយប្រាប់គាត់ថា «ប្តីនិងកូនរបស់ប្អូន ឯងស្លាប់តាំងពីប្រមាណកន្លះឆ្នាំមុន ម៉្លេះព្រោះតែអត់អាហារ» ។ ឮសម្តីនេះភ្លាម មីងរបស់ខ្ញុំតក់ស្លុតជាខ្លាំង ហើយនិយាយលែងចេញ ព្រោះគាត់មិនដឹងជារស់មានន័យអ្វីទៀត ។ អ្នកជិតខាងនោះបាននិយាយលួងលោម គាត់ឲ្យគាត់ចិត្តខ្លះទៅ ។

ប៉ុន្មានថ្ងៃក្រោយមក អង្គការក៏ជម្លៀសមីងរបស់ខ្ញុំទៅកន្លែងថ្មីទៀត ។ នៅទីនោះ គាត់បានជួបជាមួយប្អូនស្រីនិងប្អូនថ្លៃរបស់គាត់ ដោយអ្នកទាំងពីរនោះមានមុខងារជាអ្នកចិញ្ចឹមទា ។ អ្នកទាំងពីរនោះសំណាងណាស់ ព្រោះការងារនេះមិនសូវជាពិបាកប៉ុន្មានទេ ប៉ុន្តែនៅពេលយប់គាត់ត្រូវដាក់វេនគ្នាយាមទាកុំឲ្យបាត់ ប្រសិនបើមិនអីចឹងទេនឹងត្រូវអង្គការយកទៅវាយចោលហើយ ។ ពេលខ្លះមីងរបស់ខ្ញុំ ត្រូវអង្គការប្រើឲ្យរែកទឹកមួយថ្ងៃ២០អង្រែក ដែលនេះជាការងារពិបាកទ្រាំទ្រណាស់ព្រោះដៃជើងរបស់គាត់ឡើងហើមពោរដោយសារគ្មានអាហារហូបគ្រប់គ្រាន់ ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមករំដោះតំបន់ខ្លះបាន មីងរបស់ខ្ញុំក៏ធ្វើដំណើរត្រឡប់មកផ្ទះវិញ ។ សព្វថ្ងៃ មីងរបស់ខ្ញុំរស់នៅតែម្នាក់ឯងជាស្ត្រីមេម៉ាយជាមួយនឹងប្អូនស្រីគាត់នៅទីណា ។ **ថា ផល្លា**

## លិខិតពីមិត្តអ្នកអាន

### *សូមគោរពលោកនាយកមជ្ឈមណ្ឌលឯកសារស្វែងរកការពិតពីចម្ងាយ!*

ខ្ញុំបាទមានកិត្តិយសសូមប្រកាសជូនដំណឹងអំពីការស្រាវជ្រាវរកជនរងគ្រោះ!

នៅសម័យខ្មែរក្រហម ខ្ញុំរស់នៅភូមិតាឥន្ទ (បច្ចុប្បន្នហៅភូមិត្រពាំងវែងខាងលិច) ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត ។ កាលនោះខ្ញុំនៅកុមារតូចនៅឡើយ ។ ថ្ងៃមួយខ្ញុំបានជួបបុរសម្នាក់មាឌក្រអាញសាច់ដុំធំៗ សម្បុរស្រអែម គាត់ឈ្មោះ ឡុង អាន ជាអ្នកប្រដាល់កាលពីសង្គមចាស់ ។ ពេលខ្ញុំបានជួបនិងឃើញគាត់ អ្នកស្រុកខ្ញុំបានសុំឲ្យគាត់សាកបញ្ចេញក្បាច់ប្រដាល់មើល គាត់ក៏បានធ្វើឲ្យមើលដូចជាក្បាច់ចាប់ទាត់ធាក់យ៉ាងស្ទាត់ជំនាញគួរឲ្យចង់មើលនិងស្ងើចសរសើរពីវិជ្ជារបស់គាត់ ។ គាត់ជាប្រជាជនថ្មីមិនដឹងគាត់ជម្លៀសមកពីភូមិឃុំស្រុកខេត្តណាទេ មកនៅភូមិតារាជ្យជាប់នឹងភូមិរបស់ខ្ញុំ ។ ក្រោយមកខ្ញុំបានសាកសួររកឈ្មោះគាត់អ្នកភូមិបានប្រាប់ខ្ញុំថា គាត់ត្រូវគេយកទៅសម្លាប់បាត់ហើយ តែខ្ញុំមិនបានសួរថាតើគេយកគាត់ទៅសម្លាប់នៅកន្លែងណាទេ ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែនឹកឃើញគាត់និងសែនស្រណោះអំពីជីវិតរបស់គាត់ក៏ដូចបងប្អូនពូមីងខ្ញុំនិងជនរួមជាតិដែលទទួលរងគ្រោះត្រូវឈ្លបសម្លាប់ដូចសត្វធាតុ ។

ព័ត៌មានដែលខ្ញុំបានដឹងខាងលើចាត់ទុកជាការជូនដំណឹងដល់បងប្អូន សាច់ញាតិ ឪពុកម្តាយរបស់គាត់បានជ្រាបនឹងដឹងឮខ្លះៗតែប៉ុណ្ណោះ ។ ប្រសិនបើបងប្អូនមិនទាន់បានដំណឹងនេះ ហើយចង់ដឹងព័ត៌មានលម្អិតសូមអញ្ជើញទៅជួបអ្នកភូមិខាងលើប្រហែលនឹងបានដំណឹងបន្ថែមទៀតជាពុំខាន ។

សូមអរគុណក្នុងការចុះផ្សាយនូវដំណឹងនេះទុកជាប្រយោជន៍ដល់គ្រួសារទៅតាមផ្លូវធម៌ ឬជាប្រវត្តិសាស្ត្រផងដែរ ។

**គុងរ៉ា**

# រង់ចាំតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

មុនឆ្នាំ១៩៧០ គ្រួសារម្តាយខ្ញុំដែលមានសមាជិកជាច្រើន នាក់បានរស់នៅយ៉ាងមានសុភមង្គលនិងពោរពេញទៅដោយភាពសប្បាយរីករាយ នៅក្រោមដំបូលផ្ទះមួយ ស្ថិតនៅស្រុកស្អាង ខេត្តកណ្តាល ។ ប៉ុន្តែជីវភាពបែបនេះត្រូវបានផ្លាស់ប្តូរទៅវិញ ដោយសាររដ្ឋប្រហារឆ្នាំ១៩៧០ យន្តហោះអាមេរិកាំងចំនួន ១០-១៥គ្រឿង បានមកទម្លាក់គ្រាប់បែកជាច្រើនគ្រាប់រៀងរាល់ថ្ងៃ ។ ដោយសារតែស្ថានភាពច្របូកច្របល់បែបនេះ ជីដូនជីតាខ្ញុំបាននាំគ្រួសាររត់ភៀសខ្លួនទៅរស់នៅស្រុកមោងឫស្សី ខេត្តបាត់ដំបងវិញ ។ នៅទីនោះ ក្រុមគ្រួសារម្តាយខ្ញុំពុំសូវមានជីវភាពធូរធារប៉ុន្មានទេ ព្រោះជីដូនជីតាខ្ញុំរកស៊ីលក់ដូរបន្តិចបន្តួច ។ រីឯម្តាយខ្ញុំដែលមានអាយុទើបតែ១១ឬ១២ឆ្នាំ ពេលព្រឹកគាត់ត្រូវដើរលក់នំអាកោឬអន្សមអាំង ពេលថ្ងៃទៅម៉ាស៊ីនកិនស្រូវសុំអង្កាមយកមកអុំយកចុងអង្ករមកដាំបាយហូប ។

ឆ្នាំ១៩៧៤ គ្រួសារម្តាយខ្ញុំក៏បានផ្លាស់ទៅរស់នៅក្បែរវាលយន្តហោះថ្មី (ផ្សារក្រោមបច្ចុប្បន្ន) ខេត្តសៀមរាប ប្រកបមុខរបរធ្វើចម្ការនិងដាំបន្លែយកទៅលក់នៅឯផ្សារចាស់ដើម្បីផ្គត់ផ្គង់ជីវភាព ។ ទោះបីជាជីវភាពនៅពេលនោះហាក់ដូចជាពុំសូវសម្បូរយ៉ាងណាក៏ដោយ ក៏ការរស់នៅរបស់គាត់ទទួលបានសេចក្តីសុខនិងប្រកបដោយសុភមង្គលដែរ ។

នៅឆ្នាំ១៩៧៥ ពេលអង្គការបញ្ជាឲ្យជម្លៀសប្រជាជនចេញ គ្រួសារម្តាយខ្ញុំបានជួបនឹងកម្មាភិបាលខ្មែរក្រហមម្នាក់ដែលគាត់មិនស្គាល់ថាមានឈ្មោះអ្វីទេ ។ បន្ទាប់ពីបានជជែកគ្នាមួយសន្ទុះ ខ្មែរក្រហមនោះក៏ដឹងថាជីដូនជីតារបស់ខ្ញុំធ្លាប់រាប់អានគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងឪពុកម្តាយគាត់នៅពេលដែលរស់នៅស្រុកស្អាងព្រែកតូច ខេត្តកណ្តាល ។ ដោយមានការអាណិតអាសូរដល់គ្រួសារម្តាយខ្ញុំ ខ្មែរក្រហមនោះបានប្រាប់ឲ្យជីដូនជីតាខ្ញុំស្លៀកសម្លៀកបំពាក់ចាស់ៗ រួចកាត់សក់ឲ្យខ្លី ដើម្បីកុំឲ្យអង្គការចោទថាជានាយទុន ព្រោះតែគាត់មានសម្បុរ-ស ខ្លាចខ្មែរក្រហមឯទៀតយល់ច្រឡំ ។ គាត់ប្រាប់ទៀតថា បើអង្គការសួរកាលពីមុនធ្វើការអ្វី ឲ្យឆ្លើយប្រាប់ថាធ្វើជាកម្មករ បើមិនអ៊ីចឹងទេនឹងត្រូវជម្លៀសទៅរស់នៅតំបន់ឆ្ងាយៗ ដូចជាភ្នំគូលែន បន្ទាយស្រីនិងព្រះដាក់មិនខាន ។ ក្រោយមកទៀត ខ្មែរក្រហមបានជម្លៀសគ្រួសារម្តាយខ្ញុំឲ្យទៅភូមិអន្ទ្រង់ ខេត្តសៀមរាប ។ ពេលទៅដល់ ម្តាយខ្ញុំត្រូវចាត់តាំងឲ្យនៅក្រុមកងចល័តកាប់ដីនិងជីកប្រឡាយនៅរដូវប្រាំងនិងធ្វើស្រែនៅរដូវវស្សា ។ ចំណែកការហូបចុកវិញ ជួនកាលម្តាយរបស់ខ្ញុំហូបបាយ ជួនកាលបបរលាយជាមួយត្រកួន ។


គ្រួសាររបស់ ម៉ែន ពិចិត្រ ក្នុងឆ្នាំ១៩៨៥

នៅទីនោះបានប្រហែលជាមួយឆ្នាំ ម្តាយខ្ញុំត្រូវបានបញ្ជូនឲ្យទៅជីកប្រឡាយនៅទំនប់បារាំង ស្រះស្រង់និងបារាយណ៍ទឹកថ្លា រួចក៏បន្តទៅជីកប្រឡាយនៅជ្រាវ ដាំឪឡឹក ល្ពៅ ពោតនៅក្បែរមាត់ទន្លេសាបជិតភ្នំក្រោមរហូតដល់ម៉ោង១២យប់ទើបបានសម្រាក ។ ការងាររបស់ម្តាយខ្ញុំមិននៅមួយកន្លែងទេ មួយរយៈក្រោយមក គាត់ត្រូវបានបញ្ជូនឲ្យទៅធ្វើត្រីងៀតនៅភូមិឃ្លាំងក្បែរទន្លេសាប ដែលមានប្រជាជនប្រហែលជា៥០ទៅ៦០នាក់ ។ ព្រឹកឡើង ម្តាយរបស់ខ្ញុំមានភារកិច្ចធ្វើត្រី នៅពេលល្ងាចត្រូវយកត្រីដែលធ្វើហើយទៅប្រឡាក់និងម៉ោង៣ត្រូវក្រោកហាលត្រី ។ ប៉ុន្តែ ត្រីងៀតទាំងអស់នេះ ម្តាយរបស់ខ្ញុំមិនដឹងជាអង្គការដឹកយកទៅណាទេ ។ ពេលចប់រដូវសម្បូរត្រី អង្គការក៏បញ្ជូនម្តាយខ្ញុំឲ្យទៅគាស់គល់ឈើនៅលៃដើម្បីរានយកដីដាំដំឡូង ។ មុនពេលដែលកងទ័ពវៀតណាមបានចូលមកដល់ប្រហែលជាបីខែ បងស្រីម្នាក់ឈ្មោះ បងរី ដែលជាអ្នកមូលដ្ឋានបានមកខ្សឹបប្រាប់ម្តាយខ្ញុំថា «ពួកឯងត្រូវតែប្រយ័ត្នខ្លួន បីខែទៀតពួកឯងនឹងត្រូវពួកនិរតីមកពីខេត្តតាកែវយកទៅសម្លាប់ចោលហើយ ព្រោះឈ្មោះរបស់ពួកឯងមាននៅក្នុងបញ្ជីរបស់គេ» ។ ប៉ុន្តែ បង រី ក៏បានលួងលោមម្តាយខ្ញុំផងដែរថា «កុំភ័យអី ខំតែធ្វើការទៅ របបនេះនៅមិនបានយូរទេ» ។ បន្ទាប់ពីបានទទួលដំណឹងនេះ ម្តាយខ្ញុំមានការភិតភ័យជាខ្លាំង ទោះបីជាគាត់ចង់រត់ ក៏មិនដឹងជារត់ទៅទីកន្លែងណាដែរ ព្រោះគ្រប់ទីកន្លែងមានសុទ្ធតែកងទ័ពខ្មែរក្រហម ។ ដូច្នេះ ម្តាយរបស់ខ្ញុំមានតែខិតខំធ្វើការទាំងមានអារម្មណ៍ភ័យខ្លាច ។ នៅពេលកងទ័ពវៀតណាមបានចូលរំដោះនៅឆ្នាំ១៩៧៩ ស្នូរកាំភ្លើងបានផ្ទុះឡើងគ្រប់ទីកន្លែង ។ ពេលនោះ ម្តាយខ្ញុំកំពុងតែច្រូតស្រូវនៅកណ្តាលថ្ងៃក្តៅក៏រត់ត្រឡប់មកផ្ទះវិញជាមួយប្រជាជនមូលដ្ឋាន និងប្រជាជន១៧មេសាជាច្រើននាក់ ។

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ បងថ្លៃប្រុសរបស់ម្តាយខ្ញុំម្នាក់ឈ្មោះ ឡុង បានស្លាប់ដោយសារខាងនិរតីយកគាត់ទៅសម្លាប់ ព្រោះតែគាត់ជាមនុស្សស្និទ្ធស្នាលជាមួយគណៈតំបន់កាន់កាប់នៅទន្លេសាបឈ្មោះតា ញ ។ គាត់ក៏នៅតែមិនអាចបំភ្លេចបានដែរគឺមិត្តរួមការងារជាមួយម្តាយខ្ញុំពីរនាក់ឈ្មោះ រី និង រ៉ាន់ ជាអតីតគ្រូបង្រៀននៅសម័យលន់ នល់ ត្រូវខ្មែរក្រហមចងស្លាបសេកនិងរុំមុខជិត រួចអូសតាមកន្លែងបណ្តើរយកទៅសម្លាប់នៅពេលថ្ងៃត្រង់ ពេលគាត់ទាំងពីរនាក់កំពុងធ្វើការ ។

ចំណែកឪពុកខ្ញុំមុនឆ្នាំ១៩៧០ មានអាយុ១១ឆ្នាំ ជាសិស្សថ្នាក់ទី៧ (សង្គមចាស់) នៅសាលាបឋមសិក្សាព្រះកៅឌិណ្ឌ រស់នៅឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឪពុកខ្ញុំមានបងប្អូនប្អូននាក់ (ស្រី១ ប្រុស៣) ។ នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមបានឡើងកាន់អំណាច គ្រួសារគាត់ត្រូវបានជម្លៀសទៅស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់ធ្វើការងារជាច្រើន ដូចជាលើកទំនប់នៅស៊ីងខ្ទបត្របែក កាប់ដីដំបូកនិងរែកដីដាក់ស្រែ ។ បន្ទាប់ពីនោះ គាត់ត្រូវបានបញ្ជូនឲ្យទៅជីកប្រឡាយនៅឃុំត្រពាំងធំដើម្បីយកទឹកធ្វើស្រែប្រាំង លើកទំនប់នៅតាកែនកោះស្លា រួចផ្លាស់ឲ្យទៅដាំដំណាំ ដូចជាដាំស្ពៃ ល្ពុងជាដើម ដោយក្នុងមួយថ្ងៃគាត់ត្រូវរែកទឹកស្រោចដំណាំឲ្យបាន២០០អម្រែក ។ ចំពោះរបបអាហារវិញ នៅរដូវច្រូតគាត់ហូបបាយជាមួយសម្លម្ជូរព្រលិតឬត្រកួន នៅរដូវវស្សាហូបបបរជាមួយសម្លម្ជូរព្រលិត ។

នៅឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមចូលមកដល់ ខ្មែរក្រហមបានកៀរប្រជាជនទៅដល់ភ្នំក្រឡើតនៅខេត្តកំពង់ស្ពឺ ។ ពេលនោះឪពុករបស់ខ្ញុំបានរត់កៀសខ្លួនទៅស្រុកខត្តុង្គ ហើយក៏ត្រឡប់មកស្រុកកំណើតវិញ ។ គ្រួសាររបស់ឪពុកខ្ញុំមិនមានបាត់បង់សមាជិកគ្រួសារណាម្នាក់ទេ ។

ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅអស់រយៈពេល៣០ឆ្នាំក៏ដោយ រឿងរ៉ាវទាំងអស់នេះនៅតែដក់ជាប់ក្នុងចិត្តរបស់ឪពុកម្តាយខ្ញុំជានិច្ច ។ សំណួរជាច្រើននៅក្នុងគំនិតរបស់គាត់នៅតែគ្មានចម្លើយ ថាតើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាពលរដ្ឋឯងនិងធ្វើឲ្យប្រទេសជាតិមួយដែលធ្លាប់តែសម្បូរសប្បាយប្រែក្លាយទៅជាប្រទេសមួយប្រឡាក់ទៅដោយឈាម ។

សព្វថ្ងៃនេះ អ្វីៗនឹងត្រូវបានលាតត្រដាងបន្តិចម្តងៗ ដោយសារតែមេដឹកនាំខ្មែរក្រហមធំៗត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការឃុំខ្លួនជាបណ្តោះអាសន្ន ។ ដូច្នេះ នេះជាពេលវេលាមួយដែលឪពុកម្តាយខ្ញុំព្រមទាំងជនរងគ្រោះនៅទូទាំងប្រទេសកំពុងរង់ចាំការកាត់ទោសនេះប្រកបដោយភាពយុត្តិធម៌មិនខាន ។ **ម៉ែន ពិចិត្រ**

# បំភ្លេចមិនបាន

នាងខ្ញុំឈ្មោះ សោ ភា កើតនៅថ្ងៃទី៧កុម្ភៈ ឆ្នាំ១៩៧៦ ក្នុងរបបប៉ុលពតយ៉ាត ។ ឪពុកខ្ញុំឈ្មោះ ចិន ស៊ា ហៅ ហាវ ហាន នៅខេត្តស្វាយរៀង ម្តាយឈ្មោះ ញ៉ែម សុផាត នៅខេត្តកំពង់ធំ ។

ជិតបីទសវត្សរ៍ដែលគ្រួសារនាងខ្ញុំនិងខ្មែរទាំងអស់រង់ចាំយុត្តិធម៌ ។ ខ្ញុំនៅចាំបានថា ម៉ែធ្លាប់និយាយពីគុណសម្បត្តិរបស់ឪពុកប្រាប់ខ្ញុំជានិច្ចថា ឪពុកខ្ញុំជាមនុស្សល្អមានគុណធម៌ មានឧត្តមគតិ និងជាមនុស្សស្លូតបូត រាប់អានមនុស្សមិនរើសវណ្ណៈ ដូច្នេះហើយទើបខ្ញុំមានអារម្មណ៍ថា ខ្ញុំមានសំណាងដែលបានកើតជាកូនរបស់គាត់ ប៉ុន្តែខ្ញុំសោកស្តាយដែលគ្រួសារខ្ញុំត្រូវព្រាត់ប្រាសពីគាត់ទៅដោយមិនអស់ចិត្តជារៀងរហូត ។

ឪពុកខ្ញុំជាកម្មាភិបាលភាគខាងជើងនៅអង្គភាព «គ-៩២» គាត់រៀបការជាមួយម៉ែនៅឆ្នាំ១៩៧៥ នៅពេលប្រទេសជាតិរំដោះផុតពីចក្រពត្តិអាមេរិក ។ ពេលគាត់រៀបការជាមួយម៉ែ អង្គការបានចាត់តាំងឲ្យអង្គភាពរបស់គាត់ផ្លាស់ទៅបម្រើការនៅភ្នំពេញ ។ នៅខែកញ្ញា ឆ្នាំ១៩៧៥ ពេលនោះម៉ែមានផ្ទៃពោះ ម៉ែរអ៊ូមិនចង់ទៅជាមួយឪពុកខ្ញុំទេ ព្រោះម៉ែស្អប់ការធ្វើបដិវត្តន៍ណាស់ ។ ម៉ែរំឭកថា ពេលធ្វើដំណើរទៅ ក្រុមរបស់ឪពុកខ្ញុំត្រូវបានដកហូតអាវុធទាំងអស់គ្នា ។ គាត់ធ្វើដំណើរទៅតាមផ្លូវជាតិលេខ៧១ឆ្ពោះទៅខេត្តកំពង់ចាម ។ បន្ទាប់មក ឡើងកាណូតបន្តទៅភ្នំពេញទៀត ។ អ្វីដែលម៉ែស្មានមិនដល់គឺទិដ្ឋភាពទីក្រុងភ្នំពេញស្ងាត់ជ្រងំមានតែកងទ័ពអាវខ្មៅដើរមួយៗ ស្ពាយកាំភ្លើងស្ទើរមិនផុតពីដី ។ ម៉ែមានចិត្តមួយគិតថា ប្រាកដជាមានអ្វីមួយកើតឡើងខុសប្រក្រតីហើយ ម៉ែលួចខ្សឹបជាមួយឪពុកខ្ញុំថា យើងមានអ្វីមិនស្រួលហើយ តែឪពុកខ្ញុំបានត្រឹមតែប្រាប់ថា កុំមាត់គេកំពុងរៀបចំប្រទេសឲ្យមានការចាយលុយដូចធម្មតាហើយ ប៉ុន្តែម៉ែមិនជឿទេព្រោះឪពុកខ្ញុំក៏គាត់មិនសូវដឹងពីផែនការអង្គការអាវខ្មៅនេះប៉ុន្មានដែរ ។ តាំងពីទៅដល់ភ្នំពេញ គ្រួសារកងទ័ពទាំងអស់ត្រូវបានចាត់តាំងឲ្យទៅនៅម្តុំបឹងត្របែក ម៉ែរំឭកថា ការរស់នៅទីនោះគឺមិនខុសពីទាសកររបស់អង្គការទេ ប្តីធ្វើការងារប្តី ប្រពន្ធធ្វើការងារប្រពន្ធ ការងារអ្នកណាអ្នកនោះធ្វើ ពេលនោះដែលម៉ែលំបាកបំផុត របបអាហារមិនគ្រប់គ្រាន់ ជាពិសេសស្ត្រីមានផ្ទៃពោះដូចជាម៉ែរឹតតែពិបាកថែមទៀត ។

នៅចុងឆ្នាំ១៩៧៥ ការបោសសម្អាតខ្មាំងរបស់អង្គការចាប់ផ្តើមបណ្តើរៗ មេដឹកនាំធំរបស់ឪពុកខ្ញុំឈ្មោះ «ភឹម» ត្រូវអង្គការចាប់ខ្លួនទៅមុនគាត់ បន្ទាប់មក ពួកវាចាប់ផ្តើមចាប់ពុកនិងមិត្តរួមការងាររបស់គាត់ទៀត ។ ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ ជាថ្ងៃដែលម៉ែបែកចេញពីពុក ។ ម៉ែនៅចាំសម្តីចុងក្រោយរបស់ពុកដែលផ្តាំគាត់ថា «គេឲ្យបងទៅមុន ទៅធ្វើផ្ទះ ចាំធ្វើផ្ទះរួចបងមកទទួល ។ ថែរក្សាខ្លួនផង ។ បើកូនកើតមកជាស្រីដាក់ឈ្មោះថា សោភា បើជាកូនប្រុសចាំបងដាក់ឈ្មោះឲ្យក្រោយពេលគាត់ត្រឡប់មកវិញ» ។ ដោយសារខ្ញុំកើតមកជាកូនស្រី ទើបម៉ែដាក់ឈ្មោះតាមបណ្តាំឪពុកខ្ញុំ ។ ពេលនោះ ម៉ែបានសុំគាត់ទៅជាមួយដែរ ប៉ុន្តែឪពុកខ្ញុំបដិសេធ ។ តាំងពីនោះមក ឪពុកខ្ញុំបាត់ខ្លួនរហូត ចំណែកម៉ែធ្វើការងាររហូតដល់ថ្ងៃសម្រាលខ្ញុំ ។ ពិតជាលំបាកណាស់ ម៉ែសម្រាលខ្ញុំទាំងគ្មានថ្នាំព្យាបាលនិងគ្មានញាតិបងប្អូននៅក្បែរគាត់ឡើយ ។ ម៉ែស្រឡាញ់ខ្ញុំស្មើកែវភ្នែក ពេលម៉ែចេញទៅធ្វើការ ម៉ែតែងតែផ្តែផ្តាំមិត្តភក្តិឲ្យជួយមើលថែខ្ញុំឲ្យល្អផង ។ ពេលខ្ញុំមានអាយុបីខែ អង្គការបានហៅម៉ែនិងស្ត្រីជាច្រើនរូបទៅប្រជុំ ហើយប្រាប់ថា «គ្រួសារមិត្តទាំងអស់អង្គការកម្ទេចហើយ ព្រោះជាជនក្បត់» ។ ពេលនោះម៉ែស្រឡាំងកាំងនិយាយលែងចេញ តាំងពីពេលនោះមក ម៉ែមានវិបត្តិផ្លូវចិត្តជាខ្លាំង ប៉ុន្តែម៉ែមិនភ្លេចតួនាទីជាម្តាយដ៏ល្អទេ ។ សុខភាពម៉ែចាប់ផ្តើមទ្រុឌទ្រោមបន្តិចម្តងៗ ។ ក្រោយមក គេផ្លាស់ម៉ែឲ្យទៅនៅក្បាលជ្រោយ ម៉ែបីកូនលួចរង់ចាំពុកជារៀងរាល់ថ្ងៃ ប៉ុន្តែការទន្ទឹងរង់ចាំបានត្រឹមតែផ្តាំតាមខ្សែទឹកទន្លេដែលហូរទៅបាត់ប៉ុណ្ណោះ ។ ក្រោយមក អង្គការផ្លាស់ម៉ែឲ្យទៅនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដោយប្រើម៉ែកាប់រណ្តៅដាំចេកមួយថ្ងៃឲ្យបាន៣០រណ្តៅ កាប់ខស មើលថែកុមារ និងពេលយប់បកសណ្តែកដី ។ ពេលនោះខ្ញុំមានជំងឺកញ្ជ្រឹល គ្មានថ្នាំ

ព្យាបាល ខ្ញុំចាប់ផ្តើមឈឺធ្ងន់រហូតដល់ម៉ែអស់សង្ឃឹមគាត់ដើរកាប់ដើមដំឡូងគរទុកសម្រាប់ដុតសាកសពខ្ញុំ ។ ប៉ុន្តែសំណាងល្អ ម៉ែស្រាប់តែនឹកឃើញដល់ថ្នាំដែលឪពុកខ្ញុំទុកឲ្យប្រើ ហើយលួចខ្សឹបគ្រូពេទ្យម្នាក់ឲ្យជួយមើលថ្នាំនេះ ហើយគាត់បានឲ្យខ្ញុំផឹករហូតជាសះស្បើយ ។

ថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ប្រទេសរួចផុតពីរបប ប៉ុល ពត ម៉ែបានពខ្ញុំរត់កាត់គ្រាប់ កាត់ព្រៃឆ្ពោះមកស្រុកកំណើតនៅខេត្តកំពង់ធំ ។ ម៉ែតែងសើបសួរគេឯងដែលធ្លាប់ស្គាល់ឪពុកខ្ញុំក្រែងបានទទួលដំណឹងពីគាត់ តែលទ្ធផលគឺគ្មានដំណឹងអ្វីទាំងអស់ ។

ឆ្នាំ១៩៩៣ នៅពេលមានកិច្ចបោះឆ្នោតរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ម៉ែរង់ចាំឪពុកខ្ញុំម្តងទៀត ប៉ុន្តែនៅតែគ្មានដំណឹង ។ ទោះយ៉ាងណាក៏ដោយ ក៏ម៉ែរក្សាភក្តីភាពជាមួយឪពុកខ្ញុំរហូតដល់ពេលនេះ ម៉ែប្រាថ្នាជួបពុកនៅជាតិក្រោយៗទៀត ។ របបវាលពិឃាតបានកែប្រែជីវិតប្រជាជនខ្មែរឲ្យផ្លាស់ប្តូរមិនទៀង ជីវិតស្ថិតស្រពោននៅក្នុងមាតុភូមិដ៏អភ័ព្វដែលធ្លាប់តែល្បីរន្ទឺនៅលើពិភពលោក ហើយបែរជាមានស្ត្រីមេម៉ាយ កុមារកំព្រាគ្មានទីជម្រកស្នាក់អាស្រ័យ ។ ម៉ែបានលាក់ទុកនូវវិបត្តិផ្លូវចិត្តគាត់មិនហ៊ានបង្ហាញឲ្យដឹងទេ ដើម្បីកសាងជីវិតថ្មីនៅលើទឹកដីកំណើត ។

ឆ្នាំ២០០៦ ខ្ញុំបានទៅលេងប្អូនឪពុកខ្ញុំនៅភ្នំពេញ ពូមីងនិងបងស្រីជីដូនមួយបានប្រាប់ខ្ញុំថា មជ្ឈមណ្ឌលឯកសារកម្ពុជារកឃើញឯកសារស្តីពីការស្លាប់របស់ឪពុកខ្ញុំនៅគុកទួលស្លែង ។ ពេលនោះខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំងស្ទើរស្រែកឲ្យអស់ចិត្ត តែខ្ញុំទប់ស្មារតីត្រឡប់មកកំពង់ធំវិញ ហើយខ្ញុំប្រាប់ម៉ែតាមដំណើររឿង ។ ម៉ែប្រែទឹកមុខស្រពោនភ្លាម ម៉ែមិនស្មានថាគេយកពុកទៅទួលស្លែងដែលនៅជិតបង្កើយ តែគាត់មិនដឹង ។ ម៉ែកាន់តែរន្ធត់ពេលឮថាគុកទួលស្លែង ម៉ែនឹកដល់បទចម្រៀងមួយបទដែលមានចំណងជើងថា «ទួលស្លែងគុកធំឲ្យខ្ញុំទឹកភ្នែក» ម៉ែស្រក់ទឹកភ្នែកនឹកដល់ស្វាមីជាទីស្រឡាញ់ មិនដឹងជាស្លាប់វេទនាយ៉ាងណាទេ ។

រយៈពេលមួយខែបន្ទាប់ ម៉ែសម្រេចចិត្តមកទីក្រុងភ្នំពេញ ពូបានជូនម៉ែទៅមើលសារមន្ទីរគុកទួលស្លែង ម៉ែសែនស្តុតចិត្តជាមួយនឹងឧបករណ៍ដែលខ្មែរក្រហមប្រើប្រាស់ធ្វើទារុណកម្មអ្នកទោស ម៉ែប្រញាប់ទៅមើលអគារ «គ» បន្ទប់ធំ «៥» បន្ទប់តូច «៤» តាមឯកសារដែលម៉ែទទួលបាន ។ ម៉ែស្រក់ទឹកភ្នែក នៅពេលឃើញរូបថតឪពុកខ្ញុំត្រូវឃុំឃាំងមុនពេលស្លាប់យ៉ាងអយុត្តិធម៌ ។ ម៉ែត្រឡប់មកផ្ទះវិញ ហើយម៉ែទៅភ្នំពេញម្តងទៀតដោយមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសុំឲ្យជួយចម្លងរូបថតឪពុកខ្ញុំពីរសន្លឹកគ្រាន់ទុកឲ្យខ្ញុំមើល ។

ទាំងនេះជាសោកនាដកម្មនៃរបបអាវខ្មៅដែលគិតខុសអនុវត្តខុសទ្រឹស្តីធ្វើឲ្យប្រទេសលិចលង់ក្នុងវិបត្តិភ័យគ្រប់ជំពូក ។ សុវណ្ណភូមិដែលធ្លាប់ស្រស់បំព្រងប្រែជាគ្របដណ្តប់ទៅដោយស្បែពណ៌ខ្មៅ ក្រាលដោយឆ្អឹង ឈាមនិងទឹកភ្នែកប្រជាជនកម្ពុជា ។ ទោះប្រទេសជាតិបានរំដោះយូរឆ្នាំហើយក៏ដោយ ក៏នៅមានបន្សល់ទុកស្នាមឈឺចាប់របស់ប្រជាជនខ្មែរគ្រប់ស្រទាប់ ។

ដូច្នេះដល់ពេលហើយដែលប្រជាជាតិទាំងមូលត្រូវការរកយុត្តិធម៌ឲ្យសាច់ញាតិ ឪពុកម្តាយ បងប្អូននិងប្រទេសជាតិទាំងមូលកុំឲ្យមានរបបខ្មៅងងឹតនេះគ្របដណ្តប់លើពិភពលោកយើងតទៅទៀត ។ ពេលវេលាដល់ហើយដែលមេដឹកនាំកំពូលក្នុងរបបនោះត្រូវលាតត្រដាងការពិត ហើយមិនមែនឆ្លើយយកតែរួចខ្លួនរៀងៗខ្លួននោះទេ គួរតែទទួលស្គាល់នូវទង្វើដែលខ្លួនបានប្រព្រឹត្តក្នុងរបបដែលខ្លួនទទួលខុសត្រូវ ។ ជាបញ្ចប់សូមជូនពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជាសូមទទួលបាននូវជោគជ័យគ្រប់ភារកិច្ចដែលបានបំពេញដើម្បីប្រជាជនខ្មែរទាំងអស់ ។ **ហាន សោភា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*



ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 101 , May 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.